ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី៩)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាចាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក យ៉េត ចរិយា

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ បេ៊ត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទូអាត ហ្វដ*(M.r Stuart FORD)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

(*Ms. Heleyn* UÑAC)

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យ៉ុង ផានិត

លោកស្រី ស៊ីលឃិ ស្ទូតហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

កញ្ញា ម៉ុច សុវណ្ណារី

លោក ការីម ខាន *(Mr. Karim KHAN)*

លោក អាឡាំង វែនណឺ *(Mr. Alain WERNER)*

លោក ហ្វីលីព កាណុន *(Mr. Philippe CANNONE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

# សាក្សី

**សាក្សី ៖** KW-32: ចាន់ ខន

សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ១
សួរដោយ លោក យ៉េត ចរិយា ផ្តើមពី....................ទំព័រ ១១
សួរដោយ លោក អាឡិច សាន់ឌឺ បេ៊ត ផ្តើមពី ....................ទំព័រ ១៤
សួរដោយ កញ្ញា ទី ស្រ៊ីនណា ផ្តើមពី ....................ទំព័រ ២៧
សួរដោយ លោក ការីម ខាន ផ្តើមពី ....................ទំព័រ ៣០
សួរដោយ លោកស្រី ស៊ីលឃិ ស្ទូតហ្សិនស្គី ផ្តើមពី ....................ទំព័រ ៣៤
សួរដោយ លោក ហ្វីលីព កាណុន ផ្តើមពី ....................ទំព័រ ៤៧
សួរដោយ លោក ហុង គឹមសួន ផ្តើមពី....................ទំព័រ ៦២
សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្តើមពី ....................ទំព័រ ៦៥

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អាឡិចសាន់ឌឺ ប៊ែត | អង់គ្លេស |
| លោក ហ្វីលីព កាណុន | បារាំង |
| លោក ចាន់ ខន (សាក្សី) | ខ្មែរ |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ខារីម ខាន | អង់គ្លេស |
| លោក គង់ ពិសី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី ស៊ីលឃិ ស្តូតហ្សីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធាអង្គជំនុំជម្រះ) | ខ្មែរ |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក យ៉េត ចរិយា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០៥:៤៣]

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការសវនាការ ។ ហើយជាបន្តនេះ សូមប្រគល់វេទិកានេះទៅចៅក្រម ហ្សង់ម៉ាក ដើម្បីបន្តសួរដល់សាក្សីរូបនេះជាបន្តទៀត ។ សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សាក្សីគឺគាត់-- លោក ចាន់ ខន តើលោកយល់ខ្ញុំដែរ ឬទេ? លោកស្តាប់បានដែរ ឬទេ?

**សាក្សី KW-32៖**

**ឆ៖** ស្តាប់បាន ។

**ស៖** ថាលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ ថាស្ថិតនៅក្នុងស្ថានភាពអ្វីដែលលោកចាកចេញពី ម-១៣ ហើយដោយសារមូលហេតុអ្វីបានជាលោកចេញពី ម-១៣?

**ឆ៖** មូលហេតុដែលយើងខ្ញុំចេញពី ម-១៣ ដោយខ្ញុំអនុវត្តទៅតាមការដឹកនាំនិងបញ្ជារបស់ តា ឌុច មិនបាន ។

**ស៖** ថាតើ ឌុច បាននិយាយអ្វីខ្លះដល់លោក?

**ឆ៖** ឌុច អត់បាននិយាយពីអ្វីទេ គ្រាន់ថាបញ្ជូនខ្ញុំឲ្យទៅរស់នៅ-- ធ្វើស្រែនៅអូរព្រាលខាងលិចត្រពាំងត្រើញហ្នឹង ។ គឺទៅធ្វើស្រែគាស់គល់ លើកទំនប់ អីចឹងទៅ ។

ស៖ ថាតើមានអ្នកទោសដែលមាននៅក្នុងវាលស្រែធ្វើការងារដែរឬទេ? គឺមានមនុស្សដូចលោកដែរឬទេ នៅពេលដែលទៅធ្វើការ ធ្វើស្រូវនោះ?

**ឆ៖** មាន អ្នកទោសក៏មាន កងការពារយើងក៏មាន តែគ្មានអាវុធ គ្មានកាំភ្លើងអីនៅខ្លួនទេ គឺមានតែកាំបិត ពូថៅ ចបកាប់ តែប៉ុណ្ណោះ ។

**ស៖** ថាតើលោកមានតួនាទីអ្វីនៅទីនោះ? គឺលោកនៅធ្វើការនៅ-- ធ្វើស្រែនៅទីនោះ ឬក៏លោក

ជាអ្នកយាមនៅទីនោះ?

[០៩:០៨:៤៥]

**ឆ៖** ចំពោះរូបខ្ញុំដែលទៅរស់នៅនុ៎ង គឺជា-- ដូចជាប្រជាជន ឬមួយក៏ដូចជាអ្នកធម្មតាទាំងអស់គ្នា ។ គឺគ្មានអ្នកយាម អ្នកកាមអីទេ គឺទៅធ្វើស្រែចម្ការ គាស់គល់ អ៊ីចឹងទៅ លើកភ្លឺ លើកទំនប់អីទាំងអស់គ្នា គឺអត់មានណាយាមណាទេ ទៅរស់នៅកន្លែងនុ៎ង ។

**ស៖** ប្រសិនបើមិនមានការយាមទៅដល់អ្នកទាំងអស់នោះ ដូច្នេះថាវាមានភាពស្របគ្នា-- គឺមានអ្នកទោស ដូច្នេះហើយគឺត្រូវតែមានអ្នកយាម បើសិនជាមិនអ៊ីចឹងទេ គឺអត់មានអ្នកទោសនោះទេ ។

**ឆ៖** អ្នកទោសនុ៎ង គឺចេញពីកន្លែងហ្នឹងទៅ ដែលអ្នកស្រាលៗដែលខុសវិន័យល្មមៗ គេយកទៅដាក់នៅនុ៎ង ដូចជា តាស៊ិន អ៊ីចឹង គេយកទៅដាក់នៅនុ៎ង ធ្វើការស្រែនៅនុ៎ង ដូច តាអ៊ុន អ៊ីចឹង គឺគេយកទៅដាក់នៅនុ៎ង ឲ្យធ្វើស្រែ ធ្វើចម្ការ គាស់គល់ អ៊ីហ្នឹង រួមទាំងអ្នកកងការពារដែលទៅនៅនុ៎ង គឺដែលគោរពវិន័យការចាត់តាំងមិនបានហ្នឹង គឺគេប្រមូលយកទៅដាក់នៅនុ៎ង ។ ធ្វើស្រែចម្ការហ្នឹងតែម្ដង ។

**ស៖** នៅពេលដែលលោកនិយាយអំពី អ៊ុន លោកអាចនិយាយបញ្ជាក់ឲ្យបានច្បាស់លាស់ដែរ ឬទេ? ថាតើគាត់មានឈ្មោះពេញហ្នឹងទាំងអស់ហៅអ្វី? ដែលលោកនិយាយអំពី អ៊ុន ហ្នឹង?

**ឆ៖** ឮតែគេហៅអ៊ីចឹងដែរ អត់ដឹងឈ្មោះអីពីដើម ។ ដឹងថាគឺនៅនុ៎ងឃើញតែអ៊ីចឹងដែរ ឃើញគេហៅឈ្មោះ អ៊ុន គឺនៅរស់ជាមួយគ្នាធ្វើស្រែ ធ្វើចម្ការហ្នឹង ។ រហូតដល់ឆ្នាំ៧៥ ហ្នឹងបានទើបខ្ញុំ គេបញ្ជូនរស់នៅធ្វើកងចល័តនៅឧដុង្គ បែកគ្នាត្រឹមហ្នឹង ។

**ស៖** គេមានឲ្យលោករៀបចំធ្វើប្រវត្តិរូបដែរ ឬទេនៅពេលដែលលោកនៅ ម-១៣?

**ឆ៖** តាឌុច គាត់ឲ្យធ្វើប្រវត្តិរូបសង្ខេប ។ ហ្នឹង តាឌុច គាត់អ្នកបញ្ជាឲ្យធ្វើប្រវត្តិរូបសង្ខេបហ្នឹង ។

**ស៖** តើគេប្រាប់លោកថា ប្រវត្តិរូបល្អ ឬក៏អាក្រក់ ឬយ៉ាងម៉េច?

**ឆ៖** គេមិនបានប្រាប់ប្រវត្តិរូបអាក្រក់ ល្អអីទេ គឺគេអត់បានប្រាប់ទេ តែគ្រាន់គេធ្វើហើយគេបញ្ជូនខ្ញុំហ្នឹងទៅនៅឯនុ៎ងតែម្ដង ។

**ស៖** គឺបន្ទាប់ពីលោកធ្វើប្រវត្តិរូបទើបលោកទៅធ្វើការ នៅធ្វើនៅស្រែ បន្ទាប់ពីលោកចាកចេញ

ទីនោះ ឬយ៉ាងម៉េច?

[០៩:១២:៤៦]

**ឆ៖** ពេលដែលធ្វើប្រវត្តិរូបហើយហ្នឹង គឺគាត់បញ្ជូនខ្ញុំហ្នឹងទៅរស់នៅធ្វើស្រែរហូតទៅដល់ឆ្នាំ ៧៥ហ្នឹង ទើបវាយរំដោះភ្នំពេញហ្នឹង គឺបញ្ជូនមកនៅខដុង្គតែម្តង ធ្វើកងចល័តនៅខដុង្គហ្នឹងតែម្តង ។

**ស៖** នៅក្នុងប្រវត្តិរូបលោក តើលោកបាននិយាយថាគ្រួសាររបស់លោកមួយចំនួន គឺជាប់ពាក់ព័ន្ធជាមួយនឹងរបប លន់ នល់ ឬក៏ជាសមាជិកនៃទាហាន លន់ នល់ ដែរឬទេ?

**ឆ៖** នៅក្នុងប្រវត្តិរូបហ្នឹង ខ្ញុំសរសេរថា ឪពុករបស់ខ្ញុំបានធ្វើទាហានសម្តេច សីហនុ ហ្នឹង តែមិនដឹងគាត់ធ្វើរយៈប៉ុន្មានខែ ប៉ុន្មានឆ្នាំ គឺខ្ញុំអត់ដឹងទេ ។ ដឹងថាគាត់ហ្នឹងធ្វើទាហានសម្តេច សីហនុ ។ អ៊ីចឹងហើយ គាត់ជាប់និន្នាការរដ្ឋការ អ៊ីចឹងខ្ញុំជាកូនរដ្ឋការដែរ ត្រូវថ្នាក់លើដកចេញតែម្តង ។

**ស៖** ដូច្នេះ តើលោកគិតថា បញ្ហានេះគឺជាមូលហេតុដែលគេបញ្ជូនលោកទៅធ្វើស្រែ គឺវាបានបង្ហាញថា ឪពុករបស់លោកគឺជាទាហានរបស់ សីហនុ ?

**ឆ៖** ដូចខ្ញុំបញ្ជាក់ខាងដើមរួចហើយថា ខ្ញុំអនុវត្តទៅតាមផែនការគោលនយោបាយរបស់ តាឌុច អត់បាន ។ ហើយមួយទៀត គឺមានការពាក់ព័ន្ធនឹងឪពុកម្តាយជាប់និន្នាការកូនរដ្ឋការថែមទៀត គឺគួបផ្សំនឹងការអនុវត្តរបស់ខ្លួនមិនបានសម្រេចទៅតាមផែនការរបស់ តាឌុច ដាក់ហ្នឹងហើយទើប តាឌុច ត្រូវដកចេញពីកងការពារជាបន្ទាន់ ។

**ស៖** លោកចាំអ្នកយាមជាមួយលោកដែលក្រោយមកត្រូវបានទៅជាមួយ ឌុច ទៅភ្នំពេញដែរឬទេ?

**ឆ៖** បញ្ជាក់មួយសាទៀត ។ អានមួយសារទៀតឲ្យច្បាស់បានអាចឆ្លើយត្រូវ ។

**ស៖** ក្នុងចំណោមសមមិត្តដែលជាអ្នកយាមដូចលោកនៅម-១៣ តើលោកចាំទេថា អ្នកយាមមួយចំនួននោះបានទៅជាមួយ ឌុច ទៅភ្នំពេញ?

**ឆ៖** ចំពោះរឿងបញ្ហាដែលកងការពារដែលបានមករស់នៅភ្នំពេញគឺយើងខ្ញុំអត់ដឹងទេ ព្រោះពេលនោះគឺគេនៅឯមន្ទីរ-១៣ កន្លែងឃុំឃាំងឯណោះ ។ ហើយខ្ញុំនៅឯកន្លែងធ្វើស្រែឯណោះ។ ដល់ពេលការបញ្ជូនយើងខ្ញុំទៅក៏ខ្ញុំអត់ដឹងគេហ្នឹងទៅពីថ្ងៃណា? ផ្នែរណាដែរ? តែអ្នកដែលរួមទៅជាមួយខ្ញុំមានគ្នាច្រើនដែរ ។

**ស៖** នៅពេលដែលលោកនិយាយថាច្រើនហ្នឹង តើចំនួនប៉ុន្មានដែរ ដែលលោកមានន័យថាច្រើនហ្នឹង?

**ឆ៖** ទៅជាមួយយើងខ្ញុំប្រហែលជាដប់នាក់ជាងហើយ ទាំងកងការពារផងទាំងអ្នកទោសដែលត្រូវទៅជាមួយហ្នឹង ។ គ្រាន់តែយើងខ្ញុំមិនចាំឈ្មោះ គឺខ្ញុំភ្លេចអស់ហើយវាយូរឆ្នាំពេក តែគ្រាន់តែដឹងថាប្រហែលជាដប់នាក់ជាង ។ ធ្វើដំណើរទៅដើរតាំងពីអមលាំងទៅ មករហូតខដុង្គហ្នឹង ។

**ស៖** ក្នុងចំណោមដប់នាក់នេះ ថាតើមានអ្នកទោសប៉ុន្មាន? និងអ្នកយាមប៉ុន្មានដែរក្នុងចំណោមដប់នាក់នុំង?

**ឆ៖** អត់ក្តាប់បានទេព្រោះអីវាភ្លេចទៅហើយ ។ ប៉ុន្តែដឹងថាចំនួនប៉ុណ្ណឹង មិនដឹងជាអ្នកទោសប៉ុន្មាន អ្នកយាមហ្នឹងប៉ុន្មាននាក់ទេ ព្រោះវាភ្លេច វាច្រើនឆ្នាំមកពេក មិនដឹងជាឈ្មោះណាឈ្មោះណា ។ ហើយមួយទៀតមកនាបច្ចុប្បន្នក៏បែកគ្នារហូតតាំងពីថ្ងៃនោះមកទាល់ថ្ងៃនេះ មិនដែលសូវបានជួបគ្នាទៀតមិនដឹងជាអស់លោកណារស់នៅ អស់លោកណាស្លាប់ទេ ព្រោះបែកគ្នាទៅមកដល់កងចល័តហ្នឹង គឺគេបំបែកគ្នាទៀត ដាក់ទៅតាមកងនានាផ្សេងៗពីគ្នា ។

[០៩:១៨:៥៥]

**ស៖** តើលោកធ្លាប់ឮមន្ទីរម-១៣ "ក" និងមន្ទីរម-១៣ "ខ" ដែរ ឬទេ?

**ឆ៖** ចំណុចត្រង់នេះ គឺយើងខ្ញុំអត់ដែលបានឮទេគ្រាន់តែមន្ទីរ-១៣ ហ្នឹងទើបមកឮក្នុងហ្នឹងទេដែលឮថាម-១៣ ។ កាលនៅហ្នឹងគឺគេហៅ "១៣" ៗ គត់ហ្នឹង គឺអត់ដែលឮមន្ទីរ "ខ" ,"ក" ហ្នឹងគឺអត់ដែលឮទេ ។ ព្រោះនៅរយៈហ្នឹងគឺ មិនបានដើរចេញចូលទៅណាមកណាទេ បើថានៅកន្លែងណាមួយគឺដឹងតែនៅកន្លែងហ្នឹង ។

**ស៖** នៅពេលដែលលោកនៅមន្ទីរម-១៣ តើលោកឮការសន្ទនា ការនិយាយគ្នាណាមួយថាតើមានអ្វីកើតឡើងបន្ទាប់ពីការបែកភ្នំពេញ? ថាតើការវាយបែកភ្នំពេញមានដែលគេពិភាក្សាដែរឬទេ?

**ឆ៖** ចំពោះការវាយបែកភ្នំពេញគឺយើងខ្ញុំអត់ដឹងផង ។ ស្រាប់តែគេប្រកាសថាបែកភ្នំពេញហើយបងប្អូនបានជ័យជម្នះលើ លន់ នល់ លើចក្រពត្តិអាមេរិកហើយ អ៊ីចឹងគឺយើងបានទទួលជ័យជម្នះហើយគឺយើងអត់បានដឹងវែងឆ្ងាយទេ ព្រោះនៅតែក្នុងព្រៃ ។ គឺកន្លែងខ្ញុំធ្វើស្រែចម្ការហ្នឹងគឺនៅក្នុងព្រៃឆ្ងាយពីភូមិណាស់ ។

**ស៖** ថាតើគេប្រកាសយ៉ាងម៉េចអំពីការបែកភ្នំពេញនេះ ចំពោះអ្នកទោសនិងចំពោះលោក ថាតើលោកដឹងថាមានប្រកាសយ៉ាងម៉េចចំពោះការបែកភ្នំពេញហ្នឹង?

**ឆ៖** កន្លែងហ្នឹងគឺខ្ញុំអត់សូវដឹងដែរ គ្រាន់តែប្រកាសថាបែកភ្នំពេញហើយតែប៉ុណ្ណឹង គឺយើងទទួលបានជ័យជម្នះពីលើចក្រពត្តិអាមេរិកហើយ គឺឮសូវតែប៉ុណ្ណឹង ។

**ស៖** តើលោកឮការប្រកាសថា អ្នកទោសទាំងអស់ត្រូវគេដោះលែង? ហើយចំណុចទីពីរ តើលោកបានឃើញមានការដោះលែងអ្នកទោសដែរឬទេ?

**ឆ៖** គឺពេលហ្នឹង គឺអ្នកទោសត្រូវដោះលែងមែន ឃើញចេញទៅបន្តៗបន្ទាប់ ដូចជាជីតារបស់ខ្ញុំអីហ្នឹងក៏ត្រូវគេដោះលែងក្នុងរយៈពេលហ្នឹងដែរ ។ ដូចជីតាខ្ញុំ ដែលខ្ញុំបានលើកកាលពីម្សិលមិញក៏ត្រូវដោះលែងក្នុងថ្ងៃនោះដែរ គឺបានទទួលជ័យជម្នះហ្នឹង អ្នកទោសភាគច្រើនហ្នឹង គឺបានចេញពីក្នុងគុកហ្នឹង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំអស់សំណួរហើយចំពោះសាក្សី ប៉ុន្តែខ្ញុំចង់លើកការតាំងសំណួរមួយចំនួនជូនជនជាប់ចោទ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ។

[០៩:២៣:០០]

**សួរដោយចៅក្រម ហ្សង់ ម៉ាកឡាវែន៖**

**ស៖** ជាបឋមលោកឮការឆ្លើយរបស់លោក ចាន់ ខន កាលពីម្សិលមិញពេលរសៀលហើយនិងព្រឹកនេះ ថាការសង្កេតជាបឋមរបស់លោកចំពោះការផ្តល់សក្ខីកម្មនេះ គឺយ៉ាងម៉េចដែរ?

**ជនជាប់ចោទ៖**

**ឆ៖** ដំបូងខ្ញុំសូមជម្រាបលោកចៅក្រមថា ខ្ញុំនិងមិត្ត ខន បែកគ្នា ៣៦ឆ្នាំមកហើយ ។ ខ្ញុំឃើញមុខកងការពារចាស់របស់ខ្ញុំ ខ្ញុំមានទឹកចិត្តរំជើបរំជួលច្រើន ។ ខ្ញុំនឹកដល់ឪពុកគាត់ បងខុម ធ្លាប់ទៅលេងជាមួយនឹងខ្ញុំ នឹកទៅដល់សេចក្តីមេត្តាករុណារបស់ប្រជាជនបីភូមិនៅជាប់ៗគ្នាហ្នឹង ។ គឺភាគភូមិត្រពាំងត្រោក ភូមិទំនាប និងភូមិថ្មគប់ ។ ប្រជាជនភូមិទាំងអស់នេះឧបត្ថម្ភគាំទ្រផ្ទាល់ខ្លួនខ្ញុំ ឧបត្ថម្ភគាំទ្រមន្ទីរ-១៣ គេការពារគេឲ្យសុខ គេផ្តល់កូនចៅគេមកឲ្យធ្វើកងការពារមន្ទីរ មកម្នាក់មើលទៅគេមិនពេញចិត្តនឹងចង់ធ្វើនៅទីនេះ ខ្ញុំក៏ឲ្យចេញទៅ ហើយគេឲ្យមកម្នាក់ទៀត ។

ចុងបំផុតកម្លាំងកងការពាររបស់ខ្ញុំ មានមួយភាគជាកូនចៅអ្នកត្រពាំងគ្រោក ថ្នគប់ ទំនាប ។ មួយភាគទៀតជាកូនចៅអ្នកភូមិព្រៃជ្រៅ មានតែម្នាក់គត់គឺហួយ មុត មាស មកពីខាងស្ទួល ។ នឹកដល់គុណអ្នកប្រជាជននៅឃុំពាម ។ ជាពិសេស និយាយបច្ចុប្បន្ននេះពេលនេះ តែប្រជាជនបីភូមិនៅទំនាប ថ្នគប់ និងត្រពាំងគ្រោកចុះ ។ ខ្ញុំនឹកដល់ឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើប្រជាជននៅថ្នគប់ម្នាក់គឺខ្មោច ពូសុខ ស្រាប់តែមកដល់ពេលនេះខ្ញុំឮមិត្ត ខន គាត់និយាយថា ជីតាគាត់មកទាំងពីរ ។ ខ្ញុំរកនឹកមិនឃើញដេកគិតមួយយប់ហើយរកនឹកឈ្មោះមិនឃើញទេ ដូច្នេះថ្ងៃក្រោយ ពេលទៅមុខទៀត បន្តិចទៀត បើសិនជាលោកចៅក្រមចង់ឲ្យ មិត្តខន គាត់បញ្ជាក់អ្នកណាខ្លះដែលខ្ញុំ មានប្រព្រឹត្តបាតដៃប្រលាក់ឈាមទៅលើគេអានោះខ្ញុំកាន់តែពេញចិត្ត និងចង់ដឹង ។

តែតទៅទៀតនេះ ខ្ញុំគ្រាន់តែសូមបញ្ជាក់ថា ៣០ឆ្នាំ នេះ ធ្វើឲ្យសក្ខីភាព សក្ខីកម្មរបស់ មិត្តខន ច្របូកច្របល់បន្តិច រវាងបានឃើញ ហើយនិងបានឮ ។ យកអាបានឮធ្វើបានឃើញ ដូច្នេះត្រង់ណាបានឮ ត្រង់ណាបានឃើញអាហ្នឹង ចាំខ្ញុំទុកជូនលោកចៅក្រមបញ្ជាក់ខ្ញុំជាបណ្ដើរៗទៅទៀតចុះ ឈរលើការពិភាក្សាគ្នាដោយស្មើភាពរវាង ខ្ញុំនិងអតីតកងការពារខ្ញុំ មិត្តខន ។ សូមអស់ ។

[០៩:២៦:៥១]

**ស៖** ជាដំបូងលោកបានប្រាប់យើងខ្ញុំថា គឺលោកមានការពេញចិត្តទៅនឹងការជួយដោយអ្នកភូមិដែលមកគាំទ្រមន្ទីរម-១៣ ហើយបានបញ្ជូនក្មេង កូនៗរបស់គាត់មក ។ សំណួររបស់ខ្ញុំជាដំបូង តើលោកគិតថា ឪពុកម្ដាយរបស់ក្មេងៗទាំងអស់នោះ គឺគាត់មានការពេញចិត្តនិងមានឆន្ទៈក្នុងការបញ្ជូនកូនរបស់គាត់មកម-១៣ ដែរ ឬទេ?

**ឆ៖** លោកចៅក្រមជាទីគោរព! ប្រជាជននៅភូមិនេះគេហៅថាភូមិមូលដ្ឋានបង្អែក ដែលគាំទ្របដិវត្តន៍តាំងពីយូរយារណាស់មកហើយ ។ តាំងពីយូរមកហើយ ខ្ញុំមិនដឹងពីកាលច្បាស់លាស់ទេ ។ ខ្ញុំគ្រាន់តែសូមបញ្ជាក់ថា មិនមែនមានតែឪពុក មិត្តខន មួយទេ ដែលគាត់ស្គាល់ខ្ញុំហើយមករាប់អានមកនិយាយលេងជាមួយខ្ញុំនោះ ។ មាន បងហួន ឪពុក មិត្តណាន មានបងអ៊ុយ ឪពុក មិត្តអុន មានច្រើន ។ ហើយប្រជាជននៅម្ដុំហ្នឹងខ្ញុំរាប់អានគាត់ គាត់រាប់អានខ្ញុំ ។ ខ្ញុំរហូតដល់សុំយកចាស់ៗពីរនាក់មកធ្វើជាម្ដាយធម៌ ឪពុកធម៌ ។

សរុបមកនិន្នាការគេជំនាន់នោះ គឺគេគាំទ្របដិវត្តន៍ ។ គេលះបង់កូនចៅមកឲ្យខ្ញុំ ក៏វាសមស្របនឹងបំណងគេដែរ ។ ពីព្រោះខ្ញុំរើសតែយុវជនក្រោម១៨ឆ្នាំ ។ យុវជនលើសពី១៨ឆ្នាំ ខ្ញុំទុកឲ្យសមរភូមិ

ខ្ញុំមិនប៉ានឆាឆៅគេទេ ។

ដូច្នេះ សរុបមួយម៉ាត់តាមទិដ្ឋភាពប្រជាជននៅទីនោះជំនាន់នោះ ខ្ញុំជឿថា គេគាំទ្របដិវត្តន៍ គេលះបង់កូនចៅគេមកឱ្យមន្ទីរ១៣ ដោយស្មោះ ។

**ស៖** ចាតើអ្នកភូមិទាំងអស់នោះ គឺគាត់ឆ្លើយតបទៅនឹងការហៅដែលថា អ្នកមូលដ្ឋានហ្នឹង តើអញ្ចឹងមែនដែរឬទេ?

**ឆ៖** មូលដ្ឋានបង្អែក ឬក៏ប្រជាជននៅមូលដ្ឋាននោះ គឺហ្នឹងហើយ *ពុិប ឌឺបាស (people de base)* ។

**ស៖** នៅក្នុងថ្ងៃនេះ លោកច្បាស់ហើយថា លោកជឿថា ក្មេងៗទាំងអស់នោះ ដែលលះបង់ ឬក៏មកដោយឆន្ទៈរបស់ពួកគេ លោកមិនដែលមានការស្ទាក់ស្ទើរក្នុងការសួរសំណួរណាមួយ ក្នុងការផ្តល់ជម្រើស ដល់ឪពុកម្តាយរបស់ក្មេងៗទាំងអស់នោះ ក្រៅពីសុំឱ្យមានការបញ្ជូនក្មេងៗទាំងអស់នោះមក?

**ឆ៖** ស្តាប់មិនទាន់ប៉ុន្មានពេកទេ សូមលោកចៅក្រមមេត្តាបញ្ជាក់ម្តងទៀត ។

**ស៖** លោកបានប្រាប់យើងខ្ញុំថា លោកជឿ និងមានភាពជឿជាក់ថា ការគាំទ្រ ដែលផ្តល់ជូនដោយអ្នកភូមិ គឺវាកើតឡើងដោយឯកឯង គឺអ្នកភូមិបញ្ជូនកូនចៅដោយឯកឯង ។ សំណួររបស់ខ្ញុំគឺថា តើគ្រួសារទាំងអស់នោះ មានជម្រើសមួយផ្សេងពីហ្នឹងដែរឬទេ ឬក៏ពួកគេមានកាតព្វកិច្ចក្នុងការបញ្ជូនកូនៗរបស់ពួកគេមកមន្ទីរម-១៣ នៅពេលនោះគឺក្មេងៗមានតួនាទីធ្វើជាអ្នកយាម?

**ឆ៖** អាយុតិចជាង១៨ឆ្នាំ មានលទ្ធភាពពីរ ។ ទីមួយ នៅក្នុងឃុំសង្កាត់ហ្នឹងតទៅទៀត ជួយធ្វើការងារជាកងសេនាជន ។ ហើយទីពី មកចូលមន្ទីរ ។ ដូចជាមន្ទីរម-១៣ ខ្ញុំនេះជាដើម ។ សរុបមកជម្រើសរបស់ប្រជាជនអស់នោះ មានពីរនេះឯង មានតែពីរហ្នឹងទេ អត់មានទៀតទេ។

អ្នកដែលមានអាយុចាប់ពី១៨ឆ្នាំឡើងលើ ជាក់ជាការចាំបាច់ហើយទៅទ័ព លើកលែងតែអ្នកជាប់រវល់នឹងមន្ទីររួចទៅហើយ បានៗរួចខ្លួន ។

**ស៖** ចាតើអ្នកភូមិគាត់មកចូលគាំទ្រដោយឯកឯង ក្នុងការផ្តល់កូនចៅរបស់គាត់ឱ្យធ្វើជាអ្នកយាមនៅម-១៣ ឬក៏គេស្នើសុំឱ្យអ្នកភូមិបញ្ជូនកូនចៅរបស់គេមកម-១៣ ។

**ឆ៖** រឿងនេះ ខ្ញុំបានពន្យល់ពីថ្ងៃមុនហើយ ខ្ញុំស៊ើបរកអ្នកណាដែលមានប្រវត្តិរូបល្អគួរជាទីទុកចិត្ត ហើយខ្ញុំស្នើសុំទៅខាងលើ ដល់ខ្ញុំស្នើសុំពីខាងលើ ខាងលើគេចាត់ឈ្មោះមកឱ្យ ហើយឱ្យខាងភូមិបញ្ជូនមកខ្ញុំ ដូចបញ្ជូនមិត្ត ខន អ៊ីចឹងមកជាដើម ។

[០៩:៣៦:២០]

**ស៖** លោកមិនបានឆ្លើយតបនឹងសំណួររបស់ខ្ញុំនោះទេ ។ សំណួររបស់ខ្ញុំគឺ ដូចតទៅនេះ ថាតើគ្រួសារអ្នកភូមិនោះ គឺមានកាតព្វកិច្ចមិនបញ្ជូនមកម-១៣ ហើយគេស្នើសុំឲ្យអ្នកភូមិបញ្ជូនកូនចៅរបស់គេម-១៣ ហើយអ្នកណាគេជាអ្នកស្នើសុំឲ្យបញ្ជូនមក ។

**ឆ៖** ពីគ្រួសារជាក្រៅផ្លូវការទេ ។ ប៉ុន្តែ គេបញ្ជូនមកហ្នឹង ពីខាងលើឲ្យគ្រួសារហ្នឹងបញ្ជូនមក ។

**ស៖** នៅពេលដែលលោកនិយាយថា ថ្នាក់លើ ថាតើគឺជា វន វ៉េត ដែលគាត់ខ្លួនឯងទៅតាមភូមិដើម្បីសុំឲ្យគ្រួសារបញ្ជូនកូនចៅមកម-១៣ ថានរណាគេជាអ្នកធ្វើការងារហ្នឹង?

**ឆ៖** ខ្ញុំមិនដែលបានសុំមនុស្សពីភូមិភាគពិសេសទេ ខ្ញុំសុំពីភូមិភាគនិរតី។ ចំពោះភូមិភាគនិរតីនេះខ្ញុំទៅបងស៊ី ឈ្មោះដើម ជូ ជេត អនុលេខាភូមិភាគនិរតី ។ ហើយគេបញ្ជូនតាមផ្លូវការឈ្មោះដែលខ្ញុំសុំហ្នឹងតាម បងប៉ាល់ ចុះមកដល់បងសយ លេខាស្រុកថ្ពង ។ ខ្ញុំសូមបញ្ជាក់ម្តងទៀត បងស៊ី គាត់បញ្ជាមកបងប៉ាល់ លេខាតំបន់៣២ ហើយបងប៉ាល់ ក៏បញ្ជូនឈ្មោះហ្នឹងមក បងសយ លេខាស្រុកថ្ពង ហើយបានលេខាស្រុកថ្ពងនោះ គេបញ្ជូនឈ្មោះមកឃុំអមលាំង ។ ដូច្នេះ មានការទាក់ទងក្រៅផ្លូវការរវាងខ្ញុំ ហើយនិងបុគ្គលិកខ្ញុំចាស់ទៅម៉ែឪ ។ ដូច្នេះ មានការការទាក់ទងក្រៅផ្លូវការពីខ្ញុំ តាមរយៈបុគ្គលិកចាស់របស់ខ្ញុំ ទៅម៉ែឪបុគ្គលិកដែលចង់ជ្រើសរើស ។

[០៩:៣៩:៥៨]

**ស៖** ដូច្នេះ គឺមានការស្នើសុំ ហើយគឺមានការស្នើសុំទៅដល់ឪពុកម្តាយការពិតទៅ ។ ថាតើលោកមានសួរខ្លួនឯងទេ ថាឪពុកម្តាយនឹងបដិសេធសំណើរនេះ ប្រសិនបើឪពុកម្តាយមានជម្រើសជ្រើសរើសយកចំណុចផ្សេង?

**ឆ៖** បញ្ហានេះខ្ញុំអត់មានឲ្យខាងលើនោះសួរទេៗ។ ក៏ប៉ុន្តែ ខ្ញុំឲ្យអ្នកខាងក្រោមហ្នឹងសួរ ។ ក៏ប៉ុន្តែអ្នកខ្លះជូនអីកូនមកពីរ ប៉ុនដល់ក្រោយមកកូននោះមិនពេញចិត្តគេទៅវិញ គាត់សុំត្រឡប់ទៅវិញ ខ្ញុំឲ្យទៅឧទាហារណ៍ ដូច បងហួន អ៊ីចឹង គាត់ឲ្យកូនមកពីរ មិត្តណាន មិត្តណែន មួយ ហើយដល់ក្រោយមក ណែន គាត់មិនចង់នៅជាមួយនឹងខ្ញុំ គាត់ទៅវិញ ។ ខ្ញុំជូនទៅខាងឃុំវិញ ។ ដូច្នេះ គេជ្រើសរើសអ៊ីចឹងទៀត វាទៅអីចឹង ។

សរុបមក ការសួរចិត្ត គឺសួរតាមរយៈបុគ្គលិកចាស់របស់ខ្ញុំ ។ សរុបមក នៅភូមិត្រពាំងគ្រោប មានមនុស្សត្រឡប់ទៅផ្ទះវិញច្រើនដែរ មិនណៃម មិត្តហ៊ិន ហើយមានអ្នកនៅជាមួយនឹងខ្ញុំក៏ច្រើនដែរ ដូចជា មិត្តណាន មិត្តអុន ហើយ មិត្តសើ ហើយនិរសារដែលខ្ញុំស្រលាញ់បំផុតនោះ គឺមិត្តឆេន គាត់អ្នកត្រពាំងគ្រោបហ្នឹងដែរ ។ សរុបមក សភាពការណ៍វា វាដំណើរការអ៊ីចឹង។ ការស្ម័គ្រចិត្ត ដូច្នេះ ការស្ម័គ្រចិត្ត និងមិនស្ម័គ្រចិត្តវានៅការ គេគិតថ្លឹងថ្លែងរបស់គេស្រួលបួលដែរ ហើយនិងគិតទៅលើសេរីភាពរបស់កុមារហ្នឹង ក្មេងជំទង់ហ្នឹងផង ។

**ស៖** ដូច្នេះហើយ លោកបានបញ្ជូនក្មេងៗត្រឡប់ទៅវិញមួយចំនួន ហើយចំពោះក្មេងៗដែលនៅធ្វើការនៅទីនោះ ថាពួកគេអត់មានធ្វើការតវ៉ា ឬក៏យ៉ាងម៉េចនោះទេ? ថាតើពួកគេពេញចិត្តនឹងការងារដែលពួកគេបំពេញនោះដែរឬទេ? ថាតើក្រុមក្មេងណាខ្លះ ដែលគាត់នៅម-១៣?

**ឆ៖** អ្នកដែលគេត្រឡប់ទៅវិញ គេសុំទៅ។ ដូច្នេះ អាចគេមិនពេញចិត្តនឹងការងារនេះ គេទៅ ដូចជា ខ្ញុំបានរាប់ឈ្មោះអំមិញអ៊ីចឹងប៉ុន្មានពីរ-បីនាក់ ហើយអ្នកដែលនៅនេះ គឺគេអ្នកចង់នៅតែម្តង ដូចមិត្តអុន ដូចខ្មោច មិតឆេន នីរសារខ្ញុំដែលខ្ញុំស្រលាញ់បំផុតនោះ គាត់ចង់នៅ ។

**ស៖** អ្នកដែលចូលមកម-១៣ ហើយមានអ្នកត្រឡប់ទៅវិញច្រើន។ អ្នកដែលទៅប្រហែលជាគេមិនពេញចិត្តនឹងការងារហ្នឹង។ ខ្ញុំនិយាយតែនៅខាងភូមិត្រពាំងគ្រោបចុះ មិត្តហ៊ិន គាត់ត្រឡប់ទៅវិញ ។ មិត្តណៃម ប្អូនមិត្តណាន ក៏ត្រឡប់ទៅវិញ ហើយអ្នកដែលនៅក៏មានច្រើនដែរ នៅខាងភូមិត្រពាំងគ្រោបនេះ ។ ទីមួយ អ្នកដែលគេនៅ ខ្ញុំមើលទៅដូចគេពេញចិត្តនឹងការងារ ។ ទីពីរ ដូចគេពេញចិត្តនឹងផ្ទាល់ខ្លួនខ្ញុំ ។

**ស៖** ថាតើពួកគេពេញចិត្តនឹងការងារនោះយ៉ាងម៉េច?

**ឆ៖** ធម្មតាការងារនៅនោះ ដូច មិត្តខន គាត់រាយការណ៍ជូនអង្គប្រជុំហើយ ។ បើកភ្នែកឡើងយាម ឃើញតែអ្នកទោស ឃើញតែជាប់ខ្នោះ ក៏ប៉ុន្តែវាមិនបានទៅមុខ ។ ក៏ប៉ុន្តែវាមិនបានទៅច្បាំងនៅសមរភូមិមុខ ហើយគេមានឈ្មោះថាអ្នកនៅក្នុងជួរ មិនដូចជាយុវជនតាមភូមិដែលហៅថា យុវជនភូមិ។

**ស៖** ប្រសិនបើខ្ញុំយល់អ្វីដែលលោកឆ្លើយ ក្មេងៗទាំងអស់នោះ គឺគាត់ពេញចិត្តនឹងធ្វើការនៅម-១៣ ពីព្រោះតែពួកគាត់មិនទៅច្បាំង ។ ហើយលោកបាននិយាយផងដែរថា អ្នកដែលទៅវៃនោះ គឺច្រើនតែអាយុលើសពី១៨ឆ្នាំ ហើយក្មេងៗនោះក៏ពេញចិត្តផងដែរ ដោយសារពួកគាត់គឺជាអ្នកដើរតាមមាគ៌ារបស់បក្ស តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកចៅក្រមថា ការបកប្រែជាភាសាបារាំងហ្នឹង មិនត្រូវទេ ។ ជួរបក្សបដិវត្តន៍បារាំងគេថា *ឡឺវ៉េងវ៉ឺហ្សន* ។

**ស៖** លោកបានចាំថា លោកបានលើកឡើងដោយខ្លួនឯងអំពីការធ្វើការនៅម-១៣ ថាលោកបាន ឬក៏មិនបាននិយាយថា បានពិភាក្សាអំពី ការធ្វើការងារនៅម-១៣ គឺលោកបាននិយាយថា លោកបានពិភាក្សាអ្វី ដែលលោកបានធ្វើការនៅម-១៣ ដែរឬទេ?

**ឆ៖** បញ្ហាមានពីរ ខ្ញុំមនុស្សចាស់បន្តិចដែរទៅហើយៗ ឯចំណែកគេ គេនៅក្មេង ។ ដែលយើងខ្ញុំធ្លាប់ហៅថា ក្មេងជំទង់ ហើយវណ្ណភាពគេជាវណ្ណភាពកសិករក្រីក្រ ។ យើងអប់រំ មាគ៌ាវណ្ណៈអំពីបញ្ហាដាច់ខាតចំពោះខ្មាំង គេឆាប់ទទួល គេឆាប់ទទួល គេឆាប់ធ្វើបាន។ អ្នកដែលនៅជាមួយនឹងខ្ញុំ គេនៅតទៅទៀត ភាគច្រើនគឺសុទ្ធតែជាមនុស្សប្រភេទនេះ ដូចខ្មោច មិត្តមាស លឿនណាស់ គាត់ខំធ្វើការងារលឿនណាស់។ ឯចំណែកអ្នកដែលគេត្រឡប់ក៏មានច្រើនដែរ ដូចយ៉ាងមិត្ត ខន ខ្ញុំនេះ ដូចយ៉ាងមិត្ត ណែម ដូចយ៉ាងមិត្ត ហិន ។ ដូច្នេះ ក្មេងជំទង់ ហើយនិងខ្ញុំមនុស្សពេញវ័យ ខុសគ្នា ។

[០៩:៥១:៤៥]

**ស៖** ឌុច, ខ្ញុំនឹងអានសម្រង់នៃការសួរចម្លើយនៅក្នុង ឌេ-២១ ទំព័រទី១២ ។ នៅក្នុងតំបន់២៥ លោកបាននិយាយថា ខ្ញុំមិនពេញចិត្តនឹងការធ្វើការងារសន្តិសុខ ហើយយើងហៅថា វាជាផ្នែកអង្គភាពពិសេស ហើយខ្ញុំមិនចិត្តនឹងការ-- ខ្ញុំស្អប់នឹងការសម្លាប់ ។ ប៉ុន្តែ អ្វីដែលខ្ញុំប្រាប់នោះ គឺជាបង្គាប់របស់បក្សនៅក្នុងមន្ទីរ១៣ គឺខ្ញុំស្អប់ដូចអាចម៍ ប៉ុន្តែខ្ញុំត្រូវតែដើរជាន់នៅលើអាចម៍នេះ ។ តើលោកបាននិយាយអ៊ីចឹងដែរឬទេ ឬក៏វាជាអ្វីដែលការសរសេរនៅទីនេះ? ដោយសារនេះជាកំណត់សម្គាល់ដែលបានបន្ថែមនៅក្នុងចម្លើយការសួរយកចម្លើយលោក គឺជាមនុស្សមួយដែលបាននិយាយនៅក្នុងហ្នឹង ។ ដូច្នេះហើយ ប្រសិនបើលោកស្អប់ការងារដែលធ្វើនៅម-១៣ ថាតើលោកគិតថាក្មេងជំទង់មួយចំនួន គឺគាត់ពេញចិត្តនឹងធ្វើការងារនៅម-១៣ នោះយ៉ាងម៉េច ប្រសិនបើលោកស្អប់ហើយនោះ?

**ឆ៖** សេចក្តីដែលលោកចៅក្រមអានអម្បាញ់មិញនេះ ខ្ញុំជឿជាក់ថាជាសេចក្តីបញ្ជាក់របស់ខ្ញុំមែនហើយ ។ ក៏ប៉ុន្តែ ខ្ញុំចង់លើកឡើងអំពីការដែលខ្ញុំនិយាយគ្នាជាមួយបង ឆាយ គឹមហ៊ ហៅ ហុក នៅពេលដែលគេប្រគល់ភារកិច្ចមកឲ្យខ្ញុំធ្វើប្រធានមន្ទីរ១៣ ។ គេថាអាការងារហ្នឹងវាចាំបាច់ ត្រូវតែមិត្តធ្វើ សមមិត្តជាកុលបុត្ររបស់បក្ស ឥឡូវបក្សអំពាវនាវហៅមិត្ត មិត្តត្រូវតែទទួលភារកិច្ចហ្នឹង ។

**ស៖** ខ្ញុំមិនបានសួរលោក ថាតើលោកគិតខ្លួនឯងយ៉ាងម៉េចអំពីបញ្ហាហ្នឹង ថាតើលោកប្រមើលឃើញការប្រតិកម្មរបស់ក្មេងជំទង់ៗនេះយ៉ាងម៉េច? លោកបានឮពីសាក្សីហើយថា គឺឃើញតារបស់គាត់ពីរនាក់ត្រូវបានឃុំនៅម-១៣ ហើយសាក្សីក៏បានពន្យល់ជូនយើងទាំងអស់គ្នាថា គាត់ចាកចេញពីម-១៣ ដោយសារតែលោកជាអ្នកចេញបញ្ជាឲ្យចេញ ។ ហើយគាត់គឺបាននិយាយ ។ ដូច្នេះ តើលោកអាចប្រមើលមើលយ៉ាងម៉េច? ថាសាក្សី គឺគាត់ពេញចិត្តក្នុងនាមជាអ្នកយាមនៅម-១៣ តើលោកប្រមើលឃើញយ៉ាងម៉េចទៅលើបញ្ហាហ្នឹង?

**ឆ៖** ខ្ញុំសូមជម្រាបបញ្ជាក់ថា មិនទាន់យល់សំណួររបស់លោកចៅក្រម ច្បាស់លាស់នៅឡើយទេ ។

**ចៅក្រមឡា ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា ខ្ញុំសួរសំណួរខ្ញុំមិនសួរសំណួរអ្វីថែមទៀតទេ ជូនជនជាប់ចោទនោះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់សុំជូនវេទិកានេះទៅសហព្រះរាជអាជ្ញា បើមានសំណួរត្រូវសួរដល់សាក្សីរូបនេះ ។ ប្រសិន បើមានសូមអញ្ជើញសហព្រះរាជអាជ្ញា ។

[០៩:៥៦:៣០]

**សួរដោយលោក យ៉េត ចរិយា៖**

**ស៖** អរគុណតុលាការ។ ខ្ញុំសូមសួរទៅសាក្សីឈ្មោះ ចាន់ ខន ។ ចាន់ ខន តាមចម្លើយរបស់លោកឆ្លើយបញ្ជាក់ចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថាអ្នកទោសមានច្រើនប្រភេទ ដូចជា ទាហានខ្មែរក្រហម ទាហាន លន់ នល់ ជនស៊ីវិល ប្រពន្ធ ស្ត្រី និងទារក ។ តែពេលលោកឆ្លើយម្សិលមិញចំពោះចៅក្រម លោកបានបញ្ជាក់ថា គ្មានទារកទេ ។ តើចម្លើយណាជាចម្លើយពិតប្រាកដ?

**សាក្សី KW-32៖**

**ឆ៖** ខ្ញុំជម្រាបជូនទៅអស់លោកវិញ គឺបញ្ហានេះគឺឆ្លើយភ្លេច ។ ខាងដើមមកគឺខ្ញុំបានឆ្លើយថាអ្នកទោស មានគ្រប់ប្រភេទមែនពិត គឺអ្នកទោសទាហាន លន់ នល់ ក៏មាន អ្នកទោសខ្មែរក្រហមដែលជាទាហានក៏មាន ជនស៊ីវិលក៏មាន ដែលគេចោទថា គិញ ជនក្បត់សីលធម៌ ខុសវិន័យផ្សេងៗ ជាពិសេស

ដែលខ្ញុំ ឆ្លើយម្សិលមិញខ្វះនេះ គឺការគិតរបស់ខ្ញុំមិនទាន់ ។ អ៊ីចឹង គឺស្ត្រីក៏មាន ស្រីសុទ្ធក៏មាន ទារកហ្នឹង គឺប្រពន្ធទាហានគឺមានផ្ទៃពោះនៅក្នុងខ្លួន នឹងសូមជម្រាបទៅអស់លោក ។

**ស៖** អ៊ីចឹង ទារកហ្នឹង គឺនៅក្នុងផ្ទៃម្តាយ?

**ឆ៖** បាទ ។

**ស៖** ម៉េចបានលោកដឹង?

**ឆ៖** ចុះបើយកមកឃើញពោះធំ ។

**ស៖** សូមបញ្ជាក់ម្តងទៀតមើល តើលោកនឹង ចាន់ វឿន អ្នកណាចូលធ្វើការមុននៅម-១៣?

**ឆ៖** ទេ, កាលហ្នឹងមិនដឹងជាខ្ញុំចូលមុន មិនដឹងជាខ្ញុំចូលក្រោយទេ ។ តែចំពោះរូបខ្ញុំ គឺខ្ញុំដឹងតែខ្លួនខ្ញុំចូលទៅក្នុងមន្ទីរ១៣ គឺនៅក្នុងឆ្នាំ១៩៧៣ ជំនាន់ដែលកប៉ាល់ហោះទម្លាក់ខ្លាំងហ្នឹង គឺគេយកខ្ញុំទៅហ្នឹង ។ ចំពោះ ចាន់ វឿន ហ្នឹងគឺមិនដឹងជាចូលមុនខ្ញុំ មិនដឹងជាក្រោយទេ ខ្ញុំវាភ្លេច វាវែងឆ្នាំពេកអស់លោក ដែលខ្ញុំតាមដានក្តាប់វាមិនសូវបានអស់ ។

**ស៖** អ៊ីចឹង លោកកំណត់ថា ចាន់ វឿន ពិតជាបុគ្គលិក ម-១៣ ហើយ?

**ឆ៖** ចំពោះ ចាន់ វឿន គឺជាបុគ្គលិកមន្ទីរ១៣ ពិត ហើយ ចាន់ វឿន នេះបានទទួលការឃុំឃាំងពីតាឌុច ផ្ទាល់ទៀត ។ ពិសេសគឺពេលដែល ចាន់ វឿន យាមអ្នកទោសរត់រួច អ្នកទោសនោះគឺមានដាក់ច្រវាក់ក ។ ហើយអ៊ីចឹងគឺ ចាន់ វឿន ឲ្យអ្នកទោសរត់មិនដឹង ឬមួយក៏អ្នកទោសលួចកាត់ច្រវាក់ខ្លួនឯងមិនដឹង ។ អ៊ីចឹងហើយគឺអ្នកទោសទាំងនោះត្រូវរត់រួច ។ អ៊ីចឹងហើយតា ឌុច ហ្នឹង គឺត្រូវដាក់វិន័យ ចាន់ វឿន ហ្នឹងនៅក្នុងមន្ទីរឃុំឃាំង ។ អ៊ីចឹងដល់ពេលយប់ស្ងាត់ តួនាទីខ្ញុំជាអ្នកយាមក្នុងហ្នឹង ខ្ញុំថា អាវឿន អ្អែងរត់ចេញ បើអត់រត់អ្អែងងាប់ហើយណានៅហ្នឹង ។ អ៊ីចឹងឈ្មោះ វឿន ហ្នឹងក៏រត់បាត់ទៅ ។ ដល់ពេលនេះ តាឌុច គាត់សួរខ្ញុំថា វឿន ទៅណា? ខ្ញុំថា ទេមិនដឹងទៅឯណាទេ ព្រោះខ្ញុំអាល័យតែបត់ជើងស្រាប់មកវិញបាត់មនុស្សបាត់ ។

[០៩:០០:៤៤]

**ស៖** ខ្ញុំសូមសួរសំណួរមួយទៀត។ អម្បាញ់មិញលោកបញ្ជាក់ថា លោកឈប់ធ្វើការនៅម-១៣ ដោយលោកទ្រាំនឹងបញ្ហា និងផែនការរបស់ ឌុច មិនបាន ។ តើបញ្ហានិងផែនការនោះជាអ្វី?

**ឆ៖** អ៊ីចឹងគឺខ្ញុំសូមបញ្ជាក់ជូន គឺផែនការនេះវាច្រើនពេក។ ដូចខ្ញុំបានរៀបរាប់ខ្លះមកមុនហើយ ច្បាស់មិនច្បាស់គឺក៏ខ្ញុំបានជម្រាបជូនខ្លះហើយ គឺបើកភ្នែកមកឃើញបងប្អូនជនរងគ្រោះជាប់ខ្នោះរញ៉ី

រញ៉ុក មិនត្រឹមគេ អ្នកដទៃ ឈានចូលដល់សាច់ញាតិសារលោហិតរបស់ខ្លួន ។ អ៊ីចឹងគឺឲ្យខ្ញុំរស់នៅក្នុងសង្គមុន្ទុំងបានឲ្យឃើញអ៊ីចឹងកើតតទៅមុខទៀតបាន ។ គឺអ៊ីចឹងគឺខ្ញុំទ្រាំទ្រការបញ្ជា ការក្តាប់តាម តាឌុច គាត់បញ្ជាតទៅមុខទៀតគឺមិនកើតទេ ។ អ៊ីចឹងហើយគឺខ្ញុំត្រូវតែរកវិធីសេរីខ្លះ ដើរណេះដើរណោះខ្លះទៅ ទើបគាត់ដកខ្ញុំចេញពីអង្គភាពហ្នឹងទៅធ្វើស្រែហ្នឹង ។

**ស៖** ខ្ញុំសូមសួរសំណួរមួយទៀត ក្រៅពីយាមកាម តើ ឌុច មានឲ្យលោកធ្វើអ្វីទៀតទេ?

**ឆ៖** ក្រៅពីការយាមកាមហ្នឹង បើយើងអត់មានពេលការយាមកាម គឺយើងកាប់ចម្ការ ធ្វើស្រែ គាស់ដីដាំដំឡូង បើមានភារកិច្ចយាមអ្នកទោស គឺយើងត្រូវយាម។ បើអត់ទេ យើងគាស់ដីដាំដំឡូងសម្រាប់ហូប ។

**ស៖** មានដែលឲ្យកប់ខ្មោចទេ?

**ឆ៖** ចំពោះរូបខ្ញុំមិនដែលទេ ដែលតែជូនអ្នកទោសឲ្យទៅកប់ ។ បើចំពោះរូបខ្ញុំយកដៃទៅកាប់ជារណ្តៅអី គឺអត់ដែរសោះ ។

**ស៖** ពេលជូនអ្នកទោសទៅកប់ខ្មោចនោះ ឃើញខ្មោចច្រើនទេ?

**ឆ៖** ខ្មោចដែលស្លាប់នៅក្នុងគុកហ្នឹង ត្រូវបញ្ជូនទៅកប់នៅព្រៃហ្នឹង យើងជាកងការពារហ្នឹងគឺត្រូវតែជូនទៅ ។ ដល់ពេលទៅដល់ហ្នឹង គឺឲ្យអ្នកទោសហ្នឹងកាប់រណ្តៅកប់ខ្លួនគ្នាវាហ្នឹងទៅ គ្នាគាត់ហ្នឹងទៅ ។

**ស៖** (ឮមិនច្បាស់) ទៅលោកជនជាប់ចោទ ។

[១០:០៣:៣៣]

**ប្រធានអង្គជំនុំ៖**

តុលាការអនុញ្ញាត សូមអញ្ជើញលោកសហព្រះរាជអាជ្ញា ហើយជនជាប់ចោទត្រៀមស្តាប់នូវសំណួរដើម្បីបានយល់ ហើយនងឆ្លើយចំសំណួរ ។

**សួរដោយលោក យ៉េត ចរិយា៖**

**ស៖** ជនជាប់ចោទ អម្បាញ់មិញលោកបានបញ្ជាក់ថា ការជ្រើសរើសបុគ្គលិកមកធ្វើការយាមកាមនៅ ម-១៣ គឺសំដៅទៅលើជនដែលមានប្រវត្តិរូបល្អ ។ តើជនមានប្រវត្តិរូបល្អភ្ជាប់នឹងលក្ខខណ្ឌអ្វីខ្លះ ទើបកំណត់ថាជននោះមានប្រវត្តិរូបល្អ?

**ជនជាប់ចោទ៖**

**ឆ៖** ខ្ញុំជ្រើសរើសរកវណ្ណៈភាព អ្នកណាជាកសិករក្រីក្រ និងកសិករកណ្តាលថ្នាក់ក្រោម ។ ទីពីរ គឺកន្លែងភូមិទំនាបនេះមួយ ភូមិថ្មគប់នេះពីរ ភូមិត្រពាំងត្រោកនេះបី ជាភូមិបង្អែកមូលដ្ឋានចាស់ ។ ដូច្នេះ វាមិនសូមប្រឡូកប្រឡាក់ជាមួយនឹងសង្គមចាស់ទេ ។ លក្ខខណ្ឌពីរនេះហើយដែលយើងខ្ញុំជ្រើសរើស ។

**ស៖** មានភ្ជាប់ទៅលើការចេះដឹងដែរឬទេ?

**ឆ៖** សូមទោស រឿងការចេះដឹងខាងអក្សរ (ស្តាប់មិនបាន) អត់មានភ្ជាប់ទេ ។

**ស៖** តើនេះជាការសម្រេចរបស់រូបលោកផ្ទាល់ ឬជាការសម្រេចរបស់ថ្នាក់ដឹកនាំរបស់លោក?

**ឆ៖** នេះជាការអនុវត្តមាគ៌ាវណ្ណៈ ដែលខ្ញុំជាអ្នកធ្វើក្នុងក្របខ័ណ្ឌមន្ទីរ១៣ ឯចំណែកខាងលើមានកន្លែងខ្លះគេត្រូវការចំណេះដឹងខាងវប្បធម៌ជាការចាំបាច់ ។ ឧទាហរណ៍ កន្លែងខាងសរសេរកាសែតអី គេត្រូវការចំណេះខាងវប្បធម៌ ។

**ស៖** អស់ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ បើមានសំណួរសូមអញ្ជើញ ។

[១០:០៥:៥០]

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោក ចាន់ ខន ពីម្សិលមិញ លោកបានប្រាប់តុលាការថា ឌុច មានអត្តចរិតរឹងមាំ ហើយម៉ឺងម៉ាត់ដាច់ខាត ។ តើលោកៗបានឃើញគាត់ធ្វើអ្វីខ្លះ ឬក៏បានឮគាត់និយាយដែលលោកដឹងថា គាត់មានអត្តចរិតដាច់ខាតម៉ឺងម៉ាត់នោះ?

**សាក្សី KW-32៖**

**ឆ៖** ចំពោះដែលយើងខ្ញុំបានលើកថា តាឌុច អត្តចរិតម៉ឺងម៉ាត់ ដាច់ខាតនឹងការងារ គឺគាត់និយាយម៉ាត់ណា គឺម៉ាត់ហ្នឹង ។ ចំពោះថ្នាក់ក្រោមដែលអនុវត្តមិនបាន គឺត្រូវការភ័យខ្លួន ត្រូវការខ្លាចអីចឹងតែម្តង ។ ចំពោះដូចជារូបខ្ញុំអីជាដើមហ្នឹង អនុវត្តការងារជាមួយគាត់មិនបាន គឺត្រូវការភ័យហើយខ្លាច មិនហ៊ានមើលគាត់ទេ នៅជំនាន់នោះ គឺខ្លាចគាត់ណាស់ ។ គាត់និយាយម៉ាត់ណាគឺម៉ាត់ហ្នឹង មិនមែននិយាយឡេះឡោះលេងទេ ហើយអត្តចរិតរបស់គាត់ ទៅទីណាក៏គាត់អមដំណើរដោយអាវុធខ្លីគាត់ជាប់ ហើយគាត់ចូលចិត្តសើចឮណាស់ ។ អីចឹងគឺរូបខ្ញុំផ្ទាល់គឺខ្លាច និយាយពីខ្លាចគាត់គឺខ្លាចខ្លាំងមែនទែន មិនហ៊ានមើលមុខទេ ។

**ស៖** លោកបានរៀបរាប់ថា គាត់មានអាវុធខ្លីទៅមួយខ្លួន ។ គាត់កាន់នឹងដៃ ឬក៏គាត់ដាក់នឹងចង្កេះ តើលោកបានឃើញគាត់ដាក់ហ្នឹងរបៀបម៉េច អាវុធខ្លីនោះ?

**ឆ៖** ចំពោះអាវុធខ្លីរបស់គាត់ហ្នឹងគឺជាអចិន្ត្រៃយ៍របស់គាត់ ។ ជួនកាលនៅចង្កេះអ៊ីចឹងទៅ ជួនកាលនៅនឹងក្លៀកអ៊ីចឹងមក ។ គឺអត់ដែលបោះបង់ចោលទេ តាំងដែលខ្ញុំរស់នៅជាមួយ ដែលខ្ញុំឃើញ ។

**ស៖** តើលោកធ្លាប់ឃើញគាត់ទៅយកអាវុធខ្លីពីចង្កេះមកកាន់នៅនឹងដៃដែរឬទេ?

**ឆ៖** ធ្លាប់ឃើញគាត់ដោះតែពីចង្កេះមកដាក់នៅលើតុគាត់ធ្វើការ គឺធ្លាប់ឃើញ ។

**ស៖** នៅក្នុងកាលៈទេសៈពេលណាដែលគាត់យកអាវុធពីចង្កេះមកដាក់លើតុ ហើយគាត់ធ្វើអីនៅកន្លែងតុហ្នឹង លោក ឌុច តា ឌុច នោះ?

**ឆ៖** គឺតុកន្លែងគាត់ធ្វើការ ឬមួយគាត់ទៅផ្ទះបាយអ៊ីចឹងទៅ។ ឃើញគាត់ហូតដាក់លើតុ ហើយគាត់អង្គុយហូបបាយអ៊ីចឹង ។

**ស៖** តើលោកធ្លាប់ឃើញគាត់ដាក់អាវុធខ្លីនៅលើតុនៅពេលដែលគាត់សួរអ្នកទោសដែរឬទេ?

**ឆ៖** ចំពោះបញ្ហាហ្នឹង គឺខ្ញុំមិនសូវដែលឃើញទេ ព្រោះអីកន្លែងសួរចម្លើយគឺយើងមិនអាចឈានទៅចូលទៅទេ លុះត្រាមានការបទបញ្ជាពីគាត់ អាហ្នឹងបានប៉ាន ។

[១០:០៩:៤២]

**ស៖** ចំណុចទីពីរដែលលោកបានប្រាប់តុលាការកាលពីម្សិលមិញនោះ គឺថា ឌុច គឺជាអ្នកដែលធ្វើការងារម៉ឺងម៉ាត់ តើលោកអាចបញ្ជាក់ច្បាស់ថាបានឃើញគាត់ធ្វើអ្វីខ្លះហើយ ឬក៏គាត់និយាយដូចម្តេចដែលថាគាត់ជាមនុស្សអ្នកម៉ឺងម៉ាត់នឹងការងារណាស់នោះ?

**ឆ៖** ព្រោះបានយើងខ្ញុំសន្និតថាគាត់ធ្វើការម៉ឺងម៉ាត់ ជាអ្នកការងារម៉ឺងម៉ាត់ គឺគាត់និយាយអ្វីពីការងារដឹកនាំហ្នឹង គឺច្បាស់ណាស់ និយាយពីច្បាស់រកកន្លែងធៀបប្រៀបមិនបានទេ គឺម៉ាត់ណា គឺស្អីក៏គាត់អនុវត្តតាមផែនការរបស់បក្សរបស់គាត់ហ្នឹងគឺម៉ាត់ៗអ៊ីចឹងតែម្តង ។ អ៊ីចឹងហើយ បានជាខ្ញុំថាគាត់ម៉ឺងម៉ាត់ ហើយក៏គាត់មិនដែលលេងសើចអារាត់អារាយទៀត ។

**ស៖** ខ្ញុំសួរម្តងទៀតអំពីរឿងការសួរចម្លើយអ្នកទោស តើការសួរចម្លើយនោះ ធ្លាប់បានធ្វើនៅកន្លែងដែលចំហ ដែលគេគ្រប់គ្នាអាចមើលឃើញទេ? ឬក៏នៅទីកន្លែងទីវាលណាមួយដែលគេមើលឃើញច្បាស់បានទេ?

**ឆ៖** ព្រោះបញ្ហាកន្លែងដែលសួរចម្លើយគឺ តា ឌុច គាត់បានធ្វើរោងឆ្ងាយពីកន្លែងប្រជុំជនក្នុងគុកហ្នឹង គឺនៅខាងជើងត្រពាំងច្រាបឯណោះ គឺនៅក្រោមដើមស្វាយមួយ ហើយក្នុងកន្លែងនុ៎ងមានតែតុរបស់គាត់មួយ ហើយនិងអង្រឹងគាត់មួយទេ ហើយនិងកៅអីអ៊ីចឹងមួយ ។ ចំណែងរី អ្នកទោសហ្នឹងគឺនៅនឹងដីទេ ។ ហ្នឹងគឺកន្លែងដែលគាត់សួរចម្លើយ ។

**សៈ** តើលោកអាចឮអ្វីដែលគេសួរចម្លើយ ហើយនិងឆ្លើយដែល ឌុច និយាយ ឬក៏អ្នកទោសឆ្លើយនោះបានទេ បើនៅចម្ងាយប៉ុណ្ណឹងនោះ?

**ឆ៖** ចំពោះបញ្ហាហ្នឹង គឺយើងខ្ញុំគឺអត់ដឹងទេ ពីរឿងបញ្ហាសួរចម្លើយអី ។ បានថា ខ្ញុំមិនដឹង គឺនៅឆ្ងាយ ។ ដូចខ្ញុំជម្រាបជូនអ៊ីចឹង គឺឯជើងត្រពាំងច្រាបទៀត ដូចថាអាហ្នឹងត្រពាំងច្រាប វាហួសប្រហែលជាបី-បួន-ប្រាំរយម៉ែត្រ ពីកន្លែងដែលឃុំខ្លួនអ្នកទោសហ្នឹង ។

**សៈ** តើលោកធ្លាប់ឮសម្រែក ឬក៏សម្រែកយំចេញពីកន្លែងសួរចម្លើយហ្នឹងដែរឬទេ?

**ឆ៖** ចំពោះបញ្ហាកន្លែងសួរចម្លើយគឺមិនដែលស្រែកទេ តែគ្រាន់ថា ពេលដែលសួរចម្លើយហើយ បញ្ជូនអ្នកទោសមកវិញ ឃើញអ្នកទោសហ្នឹងគឺឈាមប្រឡាក់ពេញខ្លួន ដោយត្រូវនឹងរំពាត់ឫស្សីឬមួយផ្ដៅដែលគេសំពងសួរចម្លើយ ។

[១០:១៣:១៦]

**សៈ** ពីម្សិលមិញលោកបានបញ្ជាក់ថា ឌុច បាននិយាយទៅលោកក្នុងអង្គប្រជុំមួយឲ្យរក្សាការងារនៅម-១៣ ជាសម្ងាត់នៅម-១៣ ។ តើលោកអាចបញ្ជាក់ថា តើ ឌុច បានប្រាប់លោកនៅក្នុងប្រជុំថា ឲ្យរក្សាការសម្ងាត់ពីរឿងម-១៣ ហ្នឹង មែនឬទេ?

**ឆ៖** ចំពោះបញ្ហាហ្នឹងគឺតា ឌុច គាត់ផ្ទាល់ហ្នឹងគឺបានបញ្ជាឲ្យកងការពារទាំងអស់ ឬមួយក៏ក្នុងជួរថ្នាក់ដឹកនាំរបស់គាត់ គឺត្រូវតែរក្សាការសម្ងាត់ ។ មិនអាចមិត្តណាមួយនិយាយចេញទៅណាបានទេ ព្រោះកន្លែងនេះគឺកន្លែងសំខាន់ គឺគាត់និយាយអ៊ីចឹង ។

**សៈ** ហើយលោកផ្ទាល់បានចូលរួមនៅក្នុងអង្គប្រជុំដែល ឌុច បាននិយាយអំពីរឿងហ្នឹង?

**ឆ៖** បាទ, ពេលដែលនេះហ្នឹង គឺតា ឌុច គាត់ហៅកងការពារទាំងអស់ប្រជុំ ។

**សៈ** សូមប្រាប់យើងបន្ថែមទៀតអំពីការប្រជុំនោះ ជាចំណុច តើអ្នកណាខ្លះជាអ្នកចូលរួមអង្គប្រជុំនោះ តើមានមនុស្សប៉ុន្មាននាក់ក្នុងអង្គប្រជុំនោះ?

**ឆ៖** ចំពោះបញ្ហាអង្គប្រជុំគឺភាគច្រើន គឺកងការពារទាំងអស់ លើកលែងតែអ្នកដែលនៅយាមគុកហ្នឹងនៅទៅ អ្នកដែលនៅសល់ហ្នឹងគឺត្រូវតែទៅប្រជុំទាំងអស់ ហ្នឹងពេលដែលគាត់បើកអង្គប្រជុំ ។

**ស៖** តើ ឌុច តែម្នាក់ឯងជាអ្នកនិយាយក្នុងអង្គប្រជុំនោះ ឬក៏មានអ្នកណាផ្សេងដែរ និយាយក្នុងអង្គប្រជុំនោះ?

**ឆ៖** គឺពេលដែលប្រជុំគឺគាត់ហ្នឹងប្រធានដឹកនាំរួមទាំងអស់ គឺគាត់អ្នកប្រជុំណែនាំឲ្យកងការពារទាំងអស់ហ្នឹង មិនថារូបខ្ញុំ រូបគេ គឺគាត់ហ្នឹងជាអ្នកមានយោបល់ ដាក់បញ្ហាណែនាំពីការងាររបៀបធ្វើរបៀបនេះ របៀបនោះ គឺគាត់ហ្នឹងអ្នកដាក់បញ្ហា ។ ហើយក្នុងការដាក់បញ្ហា គាត់ត្រូវដាក់វិន័យយ៉ាងម៉ឹងម៉ាត់ថា “មិត្តណាអនុវត្តខុសផែនការត្រូវទទួលខុសត្រូវដោយខ្លួនឯង” ។

**ស៖** តើ ឌុច ធ្លាប់និយាយមកលោកផ្ទាល់អំពីរឿងនយោបាយទេ នៅក្នុងអង្គប្រជុំនេះ?

**ឆ៖** បាទ, ត្រង់ហ្នឹងគឺ អត់ដែលឮគាត់និយាយពីនយោបាយអីទេ ដែលឮថាឲ្យយើងគោរពវិន័យការចាត់តាំងរបស់បក្សហ្នឹង ។ ហ្នឹងគឺមានតែប៉ុណ្ណឹង នយោបាយអីផ្សេងគឺអត់ទេ ។ សំខាន់គឺឲ្យយើងហ្នឹងគោរពវិន័យ ការចាត់តាំងតាមបទបញ្ជារបស់គាត់ ។ ហ្នឹងគឺគាត់បានមានប្រសាសន៍នៅក្នុងអង្គប្រជុំ ។

**ស៖** តើគាត់ធ្លាប់និយាយអ្វីទេ អំពីខ្មាំង ពីខ្មាំងរបស់បដិវត្តន៍នោះ គាត់ធ្លាប់បញ្ជាក់ដែរឬទេក្នុងអង្គប្រជុំ?

**ឆ៖** គឺអ្នកទោសហ្នឹងហើយគាត់លើកឡើងជាខ្មាំង ចំណែកឯកងការពារនោះជាមិត្តរបស់គាត់នោះ ។ អ៊ីចឹងគឺគាត់លើកឡើងឲ្យការពារអ្នកទោសហ្នឹងជាខ្មាំង ។

**ស៖** តើ ឌុច ធ្លាប់និយាយអំពីការកសាងគោលជំហរបដិវត្តន៍របស់លោក ឬក៏គោលជំហរបដិវត្តន៍របស់អ្នកយាមម្នាក់ៗនៅក្នុងអង្គប្រជុំហ្នឹងដែរឬទេ?

**ឆ៖** សូមអស់លោកអានសំណួរឲ្យខ្ញុំម្តងទៀត ខ្ញុំស្តាប់សំណួរហ្នឹងមិនទាន់បានច្បាស់ទេ ។

**ស៖** ខ្ញុំនឹងនិយាយឡើងវិញ នៅក្នុងកិច្ចប្រជុំទាំងអស់ហ្នឹង តើ ឌុច ធ្លាប់បាននិយាយអំពី (ខ្ញុំដកស្រង់ពី) កសាងគោលជំហរបដិវត្តន៍របស់សមាជិកអង្គប្រជុំហ្នឹង ពីការកសាងចគោលជំហរបដិវត្តន៍?

**ឆ៖** អត់ដែលផង ។

**ស៖** ប៉ុន្តែ លោកនិយាយថា វាមានការប្រជុំច្រើន មិនមែនជាការប្រជុំតែមួយទេ ។ តើមានប៉ុន្មានដងនៅក្នុងពេលដែលលោកធ្វើការនៅទីនោះ នៅម-១៣នោះ មានការប្រជុំប៉ុន្មានដងដែលថា គឺថាប្រជុំមួយថ្ងៃម្តង ឬក៏មួយអាទិត្យម្តង ឬក៏មួយខែម្តង?

[១០:១៩:១៧]

**ឆ៖** ក្នុងបញ្ហាចំណុចហ្នឹងគឺខ្ញុំក្តាប់មិនបានទេ ព្រោះមិនដឹងជាប៉ុន្មានដងៗគឺមិនបានតាមដានទេ ។

**ស៖** តើលោកអាចនិយាយថា ការប្រជុំហ្នឹងច្រើនជាងមួយដងទេ ដែលថាការប្រជុំហ្នឹង បើយើងប្រើពាក្យថាការប្រជុំហ្នឹងវាច្រើនដង មិនមែនជាការប្រជុំតែម្តងទេ? តើលោកអាចចាំថាការប្រជុំនោះលើសពីមួយដង ឬក៏អាចច្រើនដងយ៉ាងដូចម្តេច?

**ឆ៖** ការប្រជុំហ្នឹងវាច្រើនដង គឺមិនដឹងជាប៉ុន្មានដងទេ តែគ្រាន់យើងខ្ញុំមិនបានក្តាប់ថា ឥឡូវមួយខែម្តង ឬមួយមួយអាទិត្យម្តង គឺខ្ញុំអត់បានតាមដានទេ ។

**ស៖** សូមអរគុណ។ តើលោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំធ្វើទិតៀន ស្វ័យទិតៀនទេនៅក្នុង ម-១៣នោះ?

**ឆ៖** ចំពោះបញ្ហាជំនាន់នុំងគឺមានការទិតៀន ស្វ័យទិតៀនពិត គឺខ្ញុំធ្លាប់ចូលរួមប្រជុំដែរ គឺនោះគឺប្រជុំកងការពារទាំងអស់ ហ្នឹងគឺស្វែងយល់ពីមិត្តល្អ មិត្តអាក្រក់ ។ អ៊ីចឹងបន្តឲ្យទិតៀនគ្នាទៅវិញទៅមក ហ្នឹងគឺធ្លាប់ទទួលបានការទិតៀនពីមិត្តផងគ្នាដែរ ចំពោះរូបខ្ញុំ ។

**ស៖** តើកិច្ចប្រជុំទិតៀត ស្វ័យទិតៀនហ្នឹងធ្វើញឹកញាប់យ៉ាងដូចម្តេចដែរ?

**ឆ៖** អ៊ីចឹងការប្រជុំស្វ័យទិតៀនហ្នឹងគឺវាមានច្រើនដងដែរ តាមការរស់នៅរបស់ខ្ញុំក្នុងកន្លែង១៣។

**ស៖** ដោយសារថា មានអ្នកយាមផ្សេងទៀតក៏ចូលរួមក្នុងកិច្ចប្រជុំហ្នឹងដែរ តើមានមេដឹកនាំជាន់ខ្ពស់ ឬក៏ថ្នាក់លើនៅក្នុងម-១៣ ចូលរួមទេ ឬក៏ ឌុច បានចូលរួមនៅក្នុងកិច្ចប្រជុំទិតៀន ស្វ័យទិតៀនហ្នឹងដែរឬទេ?

**ឆ៖** ចំពោះបញ្ហាហ្នឹងគឺ តាឌុច គាត់អ្នកបញ្ជាឲ្យធ្វើ ហើយក៏គាត់នៅចាំនៅហ្នឹងដែរ នៅនឹងរោងបាយហ្នឹង ប្រជុំភាគច្រើននៅនឹងរោងបាយ គឺគាត់នៅចាំនៅហ្នឹង ។ តើមិត្តណាអ្នកទិតៀនមិត្តណា? អាហ្នឹងគឺគាត់អ្នកលើកឡើងខ្លួនគាត់ ។

[១០:២២:៤៨]

**សះ** តើមានអ្វីនឹងកើតឡើងចំពោះអ្នកដែលត្រូវគេរិះគន់ទិតៀនហ្នឹង បន្ទាប់ពីមានកិច្ចប្រជុំហ្នឹង ហើយការប្រជុំទិតៀនន៉ុងដំណើរការដូចម្តេចដែរ?

**ឆះ** ការប្រជុំទិតៀនហ្នឹងគឺលើកអង្គប្រជុំអ៊ីចឹងដាក់ខ្លួនម្នាក់ម្តងៗអ៊ីចឹង ។ ខ្ញុំឈ្មោះចាន់ ខន អ៊ីចឹងដាក់ខ្លួនឱ្យគេកសាងទៅ ។ ហើយអ៊ីចឹងទៅ គេកសាងប៉ុន្មាននាក់ចំកំហុសយើង យើងត្រូវទទួលអនុវត្តទៅតាមមិត្តផងគ្នាដែលទិតៀនមក ។ ដល់ពេលគេទិតៀនយើងខ្ញុំអស់អ៊ីចឹងទៅ ដាក់ម្នាក់ទៅទៀតទៅ បន្តគ្នារហូតទាល់អស់ក្នុងចំណោមអង្គប្រជុំ ។

**សះ** តើមានអ្នកណាម្នាក់នៅក្នុងកិច្ចប្រជុំស្វ័យទិតៀននេះ ឬក៏ទិតៀន គេបានទិតៀនទៅលើ ឌុច ដែរឬទេ?

**ឆះ** ចំពោះបញ្ហាហ្នឹងអត់ហ៊ានទេ គឺមិនហ៊ានទាន់តែសោះ ។ ព្រោះគាត់ប្រធានធំណាស់ គឺមិនអាចហ៊ានទិតៀនគាត់ទេ ចំពោះកងការពារនោះ លើកលែងតែកម្មាភិបាលគ្នាគាត់អីមិនដឹង ព្រោះគាត់ជាថ្នាក់ដឹកនាំ ខ្ញុំជាកងការពារ ។

**សះ** ខ្ញុំសូមចូលទៅដល់សំណួរដែលទាក់ទងអំពីរណ្តៅដែលគេឃុំខ្លួនអ្នកទោស ហើយនិងចំនួនអ្នកទោសប៉ុន្មាននាក់នៅក្នុងរណ្តៅនីមួយៗ។ សុំការអនុញ្ញាតពីតុលាការ ខ្ញុំសូមអានផ្នែកមួយនៃចម្លើយដែលអ្នកស៊ើបអង្កេតបានកត់ត្រាពីសម្ភាសន៍នៅ D78 ដែលលោកចៅ ក្រមឡាវែន៍ បានយោងហើយដើម្បីឱ្យអ្នកបកប្រែអាចនឹងបកទាន់ គឺ ERN0019 នៅក្នុងផ្នែកនេះគឺមិនមាននៅក្នុងភាសាអង់គ្លេសទេ ខ្ញុំនឹងអានជាភាសាបារាំង ។

ហើយលោក ចាន់ ខន សូមលោកចាំស្តាប់ ដែលខ្ញុំអានពីសេចក្តីថ្លែងការណ៍ដែលលោកបានសម្ភាសន៍ ផ្តល់សម្ភាសន៍ជូនទៅអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត។ “នៅខាងជើងគុកនោះនៅមានរណ្តៅមួយចំនួន ដែលអាចមនុស្សពី៦០ ឬ៧០នាក់នៅកន្លែងនោះ នៅក្នុងរណ្តៅនោះ” ។ លោក ចាន់ ខន តើលោកអាចបញ្ជាក់បានទេ តើសេចក្តីថ្លែងការណ៍ដែលលោកឆ្លើយនោះត្រឹមត្រូវ តើលោកនឹកឃើញទេថាតើមានអ្នកទោសប៉ុន្មានដែលគេឃុំនៅក្នុងរណ្តៅនោះ រណ្តៅនីមួយៗមានប៉ុន្មាន?

**ឆះ** ចំពោះបញ្ហាក្នុងរណ្តៅពីរបីហ្នឹងគឺខ្ញុំក្តាប់អ្នកទោសមិនបានទាំងអស់ទេ ព្រោះដូចខ្ញុំបញ្ជាក់ខាងលើអ៊ីចឹង គឺវាវែងឆ្នាំពេក តែរណ្តៅមួយនេះអាចដាក់មនុស្សបានហាហុកសិបនាក់មែនពិត ប៉ុន្តែក្នុង

រណ្តៅមួយៗវាមិនអាចដាក់មនុស្សក្នុងហ្នឹងបានហាហុកសិបនាក់ទេ ក្នុងរណ្តៅមួយ រណ្តៅខ្លះបួនដប់ម្ភៃនាក់ រណ្តៅខ្លះបួនដប់ម្ភៃនាក់អ៊ីចឹង តែគេដាក់គ្រប់តែរណ្តៅ ។

[១០:២៦:៥៩]

**ស៖** នៅពេលដែលលោកធ្វើការជាអ្នកយាមនៅម-១៣ តើលោកបានឃើញរណ្តៅទាំងអស់នោះពេញ ឬក៏ពេញតែពាក់កណ្តាល ឬក៏កន្លះ ឬក៏នៅទទេ? តើមានអ្នកទោសប៉ុន្មាននៅក្នុងរណ្តៅទាំងនោះ ប្រហែលប៉ុនណា?

**ឆ៖** ចំពោះអ្នកទោសនៅក្នុងរណ្តៅដូចខ្ញុំបញ្ជាក់អំមិញអ៊ីចឹងគឺថា ក្នុងមួយរណ្តៅប្រហែលជាបួនដប់នាក់ ក្នុងរណ្តៅមួយប្រហែលជាបួនដប់នាក់អ៊ីចឹង ។ តែដាក់គ្រប់តែរណ្តៅទាំងបី ។

**ស៖** ខ្ញុំហាក់ដូចជាតាមអត់ទាន់ចម្លើយរបស់លោក ខ្ញុំសូមឲ្យមានការបំភ្លឺទៅលើចំណុចនេះ ។ លោកបានរៀបរាប់ថា រណ្តៅនោះគឺមានអ្នកទោស៥០ទៅ៦០នាក់ ។ លោកបាននិយាយថា រណ្តៅនីមួយៗគឺមានបួនទៅដប់នាក់ ហើយលោកបាននិយាយថា លោកឃើញរណ្តៅនោះពេញ ។ ប្រសិនបើរណ្តៅពេញ ហើយរណ្តៅមាន៥០ទៅ៦០ អ៊ីចឹងគឺខ្ញុំសូមឲ្យលោកជួយបំភ្លឺទៅលើចំនួនលេខ ដែលវាមានលក្ខណៈភ័ន្តច្រឡំនៅទីនេះបន្តិច ។

**ឆ៖** អ៊ីចឹងគឺខ្ញុំបញ្ជាក់ជូនឡើងវិញគឺថា រណ្តៅហ្នឹងវាអាចដាក់មនុស្សហាហុកសិបនាក់ ប៉ុន្តែគឺអ្នកទោសដែលជាប់នៅក្នុងហ្នឹងវាអត់បានហាហុកសិបនាក់ទេ បានតែរណ្តៅមួយនោះបានដាក់ប្រហែលជាដប់ ឬម្ភៃនាក់តែប៉ុណ្ណោះទេ ។ អាហ្នឹងសូមអស់យោបល់ ។

**ស៖** ដូច្នេះ ចំនួនសរុប ថាតើមានអ្នកទោសសរុប បើសិនបូកចូលគ្នាទៅមានអ្នកទោសសរុបចំនួនប៉ុន្មាននៅក្នុងរណ្តៅនីមួយៗ?

**ឆ៖** ចំពោះអ្នកទោសនៅក្នុងរណ្តៅនីមួយៗដូចខ្ញុំបានជម្រាបម្សិលមិញអ៊ីចឹង គឺតាមវាមិនទាន់ទេ ថ្ងៃណាច្រើនៗទៅ ថ្ងៃណាតិចៗទៅ ខែណាតិចៗ ខែណាច្រើនៗ គឺវាមិនអាចសន្និដ្ឋានបានទេ ។

**ស៖** លោកប្រធានគឺដោយសារតែយើងឃើញ ខ្ញុំពិនិត្យឃើញពេលវេលា ខ្ញុំគិតថា យើងគួរតែធ្វើការសម្រាកជាមុនទៅ មុនពេលដែលខ្ញុំចូលទៅដល់ប្រធានបទមួយទៀត ដែលខ្ញុំចង់តាំងសំណួរ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវយើងដល់ម៉ោងសម្រាកហើយ ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញ ។ មន្ត្រីតុលាការសម្របសម្រួលអញ្ជើញសាក្សីទៅកាន់បន្ទប់

រង់ចាំ ហើយនឹងអញ្ជើញគាត់មកវិញឲ្យបានមុនម៉ោងដប់មួយខ្វះដប់នាទី ។

*[សវនាការសម្រាកពីម៉ោង១០:៣១នាទី ដល់ម៉ោង ១០:៥៧នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការ ពិភាក្សាដេញដោលតទៅទៀត ហើយបន្តទៅនេះ សូមប្រគល់វេទិការជូនទៅ សហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តសួរដល់សាក្សីរូបនេះបន្តទៀត ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណ លោកប្រធាន ។ គឺមានសំណួរមួយ ដែលខ្ញុំមិនបានសួរ ដែលសំណួរនេះពាក់ព័ន្ធទៅនឹងការប្រជុំជាមួយនឹង ឌុច ។ លោក ចាន់ ខន លោកប្រាប់យើងថា ឌុច បាននិយាយថា ប្រសិនបើលោកមិនអនុវត្តបញ្ជារបស់គាត់ទេ លោកនឹងទទួលរងនូវការទណ្ឌកម្ម ។

**ស៖** ថាតើ ឌុច ដែល និយាយក្នុងកិច្ចប្រជុំដែរឬទេ? ថាតើការដាក់ទណ្ឌកម្មនោះ គឺយ៉ាងម៉េច ប្រសិនបើអត់មានការគោរព តាមបញ្ជានោះ?

**សាក្សី KW-32៖**

**ឆ៖** ចំពោះបញ្ហាហ្នឹង គឺតាឌុច គាត់បានណែនាំក្នុងអង្គប្រជុំពិតមែន ។ តែចំពោះដែលកងការពារទាំងអស់គ្នា គឺត្រូវអនុវត្តទៅតាមគាត់ដែលគាត់ដាក់ ។ ឈ្មោះណាមួយដែលមិនអនុវត្តតាម គឺត្រូវទទួលវិន័យនុ៎ង ។

**ស៖** ថាតើលោកដែលជាអ្នកយាមហ្នឹង យល់ថាទណ្ឌកម្មហ្នឹងវាយ៉ាងម៉េច? ថាតើលោកមានការគិតឃើញថាតើទណ្ឌកម្មនោះ វានឹងត្រូវគេដាក់យ៉ាងម៉េច ប្រសិនបើលោកអត់អនុវត្តតាមបញ្ជាគេនោះ?

**ឆ៖** យើងខ្ញុំបញ្ជាក់ជូនថា អារឿងដាក់ទណ្ឌកម្មហ្នឹង គឺយើងដែលធ្វើខុសពីមាគ៌ា ពីបទបញ្ជារបស់គាត់ ហ្នឹងគឺត្រូវដាក់ទណ្ឌកម្ម ។ តែបើអ្នកដែលធ្វើ អនុវត្តទៅតាមគាត់បាន គឺគាត់អត់ ដាក់ទណ្ឌ

កម្មទេ ។ ចំពោះរូបខ្ញុំ ក៏មិនដែលទទួលទណ្ឌកម្មពី ឌុច ដែរ គ្រាន់ថាខ្ញុំខ្លាចស្លាប់ បានខ្ញុំប្រឹងធ្វើតាមបញ្ជា ។

**ស៖** ក្រៅពី ចាន់ វឿន តើលោកស្គាល់នរណាផ្សេងដែរឬទេ ដែលពួកគេមិនបានគោរពតាមបញ្ជាហើយទទួលរងទណ្ឌកម្មនោះ? ហើយប្រសិនបើលោកដឹងថាអ្នកផ្សេងក្រៅពី ចាន់ វឿន គាត់ទទួលរងទណ្ឌកម្មនោះ តើគាត់ទទួលរងទណ្ឌកម្មអ្វី?

**ឆ៖** នៅក្នុងអង្គភាព១៣ ហ្នឹង គឺក្រៅពី ចាន់ វឿន មានឈ្មោះ ផល ត្រូវទទួលរងទណ្ឌកម្មដោយសារពី តាឌុច គាត់ដាក់គុក។ និយាយរួមគឺដាក់គុក ។ ឈ្មោះ ផល ហ្នឹង គឺគាត់ដាក់ផ្ទាល់ ។

**ស៖** តើមានអ្វីកើតឡើងចំពោះ ផល តើបន្ទាប់ពីគាត់ដែលដាក់គុកហ្នឹង តើគាត់ត្រូវបានគេដោះលែង ឬក៏យ៉ាងម៉េច?

**ឆ៖** ផល ហ្នឹង គាត់ស្លាប់បាត់ហើយ តែក្នុងការស្លាប់ហ្នឹង មិនដឹងតាឌុច គាត់វៃចោល មិនដឹងគាត់ឈឺស្លាប់ ព្រោះអាហ្នឹង គឺខ្ញុំចេញពីអង្គភាពហ្នឹងហើយ ។

[១១:០២:១៣]

**ស៖** កាលពីម្សិលមិញ លោកប្រាប់ខ្ញុំថា តាទាំងពីររបស់លោកត្រូវបានឃុំនៅម-១៣ ។ ហើយលោកបាននិយាយថា តាខាងឪពុកត្រូវបានសម្លាប់នៅទីនោះ ហើយជីតាខាងម្តាយ ត្រូវបានដោះលែង ។ លោកតើលោកអាចប្រាប់ឈ្មោះតារបស់លោកទាំងពីរបានដែរឬទេ? ហើយថា តាមួយណាជាតាខាងឪពុក ជីតាមួយណាជាជីតាខាងម្តាយ?

**ឆ៖** ចំពោះតាខាងម្តាយ គឺឈ្មោះ តាសុទ្ធ ដែលតាឌុច គាត់និយាយមិញនុ៎ង ហ្នឹងតាខាង ម្តាយខ្ញុំ ហ្នឹងត្រូវបានដោះលែងរួច។ តែនាបច្ចុប្បន្នឥឡូវ គាត់ស្លាប់បាត់ហើយ គាត់ចាស់ហើយ ។ ហើយចំពោះតាខាងឪពុក គឺឈ្មោះ តាទឹម ។ តាទឹម ហ្នឹងមិនដឹងជាស្លាប់ដោយតាឌុច វៃចោល ឬមួយក៏ គាត់ស្លាប់នឹងជំងឺទេ តែដឹងថាច្បាស់ជាស្លាប់នៅក្នុងមន្ទីរ១៣ ហ្នឹងហើយ តែមិនដឹងជាសាកសពនៅកន្លែងណាក៏ខ្ញុំអត់ដឹងដែរ ពីព្រោះពេលនោះ គឺខ្ញុំត្រូវចេញ ដូចខ្ញុំជម្រាបដដែលហើយដដែលទៀត គឺខ្ញុំចេញទៅធ្វើស្រែបាត់ គឺខ្ញុំអត់បានដឹងទេ ។

**ស៖** ថាតើឪពុករបស់លោកផ្ទាល់ ដឹងទេថា ឪពុករបស់គាត់ត្រូវបានគេឃុំនៅ ម-១៣ ហើយត្រូវបានគេសម្លាប់នៅម-១៣ នោះ?

**ឆ៖** សុំអានសំណួរមួយលើកទៀត ខ្ញុំស្តាប់មិនបានច្បាស់ទេ អារឿងថាឪពុកហ្នឹង ។

**ស៖** លោកបានប្រាប់យើងថា លោកប្រាប់ឈ្មោះរបស់ជីតាខាងឪពុក ដែលគាត់ឈ្មោះទឹមៗ លោកបានប្រាប់ថា តាទឹម ត្រូវបានគេឃុំ ឬក៏ជាអ្នកទោសនៅម-១៣ ហើយត្រូវបានសម្លាប់ នៅទីនោះ ។

ដូច្នេះ សំណួររបស់ខ្ញុំនោះ គឺថាឪពុករបស់លោកដឹងថា តាទឹម ត្រូវបានគេឃុំខ្លួន និងសម្លាប់នៅម-១៣ ដែរឬទេ?

[១១:០៥:១៥]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សាក្សី គឺគាត់អត់ដឹងថា ជីតារបស់គាត់នោះត្រូវបានស្លាប់ដោយសារជំងឺ ឬក៏គេសម្លាប់នៅទីនោះទេ ។ ប៉ុន្តែនៅពេលនេះសំណួរ ដែលចោទសួរនោះគឺប្រើពាក្យថា “សម្លាប់” នៅទីនោះ ។

ដូច្នេះ វាជាបញ្ហានៃការបកប្រែ ឬក៏វាពាក្យដែលខាងសហព្រះរាជអាជ្ញាបានប្រើប្រាស់ គឺសាក្សីបាននិយាយថា ជីតារបស់គាត់នោះស្លាប់ ហើយគាត់អត់ដឹងថាស្លាប់ដោយសារជំងឺ ឬក៏គេសម្លាប់នៅទីនោះ ។ ហើយគឺ សាក្សីគាត់បាននិយាយថា ស្លាប់ដោយមិនមានការប្រើពាក្យថា សម្លាប់នោះទេ ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

ខ្ញុំនិយាយអំពី តាទឹម ដែលត្រូវបានគេឃុំនៅម-១៣ ។ នៅពេលនេះ គឺខ្ញុំនិយាយអំពីតាទឹម ដែលគេឃុំនៅ ម-១៣ ។ តើសាក្សី ចង់ឲ្យខ្ញុំអានសំណួរឡើងវិញ ឬយ៉ាងម៉េច?

**សាក្សី KW-32៖**

ខ្ញុំបញ្ជាក់ជូនថា តាទឹម ហ្នឹង ដូចខ្ញុំបញ្ជាក់ជូនអ៊ីចឹង គឺជាជីតាខាងឪពុករបស់ខ្ញុំ ។ ក៏ប៉ុន្តែ ដូចខ្ញុំជម្រាបដដែលហើយដដែលទៀត ថាក្នុងការស្លាប់ហ្នឹង គឺមិនដឹងឈឺ ឬមួយតាខុច គាត់វៃចោល គឺខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំអត់នៅហ្នឹង គឺខ្ញុំទៅធ្វើស្រែបាត់ ។ តែឈ្មោះ ទឹម ហ្នឹងច្បាស់ជាស្លាប់នៅហ្នឹងហើយ នៅក្នុងមន្ទីរ១៣ហ្នឹង ។

**ស៖** ឪពុករបស់លោក ឈ្មោះ ចាន់ ខុម តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ឪពុករបស់ខ្ញុំ គឺឈ្មោះ ចាន់ ខុម អ៊ីចឹង ។ ត្រឹមត្រូវហើយ ។

**ស៖** ថាតើចាន់ ខុម គាត់បានដឹងទេថា តាទឹម ត្រូវបានគេឃុំនៅម-១៣? ថាតើគឺគាត់បានដឹងថា គាត់ត្រូវបានគេឃុំនៅ ម-១៣ ហើយនៅរស់ដែរឬទេ?

**ឆ៖** សូមលោកអានមួយលើកទៀត ថាម៉េច? ថាឪពុកខ្ញុំម៉េច?

**ស៖** ថាតើឪពុករបស់លោក ដឹងថាឪពុករបស់គាត់នោះ ត្រូវបានគេឃុំនៅម-១៣ ដែរឬទេ?

**ឆ៖** គឺខ្ញុំបញ្ជាក់ជូន គឺឪពុកខ្ញុំ គឺដឹង។ ក៏តែនេះមិនមែនជាជីតារបស់ខ្ញុំបង្កើតទេ គឺត្រូវជាឪពុកមារបស់ឪពុកខ្ញុំ ។ អ៊ីចឹងក្នុងការចាប់ តាទឹម មកដាក់ដែលគុក១៣ ហ្នឹង គឺឪពុកខ្ញុំដឹងពិតប្រាកដថាចាប់មកដាក់ហើយ ។

[១១:០៩:៥៨]

**ស៖** លោកព្ញជនជាប់ចោទបាននិយាយថា ឪពុករបស់លោក ចាន់ ខុម មានទំនាក់ទំនងល្អជាមួយនឹង ឌុច ។ ថាតើត្រឹមត្រូវដែរឬទេអ្វីដែលបានលើកឡើងនុ៎ង?

**ឆ៖** ចំពោះបញ្ហាឪពុកខ្ញុំ មិនដែលមកទាក់ទង តាឌុច ទេ ។ គឺគាត់នៅតែស្រែឯណោះ គឺចម្លើយ តាឌុច ហ្នឹង គឺមិនត្រឹមត្រូវទេ ។ បានថាមិនត្រឹមត្រូវ ឪពុកខ្ញុំមិនដែលមកទេ ដែលហ្នឹងខ្ញុំរស់នៅហ្នឹង ។

**ស៖** ខ្ញុំសូមអានសម្រង់ខ្លីមួយ ពីចម្លើយដែលលោកបានឆ្លើយដល់អ្នកស៊ើបអង្កេត កាលពីឆ្នាំទៅមិញ។ ហើយដើម្បីជាកំណត់ហេតុរបស់តុលាការ គឺឯកសារលេខ D៧៨(៤) គឺបានកត់នៅថ្ងៃ៣១ ខែមីនា ឆ្នាំ២០០៨ គឺលេខ ERN00195542 សូមឲ្យ ចាន់ ខន ស្តាប់ឲ្យបានច្បាស់លាស់ ដែលខ្ញុំអាននូវអ្វីដែលលោកបានឆ្លើយទៅអ្នកស៊ើបអង្កេតកាលពីឆ្នាំទៅ ។

ជាដំបូងខ្ញុំចូលបដិវត្តន៍តាមរយៈមេភូមិ គឹម ដែលបានស្លាប់ ។ គាត់ជាមេឃុំ និងមេឃុំឈ្មោះព្រីង ស្លាប់ក្នុងឆ្នាំ១៩៧៣ ។ ដំបូងមេភូមិថា ឲ្យខ្ញុំទៅធ្វើយោធា ប៉ុន្តែ បែរជាយកទៅដល់មន្ទីរ១៣ ដែលមានសុទ្ធតែអ្នកទោស ។ អ្នកដែលត្រូវបាននាំចូលបដិវត្តន៍ដូចខ្ញុំមានចំនួនច្រើន ដែលរើសមកពីកន្លែងផ្សេងៗគ្នា គឺពួកគេត្រូវបាននាំឲ្យចូលបដិវត្តន៍ដូចខ្ញុំដែរ ។

សំណួរដំបូងរបស់ខ្ញុំ លោក ចាន់ ខន តើលោកបញ្ជាក់ថា ចម្លើយដែលខ្ញុំទើបតែអានត្រឹមត្រូវដែរឬទេ?

**ឆ៖** ចំពោះបញ្ហាសំណួរដែលលោកអាននោះ គឺពិតជាត្រឹមត្រូវតាមចម្លើយរបស់ខ្ញុំឆ្លើយពិត ។

**ស៖** លោកគិតថា លោកនឹងទៅធ្វើទាហាន ធ្វើយោធា ប៉ុន្តែលោកបែរជាត្រូវគេបញ្ជូនទៅធ្វើអ្នកយាមនៅមន្ទីរ១៣វិញ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សំណួរនេះ ពិតជាត្រឹមត្រូវ តាមដែលខ្ញុំឆ្លើយ ។

**ស៖** ថាតើលោក ឬក៏ឪពុករបស់លោក ដែលសួរដែរឬទេ ថាលោកចង់ទៅម-១៣ ហើយធ្វើការនៅទីនោះ?

**ឆ៖** ចំពោះបញ្ហាហ្នឹង គឺឪពុកខ្ញុំអត់ដឹង ដំបូងមកអត់ដឹងថា ខ្ញុំមកនៅហ្នឹងផង ។ បានថាអត់ដឹង ចុះដល់មេឃុំប្រាប់ថាទៅធ្វើយោធា ។ ស្រាប់តែឮដំណឹងថានៅហ្នឹង ។ អ៊ីចឹង គឺឪពុកខ្ញុំគឺគាត់អត់ដឹង អត់ឮទេ រឿងបញ្ហាដែលខ្ញុំចាកចេញពីផ្ទះមកនោះ ។ ព្រោះនៅជំនាន់នោះ គឺស្រេចតែមេភូមិ មេឃុំរបស់គេបញ្ជូនទេ គឺគេបញ្ជូនទៅមុខព្រួញណា មុខទៅហើយ ទាំងគេ ទាំងខ្ញុំត្រូវតែទៅ ។

**ស៖** ថាតើមានអ្វីកើតឡើងប្រសិនបើលោកបដិសេធបញ្ហាមិនទៅមន្ទីរម-១៣ ឬក៏លោកបដិសេធមិនទៅធ្វើទាហាន តើមានអ្វីកើតឡើង?

**ឆ៖** សូមអានសំណួរហ្នឹងឲ្យច្បាស់មួយសាទៀត ។

**ស៖** លោកនិយាយថា លោកមិនអាចបដិសេធទៅលើបញ្ហានោះទេ អ៊ីចឹងមានអ្វីកើតឡើងប្រសិនបើលោកបដិសេធបញ្ហា និងការស្នើសុំឲ្យទៅហ្នឹង?

**ឆ៖** ខ្ញុំស្តាប់សំណួរអត់ទាន់បានច្បាស់ទេលោក ។

**ស៖** លោកបានប្រាប់យើងថា មានសំណើមកពីមេភូមិ គេសុំឲ្យលោកទៅធ្វើការបម្រើបដិវត្តន៍អ៊ីចឹងត្រូវទេ?

**ឆ៖** ត្រូវ ។

**ស៖** ហើយគេប្រាប់លោកថា គេឲ្យលោកទៅធ្វើជាយោធា តើអ៊ីចឹងត្រូវទេ?

**ឆ៖** ត្រូវ ។ ទៅតាមសំណួរហ្នឹង ពីភូមិមក ។

**ស៖** តើលោកមានលទ្ធភាពណា ឬក៏ឱកាសអ្វីមួយដើម្បីបដិសេធនឹងសំណើហ្នឹងថា មិនព្រមធ្វើទាហានតាមសំណើហ្នឹង អាចបដិសេធបានទេ?

**ឆ៖** នៅក្នុងជំនាន់ហ្នឹង អត់ហ៊ានបដិសេធទេ តែគេបញ្ជូន គឺត្រូវតែទៅហើយ ព្រោះការបដិសេធទៅខ្លាចគ្រោះថ្នាក់ដល់ក្រុមគ្រួសារ ។ អ៊ីចឹងបើគេបញ្ជូនឲ្យទៅធ្វើអី ត្រូវតែទៅ ។ គឺថាបដិវត្តន៍ហ្នឹងផ្តាច់ម៉ាត់ហើយ អនុវត្តតាមផែនការហ្នឹង មិនចង់ទៅក៏ត្រូវតែទៅដែរ ។

**លោក អាឡិចសាន់ឌឺ បើត៖**

លោកប្រធាន ខ្ញុំមិនមានសំណួរទៅសាក្សីទៀតទេ ប៉ុន្តែខ្ញុំមានសំណួរពីរទៅជនជាប់ចោទ ខ្ញុំសូមអនុញ្ញាតសួរ ។

**ប្រធានអង្គជំនុំ៖**

សូមអនុញ្ញាត សូមអញ្ជើញសហព្រះរាជអាជ្ញា ហើយសូមជនជាប់ចោទត្រៀមស្តាប់នូវសំណួរឲ្យបានច្បាស់មុននឹងឆ្លើយ ។ សូមអញ្ជើញ ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោក កាំង ហ្កេកអ៊ាវ តើមានអ្វីកើតឡើងចំពោះក្រុមគ្រួសារ ដែលបានបដិសេធសំណើដែលបញ្ជូនពីបក្សថា ឲ្យបញ្ជូនកូនរបស់គេទៅម-១៣នោះ?

**ជនជាប់ចោទ៖**

**ឆ៖** អ្នកដែលមានសំណើពីខាងលើឲ្យបញ្ជូនយុវជនមកម-១៣នេះ ត្រូវតែបញ្ជូន ជៀសមិនរួច។ ដល់ក្រោយមកចេញទៅវិញ អាហ្នឹងវាផ្សេង ដូច្នេះ អ្នកដែលបញ្ជូនមក គ្មានអ្នកណាខានទេ មិនដែលមានអ្នក ណាដែលហ៊ានខាននោះ ត្រូវតែមក ។

[១១:១៧:១៣]

**ស៖** នៅពេលលោកប្រើពាក្យថា ត្រូវតែទៅម-១៣នោះ តើលោកចង់បញ្ជាក់ថាមិនមានលទ្ធ-ភាពអ្វីក្រៅពីហ្នឹង គឺថាមិនអាចបដិសេធនឹងសំណើ ឬក៏មិនអាចច្រានចោលសំណើហ្នឹងបានទាល់ តែសោះ ឬដូចម្តេច?

**ឆ៖** ធម្មតាគ្មានអ្នកណាហ៊ានបដិសេធទេ ដូចមិត្តខន គាត់បញ្ជាក់ជូនមិញហ្នឹង។ អាហ្នឹងគាត់ច្បាស់ជាងខ្ញុំហើយ ម៉ែឪគាត់បញ្ជូនគាត់មកនោះ។ ខ្លាចស្លាប់ ។

**ស៖** លោកបានឮសាក្សីបញ្ជាក់ថា ទាក់ទងពីទំនាក់ទំនងឪពុករបស់គាត់ជាមួយលោក ។ តើលោកប្រកាន់ជំហរថា ពុករបស់សាក្សីនេះមានទំនាក់ទំនងល្អជាមួយលោកទេ បន្ទាប់ពីលោកបានឮសាក្សីបញ្ជាក់ចុងក្រោយអម្បាញ់មិញនេះ?

**ឆ៖** បងខ្ញុំ អញ្ជើញទៅកន្លែងខ្ញុំម្តងឬក៏ពីរដង មុនមិត្តខន ទៅដល់កន្លែងខ្ញុំ ។

**ស៖** ហើយលោកបានឮសាក្សីបានបញ្ជាក់ពីបញ្ហាទាក់ទងពីឪពុកផ្ទាល់របស់គាត់នុ៎ង គឺថាជីតារបស់គាត់ ដែលត្រូវបានឃុំខ្លួននៅម-១៣ សំណួររបស់ខ្ញុំ តើលោកប្រកាន់ជំហរថា តាខុម នៅតែមានទំនាក់ទំនងល្អជាមួយលោកក្នុងពេលនោះ បន្ទាប់ពីលោកបានដាក់ឃុំឪពុករបស់តាខុម ហ្នឹងនៅ ម-១៣ ហើយនោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា មិត្តខន ចេញពីខ្ញុំតាំងពីមុន ដែលបងទឹម ត្រូវគេបញ្ជូន ពូទឹមត្រូវគេបញ្ជូន ទៅដល់ម-១៣ម្ដ៉េះ ហើយមុនពូសុខ ទៅដល់ម-១៣ ម្ដ៉េះ ។ ហើយចំណែកមិត្តខុម បងខុម គាត់អញ្ជើញទៅកន្លែងខ្ញុំ មុនមិត្តខន ចូល ។ ទៅតែម្ដង ឬពីរដងប៉ុណ្ណឹងទេ ដល់មិត្តខន ចូលទៅនៅជាមួយខ្ញុំ អត់ឃើញមុខបងខុម ទេ ហើយក្រោយមកបាត់មុខ បងខុម រហូត ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនមានសំណួរអ្វីបន្ថែមទៀតទេ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត សូមប្រគល់វេទិកានេះទៅមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ប្រសិនបើមានអាចសួរដល់សាក្សីរូបនេះ ដោយសុំសួរតាមលំដាប់នៃក្រុម១, ក្រុម២, ក្រុម៣, ក្រុម៤ ។

ជាដំបូងនេះ សូមអញ្ជើញមេធាវីក្រុម១មុន ប្រសិនបើមាន ។

[១១:២០:២៤]

**សួរដោយកញ្ញា ទី ស្រ៊ុនណា៖**

សូមអរគុណលោកប្រធាន មុននឹងខ្ញុំធ្វើការចោទសួរ ខ្ញុំសូមបញ្ជាក់ជាមួយនឹងសាក្សីនូវចំណុចមួយចំនួន ។

**ស៖** ខ្ញុំសូមបញ្ជាក់ជាមួយនឹងលោក ចាន់ ខន ទាក់ទងទៅនឹងករណីទឹកជំនន់ ។ ពេលដែលទឹកជំនន់កើតឡើងហ្នឹង គឺនៅពេលយប់ ឬក៏ពេលព្រឹក?

**សាក្សី KW-32៖**

**ឆ៖** ក្នុងករណីទឹកជំនន់ហ្នឹង គឺរៀបភ្លឺហើយ ជិតភ្លឺ អ៊ីចឹងគឺទឹកមកឈ្មុលរហូតម៉ោងប្រហែលជាម៉ោងប្រហែលជាបួនប្រាំហើយ ទឹកមកឡើងជាបន្តបន្ទាប់ ដល់តែពេញប៉ាយមែនទែន គឺភ្លឺហ្មង ។

**ស៖** ខ្ញុំសូមបន្តចំណុចដែលខ្ញុំត្រូវបញ្ជាក់មួយទៀត ។ ម្សិលមិញហ្នឹងលោកពូបានលើកឡើងទាក់ទងទៅនឹងចំណុចនៃគ្រូពេទ្យ លោកពូថា នៅក្នុងម-១៣ ហ្នឹងមានគ្រូពេទ្យប្រចាំនៅម-១៣ ហើយខ្ញុំចង់សួរលោកពូបញ្ជាក់ថា តើគ្រូពេទ្យហ្នឹង គឺជាគ្រូពេទ្យដែលសម្រាប់ព្យាបាលអ្នកយាម ឬក៏គ្រូពេទ្យសម្រាប់ព្យាបាលអ្នកទោស?

**ឆ៖** ខ្ញុំក៏បញ្ជាក់ជូនវិញ គឺថាចំពោះបញ្ហាពេទ្យនេះគឺ ជាក់ស្ដែងគឺជំនាន់ហ្នឹង មិនសូវសម្បូរថ្នាំទេ មិនដូចយើងរាល់ថ្ងៃទេ។ ហើយមួយទៀតក៏ ពេទ្យនេះ គឺជាពេទ្យប្រចាំការអង្គភាពហ្នឹង អ្នក

ជម្ងឺឈឺក៏ត្រូវមើលថែ អ្នកទោសឈឺក៏ត្រូវមើលថែ រីឯកងការពារឈឺ ក៏ត្រូវតែមើលថែ ទោះអត់មានបែងចែកពេទ្យអ្នកទោស ឬមួយពេទ្យកងការពារហ្នឹង គឺពេទ្យតែមួយហ្នឹង សរុប ។

**ស៖** ខ្ញុំសូមសួរម្តងទៀត ។ តើអ្នកទោសដែលគាត់ជាប់នៅក្នុងរណ្តៅ គាត់ធ្លាប់ទទួលបានការព្យាបាលពីគ្រូពេទ្យដែរឬទេ?

**ឆ៖** ចំពោះបញ្ហាហ្នឹង គឺដូចខ្ញុំបញ្ជាក់ជូនមិញអ៊ីចឹង គឺថ្នាំពេទ្យ វាតិចតួចស្តួចស្តែង ។ ក្នុងរណ្តៅមានការឈឺអ៊ីចឹង បើសិនជាមានថ្នាំទៅ ក៏ជួយឲ្យលេប ឲ្យចាក់អ៊ីចឹងទៅ បើថាអត់ទេ គឺអត់អ៊ីចឹងទៅ ។

**ស៖** ចំពោះលោកពូផ្ទាល់ តើលោកពូដែលឃើញមានអ្នកទោសដែលនៅក្នុងរណ្តៅហ្នឹង ទទួលបានការព្យាបាលដោយផ្ទាល់ ដូចថាឲ្យថ្នាំបន្តិចបន្តួចអីនៅក្នុងដំណាក់កាលនៅក្នុងម-១៣ហ្នឹង តើលោកពូមានដែលធ្លាប់ឃើញដោយផ្ទាល់ថា មានការព្យាបាលអ្នកទោសនៅក្នុងរណ្តៅហ្នឹងដែរឬអត់?

**ឆ៖** ធ្លាប់ឃើញ ឲ្យជាថ្នាំ តែថ្នាំដូចអាចម៍ទន្សាយខ្មៅៗរោល ។

[១១:២៤:០៥]

**ស៖** ខ្ញុំសូមបន្តមួយទៀតលោកពូ។ ពីព្រឹកមិញលោកពូមានប្រសាសន៍ថា ពេលដែលអ្នកទោសក្រោយពីការសួរចម្លើយហើយ ត្រូវបាននាំចេញមក លោកពូឃើញមានឈាម មានស្នាមរបួស តើអ្នកទោសទាំងហ្នឹងមានទទួលបានការព្យាបាលពីគ្រូពេទ្យនៅទីនោះដែរឬទេ?

**ឆ៖** អាហ្នឹងគឺអត់ ។

**ស៖** អត់ទោសហ្នឹងទៅណាវិញ លោកពូ?

**ឆ៖** អាហ្នឹងទុកហ្នឹងទៅ វាឈឺនឹងព្រោះគេសួរចម្លើយ បើលើកលែងតែឈឺគ្រុនអី អាហ្នឹងគេព្យាបាល បើក្នុងការសួរចម្លើយទៅ គេវ៉ៃ គេជេរហ្នឹង ទុកចោលអ៊ីចឹង បើសិនជាស្លាប់ ស្លាប់ទៅបើសិនរស់ៗបន្តទៀតអ៊ីចឹងទៅ ។

**ស៖** អ៊ីចឹងមានន័យថា អ្នកទោសដែលគេសួរចម្លើយហើយ គឺពុំដែលមានការការព្យាបាល ទេ ទោះបីជាគាត់ឈឺធ្ងន់យ៉ាងណាក៏ដោយ អ៊ីចឹងមែនអត់លោកពូ?

**ឆ៖** ដែលខ្ញុំបញ្ជាក់ជូនគាត់មួយលើកទៀតថា ឲ្យបានច្បាស់គឺថា ចំពោះដែលគេសួរចម្លើយហើយមកមានបែកពេញខ្លួន ស្លាកស្នាមវ៉ៃហ្នឹងគឺអត់ទេ តែបើសិនជាឈឺគ្រុនអាហ្នឹងមានការព្យាបាល ។

**ស៖** សូមអរគុណលោកពូ ។ មួយទៀតពាក់ព័ន្ធទៅនឹងបញ្ហាទឹកជំនន់ ។ នៅពេលទឹកជំនន់កើតឡើងហ្នឹង គឺមានការសង្គ្រោះ ។ លោកពូថា មានការសង្គ្រោះដោះលែងអ្នកទោស នៅពេលដែលដោះលែងអ្នកទោសពី បានន័យថា យើងជួយសង្គ្រោះអ្នកទោសពីទឹកជំនន់ ។ ពេលនោះ តើអ្នកទោសហ្នឹងគឺត្រូវបានដោះខ្នោះចេញ ឬមួយក៏នៅរក្សានូវនឹងខ្នោះដដែល?

**ឆ៖** ចំពោះបញ្ហាហ្នឹងអ្នកទោសដែលជាប់នៅក្នុងរណ្តៅ ហើយទឹកមកហ្នឹងគឺយើងចាក់សោរដោះជើង តែយើងយកច្រវាក់មកដាក់ក-កវិញ ហើយនឹងបណ្តើរឡើងទៅទួល ។

**ស៖** នៅពេលដែលអ្នកទោសគាត់ទទួលរងនូវដែលលង់ទឹកជំនន់ខ្លះៗហ្នឹង គាត់មានឈឺដែលតើ ឬមួយក៏អត់ទេ? អ្នកទោសដែលយើងជួយសង្គ្រោះហើយ ។ តើគាត់មានទទួលការឈឺ ឬក៏គ្រុនញាក់អីដែរ ឬក៏អត់ទេលោកពូ?

**ឆ៖** ចំពោះដែលអ្នកទោសដែលសល់ពីស្លាប់ក្នុងរណ្តៅហ្នឹង គឺបញ្ជូនឡើងទៅលើហ្នឹង ក្រោយមក គឺមានការឈឺស្លាប់ជាបន្តបន្ទាប់ ដោយសារគាត់ភ័យផងមិនដឹង ឬមួយក៏ទឹកឈ្លក់គាត់ ។ ក្នុងពេលនោះគាត់មិនទាន់ស្លាប់ដល់តែពេលយកទៅលើនុ៎ង គឺស្លាប់បន្តៗ ។

**ស៖** ចុះនៅពេលដែលគាត់មានការឈឺ នៅក្នុងពេលដែលគាត់រួចមកពីទឹកជំនន់មក គាត់មានការឈឺ ហើយមានអ្នកខ្លះទៅគាត់-- លោកពូអម្បាញ់មានប្រសាសន៍ថា មិនដឹងថាគាត់ភ័យ ឬក៏យ៉ាងម៉េច? លោកពូអត់ដឹងថា គាត់ស្លាប់ដោយមូលហេតុអីក៏មានការឈឺដែរ ។ ចុះនៅពេលដែលអ្នកទោសគាត់ឈឺនុ៎ង! សួរថាតើមានការព្យាបាលពីគ្រូពេទ្យដូចថា ឲ្យផ្តល់ថ្នាំបន្តិចបន្តួចដើម្បីជួយសង្គ្រោះដល់ជីវិតរបស់ពួកគាត់ដែរឬក៏អត់?

**ឆ៖** គឺបញ្ហាហ្នឹង គឺមានថ្នាំពេទ្យបន្តិចបន្តួចដែរ តែធ្វើម៉េចបើវាអត់ជា ឈឺអ៊ីចឹងទៅ ស្លាប់ទៅ ។

**ស៖** សូមអរគុណលោកពូ ។ ខ្ញុំសូមបន្តសំណួររបស់ខ្ញុំទៀត ។ ទាក់ទងទៅនឹងរណ្តៅ។ ចាប់តាំងពីពេលលោកពូចូលទៅ ម-១៣ លោកពូមានប្រសាសន៍ថា មានរណ្តៅពីរទៅបី តើរយៈពេលក្រោយមកទៀត តើមានការជីករណ្តៅបន្ថែមដើម្បីដាក់អ្នកទោសដែរ ឬមួយក៏យ៉ាងម៉េច?

[១១:២៧:៥៧]

**ឆ៖** សូមបញ្ជាក់ជូន គឺថាពេលដែលទឹកជំនន់លិចហើយ គឺរណ្តៅហ្នឹងត្រូវទឹកហូរចាក់ចូលក្នុងហ្នឹងអស់ ។ ក្រោយមកទៀត គឺដាក់អ្នកទោសនៅលើវិញ ធ្វើរបង ។ របងលួសៗជុំវិញអ៊ីចឹង គឺដាក់អ្នកទោសវិញ ហើយធ្វើដំបូលស្លឹកនៅពីលើវិញ ។

**ស៖** ខ្ញុំសូមសួរលោកពូនៅចំណុចមួយទៀត ទាក់ទងទៅនឹងលោក ឌុច ផ្ទាល់ ។ ទាក់ទងនឹងការសម្រេចសេចក្តីសម្រេចរបស់គាត់ ។ ពាក់ព័ន្ធទៅនឹងការសម្រេចរបស់គាត់ ឧបមាថា ក្នុងករណីដែលថា មានករណីចាំបាច់នៅក្នុងករណីដូចជាអ្នកទោសគាត់ប្រព្រឹត្តអីខុស ឬមួយក៏អ្នកយាមគាត់ប្រព្រឹត្តអីខុស តើលោក ឌុច ហ្នឹង គាត់ជាទូទៅគាត់ជាអ្នកធ្វើសម្រេចភ្លាមៗ ឬមួយក៏គាត់ជាអ្នករង់ចាំការសម្រេចពីថ្នាក់លើសិន? តាមដែលលោកពូធ្លាប់បានឃើញ ។

[១១:២៩:០៣]

**ឆ៖** ចំពោះបញ្ហាហ្នឹង គឺយើងខ្ញុំអត់សូវដឹងទេ ។ បានថាយើងខ្ញុំអត់សូវដឹង គឺមិនដឹងជាគាត់សម្រេចពីលើ មិនជាគាត់សម្រេចខ្លួនគាត់ខ្ញុំអត់ដឹងទេ រឿងហ្នឹង ។

**ស៖** ខ្ញុំចង់សួរថា កន្លងមកដែលលោកពូមានធ្លាប់ជួបប្រទះដូចជាករណី ចាន់ វឿន ករណី ចាន់ វឿន ដែលគាត់ធ្វើខុសដោយដោះលែងហ្នឹង គឺគាត់ធ្វើការដាក់ទណ្ឌកម្មទៅលើ អ្នកយាមរូបនោះ តើតាមដែលពូឃើញស្ថានភាពជាក់ស្តែងនៅក្នុងអំឡុងពេលហ្នឹង តើលោកពូអាចចាំទេថាតើលោក ឌុច គាត់ជាអ្នកដាក់បញ្ជាឲ្យដាក់ទណ្ឌកម្មភ្លាមៗ ឬមួយក៏គាត់រងចាំ គាត់ធ្វើការស្នើសិន? បើតាមស្ថានភាពនៅពេលៗនោះ ។

**ឆ៖** អ៊ីចឹងដូចយើងខ្ញុំបញ្ជាក់ជូនអំមិញ គឺខ្ញុំមិនដឹងទេ ។ មិនដឹងសម្រេចត្រឹមគាត់តា ឌុច ហ្នឹង មិនដឹង ឬមួយថ្នាក់លើមិនដឹង គឺខ្ញុំមិនដឹងទេ ។ រឿងទាំងអស់ហ្នឹង គឺខ្ញុំអត់ដឹងទេ ។

**កញ្ញា ទី ស្រីណា៖**

ខ្ញុំសូមអស់សំណួរលោកចៅក្រម ។ ហើយប្រធានក្រុមៗរបស់ខ្ញុំនឹងគាត់នឹងមានសំណួរមួយចំនួនទៀត ដើម្បីសាកសួរទៅសាក្សីក៏ដូចជាជនជាប់ចោទដោយផ្ទាល់សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ។

**សួរដោយលោក ការីម ខាន៖**

សូមគោរពលោកប្រធាន លោកតុលាការដោយមានការអនុញ្ញាតខ្ញុំមានសំណួរពីរ ឬក៏បីទៅជនជាប់ចោទ ។

**ស៖** លោក ឌុច លោកបានឮហើយពីរបីថ្ងៃចុងក្រោយនេះ ឬក៏ពីមុនហ្នឹងទៅទៀតថា អ្នកទោសត្រូវបានឃុំខ្លួនក្នុងរណ្តៅនៅម-១៣ តើត្រូវទេបញ្ហាហ្នឹង?

[១១:៣១:២០]

**ជនជាប់ចោទ៖**

**ឆ៖** ត្រូវ ។

**ស៖** ពីមុនលោកបាននិយាយថា លក្ខខណ្ឌនៅម-១៣ ជាទូទៅ គឺជាស្ថានភាពអាក្រក់ណាស់ តើត្រូវដែរទេ ចំណុចនេះ?

**ឆ៖** ស្ថានភាពស្អីដែលអាក្រក់?

**ស៖** លក្ខខណ្ឌនៅម-១៣ លោកបាននិយាយពីដំបូងនោះ ពីដើមថានៅពេលដែលលោកនិយាយអំពីមន្ទីរម-១៣ នោះ គឺជាការមួយដែលគួរឲ្យខ្មាសអៀន គឺវាមានលក្ខណៈលំបាកតឹងរ៉ឹងណាស់ដើម្បីឲ្យគេរស់នៅបាននៅទីនោះ តើត្រូវទេថ្លែងការណ៍នោះ?

**ឆ៖** ម-១៣ វាជាគុករបស់ខ្មែរក្រហម វាមិនមែនគ្រាន់តែលំបាកទេ វាឃោរឃៅព្រៃផ្សៃ ។ វាជាកម្ទេចនៃមនុស្សធម៌ នៃមនុស្សជាតិ ។ ដូច្នេះ និយាយពីលំបាក វាមិនមែនលំបាកទេ វាលើសពីលំបាកទៅទៀត វាឃោរឃៅៗ នេះសូមបញ្ជាក់ឲ្យច្បាស់ ។

[១១:៣៣:០០]

**ស៖** ហើយប្រសិនបើលោកនិយាយថាជាការកម្ទេចនៅម-១៣ តើថារណ្តៅទាំងនោះដែលលោកបានប្រើ តើលោកជីកជារណ្តៅហ្នឹង ដើម្បីគោលបំណងអីនៅជម្រៅប៉ុនណានោះ?

**ឆ៖** រឿងគោលបំណងនេះ ខ្ញុំបានបញ្ជាក់ច្រើនដងហើយ ឥឡូវខ្ញុំសូមបញ្ជាក់ម្តងទៀត ពីព្រោះថ្ងៃនេះខ្ញុំទើបនឹងឃើញលោកអញ្ជើញមកថ្មី ។ ការជីករណ្តៅទៅក្រោមនេះ វាមានគោលបំណងពីរយ៉ាងតិច ។ ទី១ គឺដើម្បីការពារជនរងគ្រោះដែលទៅជាប់ទោសនៅទីនោះកុំឲ្យរត់រួច ។ កម្ពស់ពីរម៉ែត្រលោកគិតទៅ ស្រួលហើយគ្នានៅជាប់ដើងស្រាប់ អត់បាយស៊ី សុខភាពខ្សោយស្រាប់ គ្នារត់មិនរួចទេ ។ ទី២ទៀត ពីដើមមកយើងខ្ញុំអត់បានគិតគូរជីករណ្តៅទេ ទើបនឹងសម័យ អាបេ៥២ វាចាក់ហ្នឹង បានគិតគូរជីករណ្តៅដើម្បីការពារ ។ ធម្មតាទេ ខ្មែរក្រហមវាអត់មានស្អីការពារឲ្យធំដុំទេ ។ រណ្តៅ--

**ស៖** លោកសាក្សី ហើយលោក ឌុច ខ្ញុំសូមអត់ទោសចំពោះការសុំកាត់ ខ្ញុំបានអានប្រតិចារឹកហើយខ្ញុំបានឃើញភស្តុតាងហើយអ្វីដែលខ្ញុំសួរនោះ ប្រសិនបើលក្ខខណ្ឌនៅក្នុងម-១៣ នោះ ជាទូទៅគឺជាឃោរឃៅហើយមានការលំបាកខ្លាំង តើត្រូវទេដែលនិយាយថាលក្ខខណ្ឌនៅក្នុងរណ្តៅដែលគេជីក

ទៅដីនោះ? ជាពិសេសលក្ខណៈឃោរឃៅ ហើយជាពិសេសលំបាកពិសេស រឹតតែអាក្រក់ទៅទៀត តើត្រូវទេអ៊ីចឹង?

[១១:៣៤:៥១]

**ឆ៖** អាក្រក់នោះវាសព្វមុខហើយ ។ បើនិយាយពីរឿងអាក្រក់ហ្នឹងវា១ច្បាស់ហើយ វាមិនមែនជាកន្លែងសាលារៀនទេ គឺជាគុកខ្មែរក្រហម ។

**ស៖** ថាតើត្រូវឬទេ? បើសិនជាអ្នកដែលជាប់ឃុំនៅក្នុងរណ្តៅនេះនៅក្នុងឆ្នាំ១៩៧៤ តើលោកឯកភាពថា អ៊ីចឹងទេ?

**ឆ៖** សូមទោស សូមលោកប្រសាសន៍ មានប្រសាសន៍ម្តងទៀត ។

**ស៖** សំណួរ ។ ទោះបីជានៅក្នុងឆ្នាំ១៩៧៤ អ្នកទោសត្រូវបានឃុំនៅក្នុងរណ្តៅទាំងនុំង តើត្រូវឬទេ?

**ឆ៖** ត្រូវ ។

**ស៖** ហើយលោកបានដឹងយ៉ាងច្បាស់ទេ? ឬក៏មិនច្បាស់ទេថា ការទម្លាក់គ្រាប់បែកពីលើអាកាសរបស់បារាំងគឺថាបានបញ្ចប់ក្នុងខែសីហា ឆ្នាំ១៩៧៣ តើពិតដែរឬទេ?

**ឆ៖** ៧៣ ឬ៧៤?

[១១:៣៦:០៥]

**ស៖** ខ្ញុំនឹងបញ្ជាក់សំណួរឡើងវិញ លោកបានដឹងច្បាស់ថា អំពីការទម្លាប់គ្រាប់បែករបស់អាមេរិកកាំងហ្នឹង គឺថាបានបញ្ចប់នៅខែសីហា ឆ្នាំ១៩៧៣ ថាតើពិតអ៊ីចឹងទេ? ការពិតហ្នឹងវាចប់អ៊ីចឹងមែន ឬអត់?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ថ្ងៃខែខ្ញុំអត់ច្បាស់ជាមួយទេ ។ ខ្ញុំអត់ចូលដៃទេ ៧៣ ឬ៧៤ ខ្ញុំអត់ទៀតចូលដៃទេ ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា ចាប់ពីអាបេ៥២ អា *អេហ្វ*១៨ ឬ *អេហ្វ*១៦ ទៅទម្លាក់សមរភូមិហើយជាទូទៅមុន អាបេ៥២ ហ្នឹង វាមានអា*ស្កេរ៉ាឌ័រ* ដែលគេហៅថា *ស្កេរ៉ាឌ័រ* ហ្នឹងវាហោះទម្លាក់តាមភូមិឃុំ ។ ដូច្នេះ *បេ*៥២ វាផ្សេង អាពួក *អេហ្វ* ផ្សេងវាផ្សេង ហើយអាពួក *ស្កេរ៉ាឌ័រ* វាទៅទម្លាក់តាមភូមិឃុំវាផ្សេង វាទៅទម្លាក់*ណាប៉ាល់* វាទម្លាក់គ្រាប់ធម្មតា ។ ដូច្នេះ រហូតដល់ថ្ងៃ១៧ មេសា បាន១វាចប់ការទម្លាប់គ្រាប់បែករបស់អាមេរិក ។

[១១:៣៧:២៩]

**ស៖** សំណួរ ខ្ញុំសូមនិយាយឲ្យបានច្បាស់ ដើម្បីកុំឲ្យច្រឡំគ្នា ច្របូកច្របល់ ។ លោក ឌុច លោកបានដាក់អ្នកទោសនៅក្នុងរណ្ដៅហ្នឹង គឺថាក្រោយពេលដែលគ្រប់បែកទម្លាក់ដោយអាមេរិកកាំង ត្រូវបានបញ្ចប់ ប៉ុន្តែនៅតែរក្សាឃុំអ្នកទោសតទៅទៀតដែរឬទេ?

**ឆ៖** វាផុតអាបេ៥២ ហ្នឹងលោក ខាន ផុតអា*បេ*៥២ វានៅមានអាទៅទម្លាក់អីក្រោយសមរភូមិក្រោយនោះ អាពួកអា*ស្កេរ៉ាយ៉័រ* ទម្លាក់គ្រប់បែកយើងធម្មតាទេ ។

**ស៖** សំណួរ ខ្ញុំសូមសួរតទៅទៀត មូលហេតុដែលលោកបានដឹងពីរឿងហ្នឹង ។ ដើម្បីដាក់អ្នកទោសនៅក្នុងរណ្ដៅដើម្បីការពារ ដើម្បីលាក់នូវការពិត ដែលថាលោកដាក់អ្នកទោសនៅក្នុងរណ្ដៅ ។ ដោយបានដឹងយ៉ាងច្បាស់ថា គឺកុំឲ្យអ្នកទោសរត់រួចបាន ហើយបន្ថែមគឺដើម្បីជាការដាក់ឲ្យនៅក្នុងស្ថានភាពលំបាកឃោរឃៅជាទម្ងន់ថែមទៀត ឬក៏យ៉ាងដូចម្ដេច?

**ឆ៖** អាហ្នឹងៗ វាជាបច្ច័យទេលោក ខាន់ ។ បច្ច័យវាជាផលវិបាក។ ភាសាខ្មែរខ្លះគេហៅ ផលវិបាកទេ ។ អាកាន់តែលំបាកថែមទៀត អាហ្នឹងផលវិបាកទេ តែបំណងរបស់ខ្ញុំមានពីរ។ ទីមួយការពារកុំឲ្យអ្នកទោសស្រួលរត់ព្រោះយើងខ្ញុំគ្មានជញ្ជាំងថ្មទេ ។ ទីពីរទៀត គឺដើម្បីជីករណ្ដៅការពារគ្រប់បែក បើគ្រប់បែទម្លាក់មកចំអារណ្ដៅវាងាប់ទាំងអស់គ្នាហើយ ។ បើទម្លាក់ចំរណ្ដៅខ្ញុំដែលខ្ញុំដេកហ្នឹង វាងាប់ខ្ញុំ បើទម្លាក់ចំរណ្ដៅអ្នកទោសវាងាប់អ្នកទោស ក៏ប៉ុន្តែបើវាទម្លាក់ខុសថា ប្រាំម៉ែត្ររស់។ តែប្រាំម៉ែត្រពីមាត់រណ្ដៅអាគ្រប់បែកធម្មតានេះ រស់ ។ បើអាបេ៥២ មិនបានទេទាល់តែ៥០ម៉ែត្រ ។ ចម្ងាយពីនុំងបានៗនេះ ប៉ុន្តែ ខ្ទីរហ៊ឹងត្រចៀក ខូចក្រដាសត្រចៀកឥឡូវហ្នឹង ។ ដូច្នេះ អារឿងធ្វើឲ្យអ្នកទោសកាន់តែលំបាកវាមានពិត ក៏ប៉ុន្តែអាហ្នឹងវាជា *កុងសេកង់ប្រាទិក* បារាំងហៅថា “*កុងសេកង់ប្រាទិក*” ហៅថា “បច្ច័យដែលកើតមកពីការអនុវត្ត” មិនមែនជា “វត្ថុបំណង” របស់ខ្ញុំទេ ។

[១១:៥០:00]

**ស៖** តាមពិតលោកបានដឹងសក្ខីកម្មពីខាងដើមហើយថា នៅក្នុងឆ្នាំ១៩៧៤ គឺថាមានអ្នកទោសលង់ទឹកស្លាប់ ដោយសារមានទឹកជំនន់ ។ តើហេតុការណ៍នឹងពិតដែរ ឬទេ?

**លោក ហ្វេង់ស្វ័រ រូ៖**

លោកប្រធាន ខ្ញុំចង់បញ្ជាក់ពីអ្វីដែលខ្ញុំបាននិយាយពីខាងដើម ហើយសូមអញ្ជើញឲ្យលោកមេធាវីសួរសំណួរឲ្យបានគួរសមជាងធម្មតា។ គឺថានេះមិនមែនជាទីលានប្រដាល់ទេ ជាកន្លែងសាលសវនាការ។ លោកប្រធានខ្ញុំមិនបានពាក់ហ្គង់នៅនឹងដៃនឹងនោះទេ ។

**លោក ការីម ខាន៖**

**ស៖** ខ្ញុំរីករាយ ខ្ញុំនឹងចោទសួរជាថ្មីម្ដងទៀត គឺថាដើម្បីឲ្យៗ--

**លោក ហ្វ្រង់ស្វ័រ រូ៖**

សុំលោកមេធាវីរង់ចាំ ការបង្គាប់ពីលោកប្រធានសិន។ ខ្ញុំសូមស្នើឲ្យលោកប្រធានដើម្បីបង្គាប់--ឲ្យលោកមានការគោរពបន្តិច ដូច្នេះសូមលោកយល់អំពីបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

សំខាន់ឥឡូវហ្នឹង យើងរំឭកឡើងវិញដោយបញ្ហាការកត់សម្គាល់ក៏ដូច្នោះដែរ ដោយអង្គជម្រះបានថ្លឹងថ្លែងរវាងសេរីភាពក្នុងការសួរដេញដោយ ហើយក៏មានការកត់សម្គាល់នូវបញ្ហាការសួរ ។ ទី១ គឺច្រំដែលនូវសំណួរ ឬក៏បញ្ហាតែមួយសួរវិលចុះវិលឡើង ដោយមូលហេតុមានការផ្លាស់ប្ដូរមនុស្សដែលក្ដាប់នូវអ្វីដែលបានសួររួចហើយមិនបាន។ អ៊ីចឹងហើយបានជាមានការសួរច្រំដែល ។ ហើយមួយទៀតគឺសំណួរ ដោយមានហេតុផលពីរ ទីមួយគឺសំណួរវែងដែលនាំឲ្យឆ្លងការបកប្រែទៅ វាបាត់នូវពាក្យមួយចំនួន នាំឲ្យខ្លឹមសារនៃសំណួរហ្នឹងដល់អ្នកស្ដាប់ដើម្បីឆ្លើយ ស្ដាប់អត់យល់ទេ ។ អ៊ីចឹង ខ្ញុំក្នុងនាមអង្គជំនុំជម្រះសូមណែនាំថា ទីមួយគឺប្រឹងប្រែងបញ្ចៀសនូវសំណួរច្រំដែល ឬក៏សួរបញ្ហាដដែលដែលនាំឲ្យការអូសបន្លាយនៃដំណើរការសវនាការ ។ ទីពីរគឺសូមសួរឲ្យបានច្បាស់ ហើយខ្លីសមល្មម ដើម្បីឲ្យមានការបកប្រែទៅ គឺបានច្បាស់លាស់ដែលអាចឆ្លើយឲ្យបានច្បាស់លាស់ ។ សូមអញ្ជើញបន្ត ។

[១១:៤៣:០២]

**សួរដោយលោក ការីម ខាន៖**

សូមអរគុណលោកប្រធាន ។ ដែលខ្ញុំនឹងគោរពតាមការបង្គាប់នេះ ហើយខ្ញុំនឹងមិនសួរឡើងវិញទេ គឺនិយាយពីរឿងខ្លឹមសារ ។ ខ្ញុំសូមបញ្ជាក់ថា ទម្រង់ត្រឹមត្រូវនៅពេលមានការជំទាស់ ហើយមុននឹងមានសេចក្ដីសម្រេច ភាគីត្រូវមានសិទ្ធិឆ្លើយតបសិនដែរ ។ អ៊ីចឹងហើយ ខ្ញុំសូមអនុញ្ញាតបន្តសួរ ដោយមានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ខ្ញុំនឹងសួរតទៅទៀត លោក ឌុច ។

**ស៖** អ៊ីចឹងហើយ គឺមូលហេតុដែលថា លោកៗបានដឹងច្រើនអំពីរឿងទាំងអស់នេះ ដែលថាបានដាក់អ្នកទោសនៅក្នុងរណ្ដៅដោយមិនមានការការពារនោះ ។ អ៊ីចឹង មិនមែនជាការប៉ុនប៉ងដើម្បីសម្រាលអំពើរបស់លោក ដើម្បីដាក់អ្នកទោសនៅក្នុងស្ថានភាពមួយដ៏អាក្រក់ ដែលថាមានជាប់ខ្នោះនៅក្នុងរណ្ដៅ ។ តើលោកឯកភាពទៅលើការវាយតម្លៃបែបនោះទេ?

**ឆ៖** ខ្ញុំសូមនិយាយយ៉ាងខ្លី ។ ពាក្យនេះមិនដឹងជានិយាយប៉ុន្មានរយដងហើយទេ ។ ប៉ុន្តែ ដោយលោកទើបអញ្ជើញមកថ្ងៃនេះ ខ្ញុំសូមនិយាយម្តងទៀត ។ អ្នកទោសនៅក្នុងរណ្តៅពិតជាមានដាក់ខ្នោះ ។ នេះខ្ញុំសូមឆ្លើយតែប៉ុណ្ណឹង ។

**លោក ការីម ខាន៖**

លោកចៅក្រមខ្ញុំមិនមានសំណួរអ្វីទៀតទេ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីក្រុមពីរ ។ បើមានសំណួរសូមអញ្ជើញ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

**ស៖** អរគុណលោកប្រធាន លោក លោកស្រី ចៅក្រមជាទីគោរព ។ អារុណសួស្តីលោក ចាន់ ខន ឈ្មោះរបស់ខ្ញុំគឺ ស្ទូតហ្សីនស្គី ខ្ញុំជាមេធាវីតំណាងឲ្យជនរងគ្រោះ ។ ខ្ញុំអាចសង្កេតឃើញថា សវនាការព្រឹកនេះ លោកចាប់ផ្តើមនិយាយនិងរៀបរាប់ច្រើនជាងកាលពីម្សិលមិញ ហើយខ្ញុំសង្ឃឹមថាលោកមានអារម្មណ៍រៀងធូរស្បើយបន្តិចនៅក្នុងថ្ងៃនេះ ។ តើខ្ញុំនិយាយហ្នឹងត្រឹមត្រូវដែរ ឬទេថាលោកមានអារម្មណ៍រៀងធូរជាងការផ្តល់សក្ខីកម្មពីម្សិលមិញ តើត្រឹមត្រូវដែរឬទេ?

**សាក្សី KW-32៖**

**ឆ៖** គឺតាមខ្ញុំដឹងគឺធូរជាងម្សិលមិញពិត ព្រោះម្សិលមិញក្នុងអារម្មណ៍គឺច្របូកច្របល់ណាស់។

**ស៖** អរគុណ ។ ហើយខ្ញុំសង្ឃឹមថា លោកអាចចូលរួមក្នុងការជួយលោក លោកស្រីចៅក្រមស្វែងរកការពិត ។ លោកបានប្រាប់យើងកាលពីម្សិលមិញថា ឌុច, ចាន់, មាស, ផល គឺជាអ្នកសួរចម្លើយ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សំណួរទាំងនេះ គឺពិតជាត្រឹមត្រូវ ។

**ស៖** ថាតើអ្នកទាំងអស់នោះមានទីកន្លែងខុសៗគ្នាទេ នៅពេលដែលពួកគេសួរចម្លើយ តើអ្នកសួរទាំងអស់នោះ គាត់មានកន្លែងសួរខុសៗគ្នាដែរឬទេ?

**ឆ៖** ចំពោះបញ្ហាសួរចម្លើយអ្នកទោសនោះ គឺមានកន្លែង ពីរកន្លែងខុសគ្នា ។ គឺកន្លែង តាឌុច គាត់សួរផ្សេងទៅ កន្លែងអ្នកដទៃទៀត គេសួរផ្សេងទៀតទៅ ។

**ស៖** ថាតើលោកអាចប្រាប់អំពីកន្លែងខុសគ្នាដែលការសួរចម្លើយនោះបានធ្វើឡើងដែរឬទេ? សូមឲ្យលោកជួយបញ្ជាក់កន្លែងខុសៗគ្នានោះ?

**ឆ៖** ដូចខ្ញុំប្រាប់ជម្រាបជូនមិញអ៊ីចឹង កន្លែងវាខុសគ្នា ។ កន្លែង តាឌុច ផ្សេងទៅ កន្លែងដែលចាន់, តាមាស អីទៅ គេផ្សេងៗគ្នា គេការសួរផ្សេងពីគ្នាអ៊ីចឹងទៅ គឺមិនបានសួរទៅច្របូកច្របល់ជាមួយគ្នាទេ ។

**ស៖** ថាតើលោកអាចទៅកៀកនឹងកន្លែងសួរចម្លើយហ្នឹង កៀកប៉ុន្មានដែរ លោកអាចចូលទៅដល់ត្រឹមណាដែរ កៀកនឹងកន្លែងហ្នឹង ។

**ឆ៖** បញ្ហាហ្នឹងអត់ដែលទៅទេ ។ គឺយើងខ្ញុំនៅតែកន្លែង ។

**ស៖** ថាតើកន្លែងដែលសួរចម្លើយនោះ វាត្រូវបានបិទបាំងដែលធ្វើឱ្យលោកមិនអាចមើលឃើញដែរឬទេ? តើកន្លែងសួរចម្លើយមានការបិទបាំង ដើម្បីមិនឱ្យលោកមើលឃើញដែរឬទេ? ឬក៏យើងអាចមើលឃើញស្ថានភាពនៃការសួរចម្លើយនៅកន្លែងនោះ?

**ឆ៖** កន្លែងសួរចម្លើយនោះ គឺធ្វើរោងតូចៗហើយឆ្ងាយ គឺមានការបិទបាំងអ៊ីចឹង ទុកតែមាត់ច្រកអ៊ីចឹងទៅ គឺនៅឆ្ងាយពីកន្លែងមន្ទីរឃុំឃាំង ។ ដូចខ្ញុំជម្រាបពីមុនអ៊ីចឹង គឺខាងជើងត្រពាំងច្រាបទៅទៀត ។

**ស៖** ខ្ញុំអាចចូលទៅដល់ចំណុចមួយទៀត ។ លោកនិយាយអំពីរណ្ដៅខុសៗគ្នា ហើយនិងរណ្ដៅដែលគេឃុំអ្នកទោស ហើយនិងរណ្ដៅដែលមានសាកសព ។ តើលោកអាចជម្រាបខ្ញុំដែរ ឬទេអំពីរណ្ដៅខុសៗគ្នា ដែលរណ្ដៅមួយចំនួនសម្រាប់ឃុំអ្នកទោស និងរណ្ដៅមួយចំនួនទៀតសម្រាប់ដាក់សាកសព ។ តើលោកអាចជម្រាបអំពីភាពខុសគ្នានៃរណ្ដៅនោះដែរឬទេ? ថាតើមានរណ្ដៅដែលគេដាក់អ្នកសពចំនួនប៉ុន្មានដែលលោកបានឃើញក្នុងពេលដែលលោកធ្វើនៅម-១៣?

[១១:៥១:៤៣]

**ឆ៖** ចំពោះបញ្ហារណ្ដៅកប់សព គឺខ្ញុំអត់ដែលឃើញទេ បើរណ្ដៅដាក់ជាអ្នកទោសរស់ហ្នឹង ដូចខ្ញុំជម្រាបដដែលទៀត គឺខ្ញុំឃើញ ។

**ស៖** តើលោកដែលឃើញសាកសពនៅម-១៣ ដែរឬទេ?

**ឆ៖** ចំពោះសាកសពនៅមន្ទីរ១៣ គឺស្លាប់ដោយសារអត់បាយដូចខ្ញុំជម្រាបជូនម្សិលមិញអ៊ីចឹង ដូចលិចទឹកជំនន់អីហ្នឹង គឺឃើញនូវនឹងភ្នែកជាក់ស្ដែង ។

**ស៖** ថាតើលោកបានឃើញការសម្លាប់មនុស្សដែរឬទេ?

**ឆ៖** ដូចខ្ញុំជម្រាបជូនអ៊ីចឹងពីមុនរួចម្តងហើយ គឺថាបញ្ជាក់កន្លែងសម្លាប់មនុស្សដូចខ្ញុំថា មានគោលការណ៍លាក់ការណ៍ច្បាស់គឺមិនអាចដឹងទេ ដូចខ្ញុំជម្រាបជូនអង្គតុលាការអ៊ីចឹងថា តាឌុច គាត់បានណែនាំរឿងការលាក់ការណ៍ហ្នឹង គឺមិនអាចដឹងទេ ។ ព្រោះកន្លែងសម្លាប់ហ្នឹងគេលាក់ការណ៍មិនចេះឲ្យដឹងតែគ្រប់តែគ្នាទេ ។

**ស៖** តើលោកមានឮស្នូរបាញ់ដែរ ឬទេនៅម-១៣ ស្នូរបាញ់កាំភ្លើង ។

**ឆ៖** ចំពោះបញ្ហានៅមន្ទីរ១៣ គឺធ្លាប់ឮ ពេលអ្នកទោសរត់ ឬមួយក៏គេចងអ្នកទោសនៅជាប់នឹងសសរបាញ់ចោល គំរាមដល់អ្នកដទៃទៀតឲ្យខ្លាច ។ អាហ្នឹង គឺធ្លាប់ឃើញ ។

**ស៖** អ្វីដែលខ្ញុំយល់នោះ គឺថាលោកបានឃើញការបាញ់ ហើយនិងឮសំឡេងបាញ់កាំភ្លើងនោះ?

**ឆ៖** ថាម៉េច? សូមបញ្ជាក់មួយលើកទៀត ។

**ស៖** ខ្ញុំសូមឲ្យលោកបំភ្លឺ ថាតើខ្ញុំយល់នូវចម្លើយលោកត្រឹមត្រូវដែរឬទេ ដែលថាលោកបាននិយាយថា លោកបានឮការបាញ់សំឡេងកាំភ្លើង ហើយនិងបានឃើញការបាញ់កាំភ្លើង?

**ឆ៖** ដូចខ្ញុំជម្រាបជូនអំមិញអ៊ីចឹងគឺថា កន្លែងដែលមានបង្គោលនៅក្នុងគុកហ្នឹងគឺគេចងបាញ់អ្នកទោសហ្នឹង ឮស្នូរបាញ់ហ្នឹងមែនពិត ។

**ស៖** តើលោកមានអារម្មណ៍យ៉ាងម៉េច នៅពេលដែលលោកបានឮស្នូរស្នូរកាំភ្លើងបាញ់នោះដែលថា សំឡេងឮខ្លាំងអ៊ីចឹងលោកមានអារម្មណ៍ម៉េចដែរនៅពេលនោះ?

**ឆ៖** ចំពោះបញ្ហាសតិអារម្មណ៍វិញគឺ ភ័យព្រួយមិនដឹងជាងាប់ចំអ្នកណា រស់ចំអ្នកណាសំខាន់គឺដូចខ្ញុំជម្រាបដដែលៗ អ៊ីចឹងគឺមានជីដូនជីតាអីរស់នៅក្នុងហ្នឹង ។

**ស៖** តើលោកអាចប្រាប់យើងបានទេថាការបាញ់កើតឡើងជារៀងរាល់ថ្ងៃទេ នៅម-១៣ នោះ?

**ឆ៖** ចំពោះបញ្ហាហ្នឹងវាមិនមែនរៀងរាល់ថ្ងៃទេ ។ គឺវាមានដោយថ្ងៃអ៊ីចឹងទៅ ។

**ស៖** តើលោកបានឃើញជនជាប់ចោទនៅម-១៣ ជាមួយនឹងអ្នកផ្សេងទៀតដែលថាមានកាន់អាវុធ ដូចជា អាកា៥៧ ឬក៏អាវុធខ្លីអីទេ? ឬក៏អាវុធប្រភេទណាទេនៅក្នុងដៃរបស់គេទេ?

**ឆ៖** បញ្ជាក់ជូនមួយលើកទៀត ជនជាប់ចោទហ្នឹងគឺ អ្នកដែលជាប់នៅមន្ទីរ-១៣ ឬមួយតាឌុច ហ្នឹង? បញ្ជាក់ជូនខ្ញុំឲ្យច្បាស់ ព្រោះខ្ញុំមិនសូវច្បាស់អាត្រង់ហ្នឹង?

**ស៖** និយាយពីរឿង ឌុច?

**ឆ៖** គឺចំពោះ តាឌុច ហ្នឹងគឺគាត់មានអាវុធខ្លីពិតប្រាកដ ។ តែចំពោះរូបគាត់ហ្នឹងមិនដឹងជាមានប៉ុន្មានដើមៗ គឺអត់ដឹងទេ ។ ប៉ុនឃើញគាត់មានពិតប្រាកដ ។

**ស៖** តើលោកបានឃើញថា គាត់ប្រើអាវុធនេះដែរឬទេ?

**ឆ៖** អាវុធខ្លីហ្នឹង គឺគាត់អ្នកប្រើខ្លួនគាត់ហ្នឹង គ្មានបងប្អូនកងការពារណាប៉ះរបស់គាត់គឺអាវុធផ្ទាល់ខ្លួនរបស់គាត់ ។

**ស៖** ខ្ញុំសួរឡើងវិញប្រហែលជាមានការច្រឡំបន្តិច ខ្ញុំសួរថាតើលោកបានឃើញ ឌុច បានប្រើកាំភ្លើងដើម្បីបាញ់ តើគាត់ប្រើធម្មតាបាញ់ ឬក៏តើលោកឃើញថាគាត់ប្រើកាំភ្លើង ដើម្បីបាញ់ទៅលើអ្នកណាម្នាក់ដែរឬទេ កាលណោះ?

**ឆ៖** ចំពោះបញ្ហា តាឌុច គឺខ្ញុំមិនដែលឃើញគាត់បាញ់ផ្ទាល់ដៃទេ ។ ព្រោះគឺមានភារកិច្ចផ្សេងៗក្រែងលោថ្ងៃខ្ញុំមិននៅអីទៅគាត់បាញ់អី គឺខ្ញុំអត់ដឹងទេ ប៉ុនដែលខ្ញុំនៅយាមក្នុងបរិវេណហ្នឹងគឺអត់ដែលឃើញគាត់បាញ់មនុស្សផ្ទាល់ដៃទេ ។ តែបើគាត់បញ្ជាគេឲ្យបាញ់គឺមាន ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានសូមការអនុញ្ញាត ខ្ញុំសូមផ្តល់មតិមួយចំនួនទាក់ទងនឹងសំណួរចុងក្រោយដែលបានសួរនោះ ។ លោកសហព្រះរាជអាជ្ញា អេឡិចហ្សាប៊េត បានសួរកន្លងទៅហើយដែលសួរថា តើលោកបានឃើញ ឌុច កាន់កាំភ្លើងខ្លីនៅក្នុងដៃដែរឬទេ?

ចម្លើយ ខ្ញុំបានឃើញគាត់ដកចេញពីចង្កេះ ហើយដាក់នៅ លើតុ ហើយគាត់ហូបបាយ ។

សំណួរតទៅទៀត...

ដូច្នេះ ប្រសិនបើជៀសវាងកុំឲ្យសួរសំណួរដដែលម្តងហើយម្តងទៀត ។

**លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

ខ្ញុំមិននិយាយអំពីកាំភ្លើងខ្លីទេ ខ្ញុំនិយាយអំពីកាំភ្លើង អាកា៤៧ ជាកាំភ្លើងវែងដែលខ្ញុំដឹងថា វាមានភាពខុសគ្នាតាមពិតរវាងអាវុធខ្លី ហើយនិងអាវុធវែងហ្នឹង គឺសំណួរនោះសួរពីសហព្រះរាជអាជ្ញានោះគឺសួរអំពីទាក់ទងទៅនឹងអាវុធខ្លីទេ *ពីស្តូល* នោះអាវុធខ្លី ប៉ុន្តែខ្ញុំជូនជាឧទាហរណ៍មួយនៅពេលដែលខ្ញុំនិយាយអំពីកាំភ្លើងនោះ ជាអាវុធវែងគឺ អាកា៤៧ ប្រហែលជាការបកប្រែនោះខុសក៏មិនដឹង ។

**ប្រធានអង្គជំនុំ៖**

អាចបន្តបានដោយសារសំណួរខុសគ្នា សំណួរមួយមានអារុធ មួយមានបំពាក់ដោយអារុធមួយទៀត ការប្រើប្រាស់អារុធ បានន័យថា ការប្រើប្រាស់អារុធក្នុងការប្រព្រឹត្តបាញ់ជាក់ស្តែង វាអាចខុសគ្នា ។ អ៊ីចឹង សូមបន្តទៅទៀតចុះ ។ មេធាវីអាចបន្តទៀត ។ សូមការកត់សម្គាល់ឃើញថា គួរតែត្រូវបានស្វែងយល់ផងដែរអំពីកម្រិតអំពីការយល់ដឹងរបស់សាក្សី ពីព្រោះសាក្សីអត់ចេះអក្សរទេ ។ អ៊ីចឹង ការប្រើពាក្យពេចន៍ក្នុងការ ដែលនិយាយទៅកាន់គាត់ហ្នឹងគួរតែប្រើពាក្យដែលងាយដើម្បីឲ្យគាត់បានយល់អំពីអ្វីដែលជាអ្នកច្បាប់ហ្នឹង និយាយជាមួយគាត់ក្នុងនាមកម្រិតគាត់ ដែលមានការយល់ដឹង ការរៀនសូត្រតិចតួច ។ ដូច្នេះ ប្រសិនបើយើងសួរមានសំណួរវែង ឬក៏សំណួរដែលប្រើពាក្យលំបាកនោះ វាការស្តាប់ឆ្លងកាត់ការបកប្រែមួយទៀតនោះ គឺវាកាន់តែនាំឲ្យលំបាកស្មុគស្មាញទៀត ។

[១២:០២:៤២]

**សួរដោយលោកស្រី ស៊ីលឃី ស្នួតហ្សីនស្គី៖**

**ស៖** សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតសួរមុនពេលសម្រាកពិសារអាហារថ្ងៃត្រង់អំពីសំណួរមួយ តើលោក ចាន់ ខន តើលោកមានអារម្មណ៍ស្រួលទេ ក្នុងការសួរសំណួរមួយចំនួនដោយមិនមានវត្តមានរបស់ជនជាប់ចោទទេ? ដែលថាលោក ខន លោកគិតថា បើអវត្តមានរបស់លោកជនជាប់ ចោទ លោកអាចមានអារម្មណ៍ធូរស្រាលក្នុងការឆ្លើយឬទេ?

**សាក្សី KW-32៖**

**ឆ៖** ទោះបីជនជាប់ចោទនៅហ្នឹងក៏ខ្ញុំឆ្លើយតែម៉ាខ្ញុំដឹងឮ មិននៅក៏ខ្ញុំឆ្លើយតែប៉ុណ្ណឹង ឲ្យតែសំណួរសួរមកចំចំណុចដែលខ្ញុំដឹង គឺខ្ញុំឆ្លើយ។ បើសំណួរសួរមកចំចំណុចដែលខ្ញុំអត់ដឹង ក៏ខ្ញុំអត់អាចឆ្លើយកើត ។

**លោកស្រី ស៊ីលឃី ស្នួតហ្សីនស្គី៖**

ឥឡូវនេះ ខ្ញុំសូមចូលទៅដល់បញ្ហាមួយទៀត ប្រហែលជាលោកប្រធានអាចជាដល់ពេលយើងត្រូវសម្រាកសិន ឬក៏ដូចម្តេច?

**ប្រធានអង្គជំនុំ៖**

នោះមានន័យថា មាននីតិវិធី ទោះបីបន្តទៀតក៏នៅតែត្រូវតែបន្តសួរសាក្សីនេះនៅពេលរសៀលដែរ ។ អ៊ីចឹង ដល់ពេលម៉ោងត្រូវសម្រាកអាហារថ្ងៃត្រង់ហើយ ។ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ រហូតដល់ម៉ោងមួយកន្លះ ចាប់បន្តដំណើរការសវនាការបន្តទៅទៀត ។

ហើយ អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់បន្ទប់សម្រាក ។ ហើយឲ្យនាំគាត់មកវិញឲ្យបានមុនម៉ោងមួយកន្លះ នៅរសៀលនេះ។ ហើយមន្ត្រីតុលាការសូមអញ្ជើញសាក្សីទៅកាន់បន្ទប់រង់ចាំហើយធ្វើកិច្ចការឲ្យបានល្អដោយគោរពគោលការណ៍កុំឲ្យមានគាត់មានការប្រាស្រ័យទាក់ទង ហើយមានការពិភាក្សាពាក់ព័ន្ធ ជាមួយនឹងអង្គហេតុដែលកំពុងតែធ្វើសវនាការនេះ រហូតដល់ដំណើរការសវនាការសេក្តីកម្មបានចប់ ។ ហើយឲ្យនាំគាត់មកវិញឲ្យបានមុនម៉ោងមួយកន្លះរសៀល ។

*សវនាការសម្រាកពីម៉ោង ១២:០៦នាទីដល់ម៉ោង១៣:៣៣ នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចពិភាក្សាដេញដោលតទៅទៀត ហើយជាកិច្ចបន្តនេះសូមអញ្ជើញមេធាវីក្រុម២ ឡើងបន្តសួរនូវសំណួរផ្សេងៗដល់សាក្សីរូបនេះ ។

**សួរដោយលោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោក ចាន់ ខន តើលោកចងចាំទេថា មានមនុស្សពីរនាក់ ដែលបានធ្វើសម្ភាសជាមួយលោកប្រហែលជា៦ឆ្នាំមកហើយ អំពីអ្វីដែលលោកបានឆ្លងកាត់នៅក្នុងមន្ទីរម-១៣នោះ ។ តើលោកនៅចាំទេ?

**សាក្សី KW-32៖**

**ឆ៖** អត់បានចាំផង ភ្លេចអស់ហើយ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗ លោកហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើយើងអាចដឹងឲ្យបានច្បាស់នោះ តើឯកសារណាដែលលោកស្រីមេធាវីយោងទៅរក ខ្ញុំគិតថា យើងចង្អុលបង្ហាញអង្គជំនុំជម្រះ គឺចាប់អារម្មណ៍តែឯកសារ ដែលចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ីចឹង សូមឲ្យមេធាវីបញ្ជាក់លេខឯកសារយោងហ្នឹងផង ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី៖**

ចាំ គឺជាឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុនតាមដែលខ្ញុំយល់គឺអង្គជំនុំជម្រះមិនបានលើកយកមកប្រើជាការចោទសួរខ្លះហើយ ។ ខ្ញុំសូមអនុញ្ញាតបញ្ចប់។ តើសំណួរហ្នឹងនៅរង់ចាំបន្តទៅទៀតទាក់ទង--

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

មុននឹងចាប់ផ្តើម យើងត្រូវតែយល់ឲ្យច្បាស់ថា អង្គជំនុំជម្រះលើកឡើងជួបប្រទះនឹងការលំបាកមួយចំនួនទាក់ទងទៅនឹងឯកសារ ដែលបានមកពីមជ្ឈមណ្ឌលឯកសារដែលបានចែងច្បាស់ ដោយយើងមិនចង់យោងទៅរកឯកសារនោះទេ ។ ដូច្នេះហើយ យើងនឹងធ្វើសេចក្តីសម្រេចនៅពេលក្រោយទៀតនេះគឺថា ចំពោះចៅក្រម ហើយភាគីក៏ត្រូវយល់ដូច្នោះដែរ ។ អ៊ីចឹង ខ្ញុំជឿថា នៅក្នុងដំណាក់កាលនេះ សូមប្រើឯកសារ ដែលយើងទទួលយកមកប្រើ ដើម្បីជាមូលដ្ឋាននៃការសួររបស់លោកស្រី ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី៖**

ខ្ញុំសុំការបំភ្លឺបើសិនជាយោងទៅរកឯកសារ ដែលទាក់ទងទៅនឹងសាក្សីរូបនេះ ដែលគាត់អាចបំភ្លឺបានប្រសិនបើគាត់អាចប្រាប់-- សូមអរភ័យទោស ។

*[ពី១៣:៣៧ ដល់ ១៣:៤៦នាទី ត្រូវផ្អាកដោយសំឡេងភ្លៀង]*

**ប្រធានអង្គជំនុំ៖**

យើងចាប់ធ្វើការទៀត ដូចជាបញ្ហាដល់ពេលភ្លៀងមករំខានដូច្នេះ។

មេធាវី ស្ទួនហ្សីនស្តី សូមលោកស្រីឡើងបង្ហាញមើល អំពីឯកសារដែលលោកស្រីមានការប៉ុនប៉ងក្នុងការលើកឡើងមកដេញដោលនាពេលនេះ តើឯកសារនោះជាឯកសារកំណត់អំពីអ្វីទៅ?

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី៖**

សូមអរគុណលោកប្រធាន។ នេះជាឯកសារមួយចុះកាលបរិច្ឆេទនូវថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០០៣ ចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សាក្សីឈ្មោះ ចាន់ ខន នេះត្រូវបានសួរ ឬក៏ធ្វើសម្ភាសន៍ ហើយការសម្ភាសនោះឈ្មោះ ឃិន ហើយនិង វ៉ាស៊ី ជាអ្នកសម្ភាសគាត់ ។ ការសម្ភាសន៍នោះគឺនៅក្នុងឯកសារលេខ៥៩ ហើយនិងនៅក្នុងភាសាខ្មែរជាច្បាប់ដើមនោះ ឯកសារលេខ ០០០០២១៧៤២៩៤ ។ ឯកសារនេះ គឺជាឯកសារប្រតិចារឹកចេញពីបទសម្ភាសន៍មួយ ដោយសាក្សីដែលវត្តមាននៅក្នុងសាលសវនាការនេះឯង ដែលគាត់បានផ្តល់បទសម្ភាសន៍ ។ ហើយខ្ញុំសូមជម្រាបថា តើខ្ញុំអាចយោងទៅរកឯកសារ ដែលដាក់នៅក្នុងសំណុំរឿងនេះ?

ហើយចំណុចទីពីរជាបទសម្ភាសន៍ជាមួយសាក្សី ដែលវត្តមាននៅក្នុងតុលាការពេលនេះ អាចនឹងសួរតទល់គាត់បាននៅក្នុងផ្នែកនៃប្រតិចារឹកនៃបទសម្ភាសន៍របស់គាត់ហ្នឹងបានឬទេ? ហើយសូមឲ្យគាត់បញ្ជាក់ ឬក៏មិនបញ្ជាក់ថាត្រឹមត្រូវ ឬមិនត្រឹមត្រូវទៅលើកំណត់ហេតុពីបទសម្ភាសន៍នោះ ។ តាមទស្សនៈខ្ញុំឯកសារនេះ គឺវាខុសគ្នាពីផ្សេងឯកសារផ្សេងៗទៀត ដែលយើង ឬក៏អង្គជំនុំជម្រះបានយោងទៅរកពីមុននោះ ពីរ-បីថ្ងៃមកនេះ ។ ឯកសារផ្សេងៗទៀតមកពីមជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺបង្ហាញនូវសាក្សីដែលជាអ្នកបានស្លាប់ទៅហើយមួយចំនួន ។ ប៉ុន្តែ សេចក្តីសម្រេចនោះមិនទាន់ធ្វើនៅឡើយទេ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតថា អង្គជំនុំជម្រះមេត្តាធ្វើសេចក្តីសម្រេចនៅពេលនេះ ដោយហេតុថា សាក្សីកំពុងវត្តមាន ។ ខ្ញុំចង់បានការអនុញ្ញាត គឺថាខ្ញុំអាចយកចំណុចមួយ កថាខណ្ឌមួយពីឯកសារនោះ ដើម្បីមកសួរបញ្ជាក់ពីសាក្សីបានឬអត់? បើសិនដូច្នោះ ខ្ញុំសូមអញ្ជើញឲ្យភាគីផ្សេងៗទៀត មានមតិទៅលើបញ្ហានេះផងដែរ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាមតិយ៉ាងម៉េចដែរ ការដែលសុំលើកឡើងអំពីឯកសារមួយដែលលើកឡើងដោយមេធាវីក្រុមពីរនេះ?

[១៣:៥០:០៧]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។ យើងបានពិនិត្យមើលបោះពុម្ពឯកសារចេញនូវប្រតិចារឹកថ្ងៃទី០៥ និងថ្ងៃទី០៧ ខែមេសា ដោយចៅក្រម ឡាវែន៍ នឹងអនុញ្ញាតឲ្យខ្ញុំអានពាក្យរបស់គាត់ត្រឡប់ទៅគាត់វិញ ។ នោះគឺពាក្យដកស្រង់ទាំងស្រុង ។

ការបំភ្លឺទីមួយក្នុងពេលនេះ អង្គជំនុំជម្រះមិនមានចេតនានឹងបន្តអានសេចក្តីថ្លែងការណ៍ដែលប្រមូលDC-Cam ទេ ហើយ គឺថា អ៊ិន វន ហើយ ហម អ៊ិន ទាក់ទងនឹង គឺថាអាចនឹងចេញសេចក្តីសម្រេច ពេលក្រោយទាក់ទងទៅនឹងឯកសារនេះ ។ ប៉ុន្តែ ក្នុងពេលនេះអង្គជំនុំជម្រះស្នើឲ្យភាគីមិនត្រូវយោងឯកសារទាំងនេះទៀតទេ ។

លោកប្រធាន លោកស្រីចៅក្រម នៅក្នុងភាសាអង់គ្លេសខ្ញុំឃើញច្បាស់ថា ការហាមប្រាមនេះនៅក្នុងការយោងទៅរកសេចក្តីថ្លែងការណ៍របស់ *DC-Cam* ដែលបញ្ជាក់ឡើងដោយចៅក្រម ឡាវែន៍ ទាក់ទងទៅតែហ្នឹង ឯកសាររបស់ អ៊ិន វន និង ហម អ៊ីន នោះទេ ។ អ៊ីចឹងខ្ញុំពិនិត្យឃើញថា សហព្រះរាជាអាជ្ញា មូលហេតុគាំទ្របញ្ហានោះ គឺសាក្សីនោះបានស្លាប់ទៅហើយនៅក្នុងករណីទាំងពីរនោះ ។ ហើយមិនមានអ្នកណាម្នាក់ជាអ្នកបញ្ជាក់ថា ត្រូវ ឬមិនត្រូវទៀតទេ ។ អ៊ីចឹងក្នុងជំហររបស់សហព្រះរាជអាជ្ញា យើងគាំទ្រអ្វីដែល ស្មូតហ្សិនស្គី បាននិយាយខាងដើមនោះ ជាសំណើររបស់គាត់ ។ សាក្សីរូបនេះឈ្មោះ ចាន់ ខន គាត់វត្តមាននៅក្នុងសាលសវនាការ ហើយយើងអាចសួរអំពីការកាលៈទេសៈនៃការសម្ភាសពេលនោះដែលមានអ្នកសម្ភាសមកពី *DC-Cam* ហើយខ្ញុំសូមអនុញ្ញាតឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យធ្វើការចោទសួរពីថ្លែងការណ៍នឹងទៅសាក្សី ។ ថាតើទម្ងន់នៃព័ត៌មានហ្នឹង ភ្ជាប់ទៅនឹងសាក្សីហ្នឹងវាច្បាស់ដូចម្តេច? ហើយសូមឲ្យមានការអនុញ្ញាតពីលោកប្រធាន និងភាគីផ្សេងៗទៀតដែរ ។

**ប្រធានអង្គជំនុំ៖**

មេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀត ក្រៅពីក្រុមពីរមានមតិយោបល់យ៉ាងម៉េចដែរអំពីការដែលលើកយកឯកសារនេះមកដេញដោល?

**លោក ការីម ខាន៖**

លោកប្រធានយើងគាំទ្រគោលជំហរនេះ ដែលលើកឡើងដោយមេធាវីក្រុមទីពីរ ហើយនិងដែលលើកដោយសហព្រះរាជអាជ្ញា យើងគាំទ្រ ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារជនជាប់ចោទ លោកមានយោបល់យ៉ាងម៉េចដែរ? ទាក់ទិនជាមួយនឹងការលើកឡើងរបស់មេធាវីក្រុមពីរ ដែលបានលើកឡើងអំពីឯកសារនេះមកពិភាក្សាដេញដោល ។

[១៣:៥៣:៣១]

**លោក ហ្វ្រង់ស្វ័រ រូះ**

លោកប្រធានយើងសង្ឃឹមថា ប្រហែលលោកប្រធានមិនអាចស្តាប់ខ្ញុំច្បាស់ទេ រាប់ទាំងអ្នកបកប្រែផង ។ ការសង្កេតទីមួយ សហសេវិករបស់ខ្ញុំនោះ បាននិយាយអំពីឯកសាររបស់ *DC-Cam* ដែលចុះកាលបរិច្ឆេទខែមេសា ថ្ងៃទី៣០ ឆ្នាំ២០០៣ ។ ហើយឯកសារដែលខ្ញុំមានជាមួយខ្ញុំនៅពេលនេះ ឯងគឺថាខែមេសា ឆ្នាំ២០០៣ ទាក់ទងទៅនឹងលោក ចាន់ វឿន គឺមិនមែនសាក្សីដែលវត្តមាននៅទីនេះទេ គឺចាន់ វឿន នោះទេ ។ សាក្សីដែលវត្តមានក្នុងពេលនេះ ត្រូវបានសម្ភាសដោយ *DC-Cam* មិនមែននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៣ ទេ ប៉ុន្តែនៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០០០ ។

បន្ទាប់មកលោកប្រធាន លោក លោកស្រីចៅក្រម តាមពិតសេចក្តីសង្កេតមកពីខាងមេធាវីការពារក្តី គឺដូចគ្នាទាក់ទងទៅហ្នឹង ឯកសារមួយនេះ ។ ដូចជាឯកសារមួយចំនួនដែលថា មេធាវីការពារបានលើកឡើងពីដំបូងនោះដែរ ។ ខ្ញុំនឹងបញ្ជាក់ឡើងវិញ ហើយខ្ញុំនឹងបញ្ជាក់ឡើងវិញឲ្យច្បាស់ៗមិនមានបញ្ហាអ្វីដែលថា ខ្លឹមសារដែលយើងទទួលស្គាល់រួចមកហើយ ដែលយើងផ្អែកលើឯកសាររបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា គឺថាអង្គការមួយនេះ មិនមែន ហើយមិនមែនជានីតិបុគ្គលមួយដែលតាមផ្លូវច្បាប់ ។ យើងមិនដឹងច្បាស់ទេ ថាស្ថានភាពគេនោះ យ៉ាងដូចម្តេច? នៅពេលប្រមូលយកឯកសារ ដែលថា អ្នកដែលសួរសំណួរទាំងអស់ តើគេមានសមត្ថភាពក្នុងការសួរដែរឬអត់? នេះមិនបានចង្អុលបង្ហាញនៅក្នុងចំណុចផ្តើមនៃការសម្ភាសន៍នោះទេ ថាអ្នកដែលផ្តល់បទសម្ភាសមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបហើយនឹងមានសិទ្ធិដាក់បន្ទុកលើខ្លួនឯងដែរឬទេ?

អ៊ីចឹងហើយគឺថា យើងមានការការពារតាមនីតិវិធីមិនបានទៅប្រើក្នុងពេលនោះទេ ។ ហើយយើងព្យាយាមធានាឲ្យមានការធានាក្នុងការអនុវត្តនីតិវិធីគ្រប់ដំណាក់កាលទាំងអស់ ។ ហើយខ្ញុំសូមបន្ថែមចំណុចមួយទៀត យើងអាចពិនិត្យឃើញចំណុចពីរធ្ងន់ ការលំបាកធំៗនៅក្នុងបកប្រែនៅក្នុងឯកសារពីដំបូងដើមនោះ ពីខ្មែរទៅអង់គ្លេស ឬក៏ពីខ្មែរភាសាបារាំងក្តី ។ ហើយក្រោមលក្ខខណ្ឌទាំងអស់នេះឯង ខ្ញុំសូមអនុញ្ញាតលើកឡើង ហើយនិងបញ្ជាក់ថា វាមិនមានយុត្តិធម៌ទេដើម្បីប្រើឯកសារនោះ

ពីព្រោះវាមានការលំបាកក្នុងការបកប្រែនោះ ។ ដោយថាលោកចៅក្រមមិនដឹងថា អ្នកដែលធ្វើសម្ភាស នោះយើងមិនដឹងពីសមត្ថភាពរបស់គេ ហើយយើងមិនដឹងសមត្ថភាពអ្នកបកប្រែទាំងនោះដែរ ។

ដូច្នេះ ខ្ញុំគិតថា លោក លោកស្រីចៅក្រម មេត្តាចេញសេចក្តីសម្រេចជាក់លាក់ ទាក់ទងទៅនឹង បញ្ហានេះ ។ ខ្ញុំសូមអនុញ្ញាតលើកបញ្ហានេះជូនអង្គជំនុំជម្រះជ្រាបថា ក្រុមអ្នកបកប្រែបានប្រើដោយ ឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជានោះ ដើម្បីបកប្រែឯកសារនោះ ហើយឯកសារដែលបកប្រែត្រូវ យកមកប្រើក្នុងតុលាការនេះ ។ អ៊ីចឹងហើយគឺវាមិនស្របទៅតាមនីតិវិធីរបស់តុលាការនេះទេ ។ អ៊ីចឹង គឺថាកំហុសឆ្គងគប្បីតែបានកែតម្រូវ ហើយត្រូវតែកំណត់ឲ្យត្រឹមត្រូវទៅតាមឯកសាររបស់តុលាការ ថាឯកសារ គឺថាត្រូវបានបន្ថែមទៅក្នុងសំណុំរឿង ហើយមិនគប្បីស្ថិតនៅក្នុងសំណុំរឿងទេ មិនបាន ពិនិត្យកែឡើងវិញនោះ ។ បើមិនបានពិនិត្យកែឡើងវិញនោះ ។ ហើយមិនគប្បីចាត់ទុកថា ជាឯកសារ ដែលមានប្រយោជន៍នោះទេ បើសិនជាមិនធ្វើដោយតុលាការនោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអរគុណលោកប្រធាន ។ តាមដែលខ្ញុំយល់នីតិវិធីរបស់ច្បាប់ស៊ីវិលឡូ សុំឲ្យអង្គជំនុំជម្រះ មេត្តាកែតម្រូវបើខ្ញុំនិយាយខុស ។ កាលណាឯកសារមួយត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយ ហើយមិនមានជំទាស់ទៅហ្នឹងការដាក់ចូលទៅក្នុងសំណុំរឿងនោះទេ ហើយយើងមិនអាចដកយកចេញ ពីសំណុំរឿងហ្នឹងមកវិញបានទេ ។ សហព្រះរាជអាជ្ញាយល់ច្បាស់ថា កាលហ្នឹងវាអ៊ីចឹងមែន គឺថាយើង នឹងថ្លែងអំណរគុណប្រសិនបើអង្គជំនុំជម្រះសម្រេចថា ការបកប្រែនោះវាមិនត្រឹមត្រូវទៅតាមវិធាននោះ។ អ៊ីចឹងហើយគឺថា យើងមានគោលបំណង និងអនុវត្តទៅតាមដំណើរការនោះ ដើម្បីឲ្យយើងអាចដក ឯកសារនោះបាន ម៉េចនឹងដកបានបើសិនជាមេធាវីការពារមិនបានជំទាស់ពីមុន ពីព្រោះថាមិនជំទាស់ ទើបបានដាក់ចូលនៅក្នុងសំណុំរឿង ។

សហព្រះរាជអាជ្ញា គឺមិនបានស្វែងរកការគាំទ្រពីមេធាវីការពារ ដែលថាមិនឲ្យគាត់ធ្វើមតិ យោបល់ទេ គាត់អាចធ្វើបាន លើកឡើងពីការពារនីតិវិធី ឬក៏ការការពារអ្វីផ្សេងទៀតរឿងឯកសារ ។ ប៉ុន្តែ សហព្រះរាជអាជ្ញាសូមជម្រាបថា ឯកសារនេះគឺត្រូវបានដាក់ជូនក្នុងសំណុំរឿងយ៉ាងត្រឹមត្រូវ ហើយគោរពទៅតាមវិធាន ហើយគប្បីត្រូវបានពិចារណាដោយលោក លោកស្រីចៅក្រម លោកប្រធាន

ដែលជាចៅក្រមអាជីព ។ ហើយខ្ញុំសូមអនុញ្ញាតឲ្យអង្គជំនុំជម្រះអនុញ្ញាតប្រើឯកសារនេះ ។ ដោយហេតុថាយើងមានសាក្សីមកទីនេះ យើងអាចសួរបញ្ជាក់ ឬក៏បដិសេធទៅលើចំណុចណាមួយដែលត្រូវបានកត់ត្រាពីមុនមក ។ នេះជាសេចក្តីស្នើរបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

**លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្តី៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមបញ្ជាក់ឯកសារដែលខ្ញុំយោងទៅរកនោះគឺជាឯកសារពីបទសម្ភាសន៍លោក ចាន់ ខន មិនមែនដូចដែលមេធាវីការពារលើកឡើងថារបស់ ចាន់ វឿន ទេ គឺថា កាលបរិច្ឆេទ គឺថ្ងៃទី៣០ មេសា ឆ្នាំ២០០៣ នៅក្នុងអត្ថបទភាសាអង់គ្លេស ។

ខ្ញុំសូមបញ្ជាក់អំពីការជំទាស់របស់មេធាវីការពារដែលបានលើកឡើងខាងដើម ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ទាក់ទងទៅនឹងបញ្ហានេះ យើងពិនិត្យឃើញថា ចំពោះខ្ញុំគឺវាមានភាពខុសគ្នារវាងអត្ថបទជាភាសាបារាំង និងជាភាសាអង់គ្លេស ។ អត្ថបទជាភាសាបារាំង គឺឯកសារ D59 មានលេខ ERN 00243389 រហូតទៅដល់ 00242304 ។ ឯកសារមួយនេះ បានបញ្ជាក់ថា គឺជាឯកសារបកប្រែចេញពីភាសាខ្មែរច្បាប់ដើមលេខ00021742002194 ។ បន្ទាប់មកយើងមានអត្ថបទភាសាអង់គ្លេស នៅក្នុងលេខ D59 ដែលមានលេខ ERN00023193 រហូតទៅដល់ទំព័រ 000231911 ហើយអត្ថបទជាភាសាអង់គ្លេងក៏ជាអត្ថបទបកមកពីភាសាខ្មែរដើមក៏អាចរកឃើញនៅក្នុងចុងបញ្ចប់នៅក្នុងទំព័រហ្នឹង ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

តើទំព័រណា?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

នៅក្នុងអត្ថបទភាសាបារាំង ចាន់ ខន ត្រូវបានសម្ភាសនៅថ្ងៃទី៨ មីនា ឆ្នាំ២០០០ ប៉ុន្តែនៅក្នុងអត្ថបទអង់គ្លេសវិញ គឺកាលបរិច្ឆេទនៃសម្ភាសបានបញ្ជាក់ថា នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៣ ។ ខ្ញុំ

សូមអនុញ្ញាតបន្ថែមទៀត ចាន់ វឿន ត្រូវបានសម្ភាសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នេះក៏ត្រូវបានដាក់ជាឯកសារនៅ D59 លេខ ERN00295065 កាលបរិច្ឆេទនៃបទសម្ភាសគឺថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៣ ដែរ ។ ដូច្នេះវាអាចមានលទ្ធភាពថា មានជាការភាន់ច្រឡំនៅក្នុងការបកប្រែ ។ ខ្ញុំមិនដឹងថាតើកាលបរិច្ឆេទដែលបញ្ជាក់នៅក្នុងអត្ថបទខ្មែរដើមហ្នឹងដូចម្តេចទេ?

**ប្រធានអង្គជំនុំ៖**

មេធាវី ហ្រ្វង់ស្វ័រ រ៉ូ ។

**លោក ហ្រ្វង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកប្រធាន ខ្ញុំគិតថា ការខុសគ្នានេះក្នុងកាលបរិច្ឆេទ ហើយនិងការបកប្រែនោះគឺគាំទ្រ អ្វីការគាំទ្រដែលខ្ញុំបញ្ជាក់ខាងដើមនោះ ខ្ញុំសូមអនុញ្ញាតបន្ថែមថា សាក្សីទាំងនេះត្រូវបានគេសម្ភាសក្រោមលិខិត ដីកាចាត់ឲ្យសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេតជាផ្នែកមួយនៃនីតិវិធីរបស់តុលាការ ។ ដោយមានការការពារនីតិវិធីទាំងអស់នៅក្នុងដំណើរការរឿងក្តី ដូច្នេះ នេះជារបាយការណ៍របស់តុលាការ ដែលកំណត់ហេតុសួរចម្លើយហ្នឹង គប្បីគួរតែមានប្រៀបលើអត្ថបទទាំងអម្បាលម៉ានខាងដើមនោះ ។

ខ្ញុំសូមអនុញ្ញាតស្នើថា ទាក់ទៅនឹងប្រព័ន្ធច្បាប់ស៊ីវិលឡ ដែលលើកឡើងដោយសហព្រះរាជអាជ្ញានោះ គឺថាឯកសារនោះគឺស្ថិតនៅក្នុងសំណុំរឿង មិនមែនមានន័យថា មិនមែនមិនមានបញ្ហាដល់ពេលនេះនោះទេ ។ ប៉ុន្តែ នៅពេលណាមួយគឺថា អង្គជំនុំជម្រះអាចធ្វើសេចក្តីសម្រេចថាមិនប្រើឯកសារនោះក៏បានដែរ ។ នីតិវិធីរបស់យើងនោះគឺអនុញ្ញាតឲ្យយើងលើកឡើងភាពមោឃភាពនៃឯកសារ មុនពេលដែលមានការបញ្ជាក់ថា ត្រឹមត្រូវ ។ ប៉ុន្តែបញ្ហានៅទីនេះ ដើម្បីលើកឡើងពីមោឃភាពនៃឯកសារមួយគឺថាយើងត្រូវតែលើកពីឯកសារហ្នឹងមកដល់ដៃ ។

[១៤:០៦:៤៦]

ខ្ញុំសូមអនុញ្ញាតចង្អុលបង្ហាញថា ចំពោះឯកសារ D59 ដែលទាក់ទងទៅនឹងការសម្ភាសន៍លោក ចាន់ វឿន នោះ គឺត្រូវបានចែកទៅឲ្យមេធាវីការពារ គឺថានៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ ។ ថាតើមេធាវីអាចនឹងលុបចោល ឬក៏ដកចេញ ឬក៏ជំទាស់ដូចម្តេចបាន បើខ្លួនមិនទាន់ទទួលបានឯកសារនោះទាន់ពេលផងនោះ ។

មេធាវីមិនស្នើសុំឲ្យអង្គជំនុំជម្រះប្រកាសថា ឯកសារនេះមោឃៈនោះទេ ប៉ុន្តែ កំណត់ជាមុននៅក្នុងនីតិវិធី ពីព្រោះក្នុងច្បាប់ស៊ីវិលឡ គឺថាអនុញ្ញាតឲ្យតុលាការសម្រេចថា ឯកសារណាមួយជាភស្តុតាងមិនបានបំពេញគោលបំណងសម្រាប់ប្រើជាភស្តុតាងនោះ ។

ខ្ញុំសូមបញ្ជាក់ថា ឯកសារមួយនេះមិនសាកសមទៅលើអ្វីដែលថា វាប៉ះពាល់ទៅដល់គោលការណ៍នៃការជំនុំជម្រះដោយយុត្តិធម៌ ពីព្រោះថាមិនបានធ្វើដោយដីកាចាត់ឲ្យសួរជំនួស ដែលសាក្សីលោកបង្ហាញមុននេះ គឺថាអាចនឹងសម្អាសអាចនឹងសួរតទល់ជាមួយនឹងជនជាប់ចោទ ។ ដូច្នេះ ការជំនុំជម្រះនោះមិនបានផ្អែកទៅលើឯកសារ ដែលមិនបានធ្វើឡើងដោយមានការបញ្ជាក់តាមផ្លូវតុលាការជាមុននោះទេ ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

លោកប្រធាននេះជាពាក្យចុងក្រោយរបស់ខ្ញុំទាក់ទងទៅនឹងឯកសារ ។ សូមមេត្តាពិនិត្យអ្វីជាបញ្ហាចម្បងនៅទីនេះ ។ យើងមានសាក្សីដែលវត្តមានចំពោះមុខលោក លោកស្រីចៅក្រម ។ គាត់គឺជាមនុស្សដ៏ល្អបំផុតនៅក្នុងសាលសវនាការនេះ ដើម្បីប្រាប់យើងថា តើអ្វីដែលសរសេរនៅក្នុងបទសម្ភាសន៍នោះនៅក្នុងឆ្នាំ២០០៣ ត្រឹមត្រូវ ឬមិនត្រឹមត្រូវ? នេះជាអ្វីដែលយើងស្នើនៅក្នុងនាមរបស់ការិយាល័យសហព្រះរាជអាជ្ញានោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

**លោក ហ្វ៊ីលីព កាណុន៖**

ខ្ញុំសូមអភ័យទោសលោកប្រធាន ខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានមួយចំនួនទាន់ទងទៅនឹងក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ ។ ខ្ញុំសូមលើកសំណួរចោទដែលលើកឡើងដោយមេធាវីការពារក្តីលោក រូ ។

[១៤:០៩:៣១]

លោកប្រធាន លោក លោកស្រី ចៅក្រមជាទីគោរព! ខ្ញុំជឿថា យើងមានបញ្ហានេះសាជាថ្មីម្តងទៀតហើយ ។ ហើយនៅថ្ងៃទី៦ យើងមានបញ្ហានៅក្នុងខែនេះ ដែលវាទាក់ទងទៅនឹងការសម្ភាសន៍ គឺវាទាក់ទងទៅនឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងឃើញថាមានការឲ្យដាក់សេចក្តីសន្និដ្ឋានសង្ខេបចំពោះការឆ្លើយតបទៅនឹងឯកសារនេះ ។

ដើមបណ្តឹងរដ្ឋប្បវេណី គឺគោរពតាមអង្គជំនុំជម្រះ ហើយបញ្ហានេះមិនទាន់បានដោះស្រាយនៅឡើយ ហើយនៅថ្ងៃនេះយើងបានជួបប្រទះនឹងបញ្ហានេះសាជាថ្មីម្តងទៀត ។

ដូចដែលលោក រូ ខ្ញុំលើកឡើងបញ្ហានេះ ជាបញ្ហានៃគោលការណ៍ ។ ខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានថា វាជាការស្វែងរកយុត្តិធម៌មួយដ៏ល្អ ។ អង្គជំនុំជម្រះបានបញ្ជាក់ថា ថាតើឯកសាររបស់មជ្ឈមណ្ឌលឯក-សារកម្ពុជានេះ គួរតែអាចប្រើប្រាស់បាន ឬក៏មិនបាន? ប្រសិនបើអស់លោក លោកស្រី ចៅក្រមធ្វើការសម្រេចថា ឯកសារទាំងនោះមិនត្រូវយកមកប្រើនោះទេ នៅពេលនោះ ខ្ញុំទាំងអស់គ្នានឹងគោរពតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។ ប៉ុន្តែ បើសិនសម្រេចថា យកមកប្រើប្រាស់ដោយយើងអនុវត្តទៅតាមគោលការណ៍មួយចំនួនទៅលើឯកសារនោះ ដែលឯកសារនោះមិនមែនជាឯកសាររបស់តុលាការ។ នៅចំណុចកាលពីលើកមុន ខ្ញុំលើកឡើងអំពីការបង្ហាញការពិត ហើយចំណុចនេះគឺវាពាក់ព័ន្ធទៅនឹងឯកសារផ្សេងៗដែលបង្ហាញនៅលើអង្គហេតុ ។

ដូច្នេះ ខ្ញុំសូមបញ្ជាក់ទៅលើភាពចាំបាច់ក្នុងការជម្រាបទៅដល់ភាគី ថាតើភាគីនឹងត្រូវធ្វើអ្វីនៅពេលនេះ ឬក៏នៅថ្ងៃក្រោយ ប្រសិនមិនដូច្នោះទេនៅក្នុងថ្ងៃ អាទិត្យក្រោយ ឬក៏ខែក្រោយយើងនឹងអាចជួបប្រទះនឹងបញ្ហាពិបាកនេះសាជាថ្មី។

សូមអរគុណចំពោះការស្តាប់របស់លោក លោកស្រី ចៅក្រម ។

*(ចៅក្រមពិភាក្សាគ្នាពី១៤:១២:០១នាទី ដល់១៤:១៦:៤០នាទី)*

**ប្រធានអង្គជំនុំ៖**

ក្រោយពីបានស្តាប់នូវការលើកឡើងនូវឯកសារ ដើម្បីសួរដេញដោលទៅនឹងសាក្សីរូបនេះ ដែលលើកឡើងដោយមេធាវី ស្ទូតហ្វ៊ីនស្គី មេធាវីការពារក្តីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។ ហើយបានស្តាប់នូវបទអន្តរាគមន៍ សេចក្តីសន្និដ្ឋានរបស់ភាគីផ្សេងៗទៀត និងក្រោយពីបានពិភាក្សារវាងអង្គជំនុំជម្រះ អង្គជំនុំជម្រះសម្រេចថា ឯកសារដែលបានលើកឡើងដោយមេធាវី ស្ទូតហ្វ៊ីនស្គី ដែលតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ និងឯកសារដែលមានលេខ D59 ឬក៏ ERN0002174 រហូតដល់ 0002194នោះ គឺអង្គជំនុំជម្រះសម្រេចឲ្យអាចលើកមកពិភាក្សាដេញដោលនៅទីនេះបាន ។

ដោយឡែកបញ្ហាការកត់សម្គាល់ដែលអង្គជំនុំជម្រះបានលើកឡើងកន្លងមក គឺមិនមែនឯកសារ

នេះទេ គឺឯកសារទាក់ទិនជាមួយនឹងកំណត់ហេតុយកចម្លើយរបស់ អ៊ុន វន ហើយនិង ហាម អ៊ីន ហើយនិងឯកសារ ដែលធ្វើសម្ភាសន៍ដោយ *យូអិនអេកស៊ីអ UNHCR* កន្លងមក ដែលយើងបានសម្រេចបឋមរួចហើយ ហើយនឹងមានគោលការណ៍សម្រេចដាច់ខាតច្បាស់លាស់នៅពេលក្រោយ ។

ហើយជាតទៅមុខទៀត អង្គជំនុំជម្រះសូមជម្រាបភាគីថា បើភាគីណាមានការប៉ុនប៉ង ត្រូវលើកឡើងនូវឯកសារផ្សេងៗបែបរបៀបនេះ គឺសូមឲ្យមានការលើកឡើងហ្នឹងជាមុនបង្ហាញដល់អង្គជំនុំជម្រះ ដើម្បីអង្គជំនុំជម្រះពិនិត្យសម្រេចជាមុន មុននឹងចាប់ផ្តើមធ្វើការតទល់ ឬក៏ពិភាក្សាដេញដោលជាមួយនឹងសាក្សី ។

សូមអញ្ជើញលោកស្រីស្មួតហ្សីនស្គី ដែលមានបំណងគឺសូមអញ្ជើញ។

**លោកស្រី ស៊ីលឃីស្មួត ហ្សីនស្គី៖**

អរគុណលោកប្រធាន។

ខ្ញុំនឹងយោងទៅលើឯកសារនេះ ។ ខ្ញុំនឹងអានឯកសារភាសាអង់គ្លេសទំព័រទី១៣ ជាភាសាអង់គ្លេស គឺនៅក្នុងទំព័រ១៣ ហើយទំព័រ១៤ ភាសាខ្មែរ ហើយចំពោះភាសាបារាំងខ្ញុំអត់ដឹងថានៅក្នុងទំព័រណាទេ។

[១៤:២០:១៩]

**ស៖** លោក ចាន់ ខន ខ្ញុំសូមបន្តធ្វើការសួរលោកបន្តទៀត ។ ហើយចំពោះសំណួររបស់ខ្ញុំពីដំបូងខ្ញុំបានសួរលោក ថាតើលោកចាំព្រឹត្តិការណ៍ដែលមនុស្សពីរនាក់ គឺ ឃិន ហើយនិង វ៉ាស៊ី តើលោកចាំដែរឬទេ ដែលនៅពេលមួយនោះគឺមាន ឃិន ហើយនិង វ៉ាស៊ី? បុគ្គលពីរនាក់គឺ ឃិន ហើយនិង វ៉ាស៊ីនេះ គឺជាអ្នកដែលមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានមកធ្វើការជជែកសម្ភាសន៍ជាមួយនឹងលោកកាលពីប្រាំមួយឆ្នាំមុន ដែលនៅពេលនោះនិយាយអំពីបទពិសោធន៍ និងការឆ្លងកាត់របស់លោកនៅមន្ទីរស-២១ ។ ថាតើលោកសាក្សីបាននិយាយកាលពីប៉ុន្មានឆ្នាំទៅមិញនោះ បាននិយាយជាមួយនឹងបុគ្គលពីរនាក់ ហើយនៅពេលនោះលោកបានប្រាប់អ្នកទាំងពីរនោះអំពីបទពិសោធន៍របស់លោក ដែលបានធ្វើការនៅមន្ទីរស-២១? តើលោកបានចាំដែរឬទេ?

**សាក្សី KW-32៖**

**ឆ៖** ខ្ញុំសូមអភ័យទោសទៅ ខ្ញុំភ្លេចអស់ហើយ ។ បើអាចចាំបានតែឯកសារឆ្នាំ២០០៨នេះទេ ពីនុំងមកគឺភ្លេចភ្លាំងអស់ហើយ ។ ព្រោះបានថាភ្លេចភ្លាំង វាមិនយកចិត្តទុកដាក់ យើងជាអ្នកស្រែផង អាល័យប្រឹងការងាររកស៊ីជាបន្តបន្ទាប់ នោះគឺទើបមកឮអស់លោកហ្នឹងលើកឡើងទេបានខ្ញុំដឹង ហើយ

ពីមុនន៎ុងភ្លេច ។ ឥឡូវហ្នឹងគឺភ្លេចអស់ហើយឆ្លើយមិនរួចទេ ។

**ស៖** ថាតើលោកបានចាំទេថា មានមនុស្សពីរនាក់ បានទៅនិយាយជាមួយលោក ហើយគាត់បានសម្ភាសន៍ជាមួយនឹងលោក ហើយនៅពេលនោះគឺលោកបានរៀបរាប់នូវចំណុចច្រើនណាស់ទាក់ទងទៅនឹងការងាររបស់លោកនៅម-១៣ ថាតើលោកបានចាំទៅលើពេលន៎ុងទេ ដែលមានបុគ្គលពីរនាក់ទៅសម្ភាសន៍លោកន៎ុង?

**ឆ៖** ដូចខ្ញុំជម្រាបហ្នឹងហើយថា ខ្ញុំភ្លេចអស់ហើយ គឺអត់បានចាំទេ ។ មិនបានចាំតាំងពីការឆ្លើយរហូតដល់អ្នកដែលទៅសាកសួរហ្នឹងទៀត ។ បើឯកសារដូចខ្ញុំលើកឡើង គឺឆ្នាំ២០០៨ ហ្នឹង គឺបានខ្ញុំចាំបាន ។ សូមអភ័យទោសគឺឆ្លើយមិនរួចទេត្រង់ហ្នឹង ។

[១៤:២៣:៤៧]

**ស៖** ដូច្នេះខ្ញុំនឹងធ្វើការជួយលោក ហើយនិងជម្រាបប្រាប់លោកថាតើមានអ្វីកត់ត្រានៅក្នុងការសម្ភាសន៍នៅថ្ងៃនោះ ។ ហើយខ្ញុំនឹងអានសំណួរទាំងឡាយដែលគេបានសួរ ហើយនិងចម្លើយផ្សេងៗដែលលោកបានឆ្លើយ ។ សំណួរដំបូងនោះគឺថា “ថាតើលោកធ្លាប់មានដែលឃើញ ឌុច ហ្នឹង ទាញកាំភ្លើងបាញ់ពីណាមួយផ្ទាល់ដៃដែរឬទេ?” នោះគឺជាសំណួរ ហើយលោកបានឆ្លើយថា “ធ្លាប់បានឃើញចេះតែឃើញហើយ ប៉ុន្តែមិនដឹងថាម៉េច” ។ ហើយសំណួរពីរបន្ទាប់ទៀត “ថាតើលោកមានដែលឃើញមានមែន? ថាតើមនុស្សប្រភេទណាខ្លះដែលគាត់បានបាញ់ដោយផ្ទាល់ដៃន៎ុង? ហេតុអ្វីបានជាគាត់បាញ់ហើយតើគាត់បាញ់សម្លាប់ហ្នឹងតាមរបៀបណា?” ហើយលោកបានឆ្លើយថា “អ្នកទោសហ្នឹង ដូចដែលខ្ញុំបានជម្រាបអ៊ីចឹង ខ្ញុំវាមិនទៅតាមដានទាន់ មិនដឹងជាទោសរបៀបម៉េច? ដូចយើងសង្កមឥឡូវវាស្រួលវិនិច្ឆ័យណាស់ ដឹងថាទោសអ៊ីចេះ ទោសអ៊ីចុះ ។ កាលហ្នឹងមិនដឹងជាទោសស្អីៗផង ។

**ស៖** ហើយសំណួរបន្តទៀត--

**ប្រធានអង្គជំនុំ៖**

សួរទៅ សាក្សីដូចជាគាត់បាននិយាយច្បាស់លាស់ហើយ ថាគាត់ភ្លេចអស់ហើយ នូវអ្វីដែលបានធ្វើការសម្ភាសន៍ហ្នឹងពីប្រាំមួយឆ្នាំមុន ។ គាត់អាចចាំត្រឹមតែអ្វីដែលធ្វើការសម្ភាសន៍ហ្នឹងនៅក្រោយឆ្នាំ ២០០៨ ទេ ។ អ៊ីចឹងបើភ្លេចអស់ហើយ បើសួរទៅទៀតហ្នឹងក៏ដូចជាមិនដឹងថាឆ្លើយត្រង់ណាដែរ ពីព្រោះគាត់បានប្រាប់ថាគាត់ភ្លេចអស់ហើយ ។ អ៊ីចឹងគឺ គប្បីធ្វើការដូរសំណួរទៅ អាចសួរសំណួរផ្សេងទៀត ហើយពាក់ព័ន្ធជាមួយនឹងសំណួរដែលពិនិត្យលើឯកសារនេះ អង្គជំនុំជម្រះគិតថា មិនចាំបាច់សួរ

ទៀតទេ ពីព្រោះសាក្សីបានឆ្លើយថា ភ្លេចអស់ហើយ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សិនស្គី៖**

អរគុណលោកប្រធាន ។

គោលបំណងដែលខ្ញុំចង់អានឯកសារនោះ គឺដើម្បីចង់ផ្តល់ជាជំនួយទៅដល់សាក្សី ដើម្បីឲ្យគាត់ចងចាំឡើងវិញ ទៅលើស្ថានភាព និងពេលវេលាមួយនោះដែលគាត់បាននិយាយជាមួយនឹងបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ហើយខ្ញុំចង់អានបន្ថែមទៅលើប្រយោគចំនួនពីរបន្តទៀត ។

**ស៖** លោក ចាន់ ខន--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យបន្តទៀតទេ ។ អាចសួរសំណួរផ្សេងទៀតបើមាន បើអត់មានទេ គឺអាចតុលាការនឹងប្រគល់វេទិកានេះទៅឲ្យមេធាវីក្រុមផ្សេងទៀត ។

[១៤:២៨:១៨]

**លោកស្រី ស៊ីលឃី ស្ទូតហ្សិនស្គី៖**

លោកប្រធាន លោក លោកស្រី ចៅក្រមជាទីគោរព! ខ្ញុំយល់ ហើយទទួលបានសេចក្តីសម្រេចរបស់លោក លោកស្រីចៅក្រម ដែលលើកឡើងដោយផ្ទាល់មាត់ ។ អ៊ីចឹង គឺយើងអនុញ្ញាតឲ្យមានការតទល់លើឯកសារហ្នឹងទៅនឹងសាក្សី ។ ហើយខ្ញុំសូមបញ្ចប់ប្រយោគចំនួនពីរបន្ថែមទៀត ដើម្បីសួរសាក្សីសាជាថ្មីអំពីយោបល់របស់គាត់នៅថ្ងៃនេះ ។

ដូច្នេះហើយ គឺខ្ញុំសូមអនុញ្ញាតឲ្យលោក លោកស្រីចៅក្រមអនុញ្ញាតឲ្យខ្ញុំអានប្រយោគចំនួនពីរប្រយោគទៀត ដែលមាននៅក្នុងឯកសារ ដើម្បីបន្តធ្វើការចោទសំណួរទៅកាន់សាក្សី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! គឺថាអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចហើយ ដូច្នេះ ខ្ញុំសុំឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគោរពលើសេចក្តីសម្រេចហ្នឹង ហើយមិនអានបន្តទៀតទេ ។ ហើយខ្ញុំឮសេចក្តីសម្រេចពីអង្គជំនុំជម្រះសាលាដំបូងថា មិនឲ្យអានទៅលើចម្លើយនោះទៀតទេ ។ ដូច្នេះ ហើយខ្ញុំសង្ឃឹមថា មេធាវីនុ៎ងនឹងមិនអានទៅលើឯកសារហ្នឹងទៀតទេ ។

**ប្រធានអង្គជំនុំ៖**

មេធាវីគឺយើងបានសម្រេចហើយ ហើយអាចដូរ បើមានសំណួរអ្វីសួរគឺអាចសួរបន្តទៀត

ក្រៅពីការផ្ទៀងផ្ទាត់នៅដេញដោលជាមួយនឹងឯកសារដែលមាន ពីព្រោះសាក្សីបានបង្ហាញច្បាស់លាស់ ហើយថាមិនចាំអ្វីទាំងអស់នៅក្នុងពាក់ព័ន្ធនឹងឯកសារនោះ ។ បើគ្មានទេ យើងនឹងអនុញ្ញាតឲ្យទៅក្រុមផ្សេង ដើម្បីតាំងសំណួរបន្ត ។

**លោកស្រី ស៊ីលឃីស្នូត ហ្សីនស្គី៖**

ខ្ញុំនឹងបន្តសំណួររបស់ខ្ញុំទៀត ។ លោក ចាន់ ខន លោកបានប្រាប់ថា គឺបុគ្គលិកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា បាននិយាយថា លោកបានឃើញ ឌុច គាត់បាញ់ដោយខ្លួនគាត់ គាត់បាញ់មនុស្សនៅចំពោះមុខ ។ ហើយគាត់សុំឲ្យលោកមានការកប់ទៅលើសាកសពនុ៎ង ។

**ប្រធានអង្គជំនុំ៖**

សំណួរនេះយើងបាន អង្គជំនុំជម្រះបានប្រាប់ហើយ ថាមិនឲ្យសួរដេញដោល លើកបញ្ហានេះយកមកដេញដោលទៀតទេ នូវឯកសារនេះ ។ មានសំណួរអ្វីផ្សេងទេ ក្រៅពីឯកសារនុ៎ង ដើម្បីសួរដេញដោលដល់សាក្សីរូបនេះ ។ បើគ្មានទេ សូមប្រគល់វេទិកានេះទៅមេធាវីផ្សេងទៀត ។

**លោកស្រី ស៊ីលឃីស្នូត ហ្សីនស្គី៖**

គឺនៅពេលនេះ ខ្ញុំអត់បានអានឯកសារទេ គឺមានការយល់ច្រឡំ ប៉ុន្តែ ខ្ញុំធ្វើការសង្ខេបទៅលើចំណុចហ្នឹង ។ ដូច្នេះហើយ ទើបខ្ញុំចង់សួរទៅកាន់សាក្សី ចាន់ ខន ។

**ស៖** តើលោក ចាន់ ខន តើលោកអាចបញ្ជាក់ថា កាលពីប៉ុន្មានឆ្នាំទៅមិញនោះ គឺលោកបានប្រាប់អ្នកស៊ើបអង្កេត បានឆ្លើយប្រាប់អ្នកស៊ើបអង្កេត កាលពីប៉ុន្មានឆ្នាំទៅមុននោះ មានដែរឬទេ?

**លោក ហ្សង់ស្វ័រ រូ៖**

លោកប្រធាន សូមឲ្យលោកជម្រាបសាក្សី ថាសាក្សីមិនត្រូវឆ្លើយនឹងសំណួររបស់មេធាវីដែលមិនគួរសួរសំណួរនេះទេ ។

ដូច្នេះហើយគឺថា សាក្សីមិនគួរធ្វើការឆ្លើយតបទៅនឹងសំណួរ ដែលមានមេធាវីបានចោទសួរអម្បាញ់មិញនេះទេ ។

**លោកស្រី ស៊ីលឃីស្នូត ហ្សីនស្គី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយនឹងសំណួរមេធាវីនេះទេ ។ ម្តងទៀតចុងក្រោយ មេធាវី ស្នូតហ្សីនស្គី មាន

សំណួរអ្វីផ្សេងទៀតទេ ដែលមិនមានការពាក់ព័ន្ធទៅនឹងកំណត់ហេតុ ដែលលោកស្រីបានលើកឡើងនេះ ។ ហើយហេតុផល គឺយើងបានប្រាប់អស់ហើយ ។ បើគ្មានទេ យើងប្រគល់វេទិកានេះ ទៅឲ្យមេធាវីក្រុមផ្សេងទៀត ។

[១៤:៣៣:៣៥]

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

ដូច្នេះ គឺលោកប្រធាន ប្រកាសថាសំណួរដែលខ្ញុំសួរទៅសាក្សីនេះ គឺមិនអាចទទួលយកបានដើម្បីឲ្យសាក្សីឆ្លើយនោះទេ ។

**ប្រធានអង្គជំនុំ៖**

យើងបាននិយាយរួចហើយ ។ យើងមិននិយាយម្តងទៀតទេ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

**ស៖** លោក ចាន់ ខន ខ្ញុំចង់ដឹងថា តើលោកមានការចាប់អារម្មណ៍ក្នុងការចង់ដឹងអំពី ហេតុអ្វីបានជីតារបស់លោកត្រូវបានគេឃុំ? ហើយហេតុអ្វីបានជាគាត់ស្លាប់នៅក្នុងម-១៣? តើលោកមានការចាប់អារម្មណ៍ចង់ដឹងទៅលើបញ្ហានុំងដែរឬទេ?

**សាក្សី KW-32៖**

**ឆ៖** ចំពោះជីតារបស់ខ្ញុំ ដែលស្លាប់ហ្នឹង ខ្ញុំបានជម្រាបច្រើនលើកច្រើនដងហើយ ។ មិនដឹងគាត់ស្លាប់ដោយវិធីណាទេ ពីព្រោះខ្ញុំមិននៅ ។ ខ្ញុំនៅធ្វើស្រែងអូរព្រាល ខាងលិចត្រពាំងត្រើញឯណោះ។ ខ្ញុំជម្រាបពីរ-បីដងទៅហើយ ។

**ស៖** សំណួររបស់ខ្ញុំ ខ្ញុំសុំសួរឡើងវិញ ។ ថាតើលោកចង់ដឹង ថាតើមានអ្វីកើតឡើងចំពោះជីតារបស់លោកនុំង?

**ឆ៖** សូមអានសំណួរ បន្តិចទៀត?

**ស៖** ថាតើលោកចង់ដឹង ថាមានអ្វីកើតឡើងចំពោះជីតាទាំងពីររបស់លោកនៅម-១៣?

**ឆ៖** ចង់ដឹងថាម៉េច? ខ្ញុំអត់យល់សំណួរហ្នឹង ។

**ស៖** បើសិនលោកចង់ដឹង តើលោកចង់ដឹងថាមានរឿងកើតឡើង ឬជោគវាសនារបស់ជីតាទាំងពីររបស់លោកហ្នឹងយ៉ាងដូចម្តេចនៅម-១៣នោះ? តើគេសម្លាប់គាត់ ឬក៏តើពួកគាត់ទទួលរងទារុណកម្មដែរឬទេ? លោកចង់ដឹងដែរឬទេ? ឬក៏ចង់ដឹងថា តើពួកគាត់ហ្នឹង គាត់ស្លាប់ដោយអត់

អាហារ? ឬក៏មិនមានអាហារគ្រប់គ្រាន់?

**ឆ៖** អានសំណួរអ៊ីចឹងមក ងាយស្រួលនឹងខ្ញុំឆ្លើយ ។ គឺចំពោះតាខ្ញុំ ដែលខ្ញុំបានជម្រាបហ្នឹង គឺដូចខ្ញុំបានថាអ៊ីចឹង មិនដឹងជាទទួលការរងទណ្ឌកម្មពី តាឌុច ឬមួយក៏គាត់ស្លាប់ដោយអត់បាយ គឺខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំមិននៅហ្នឹង ខ្ញុំត្រូវទៅធ្វើស្រែ នៅអូរព្រាល ខាងលិចត្រពាំងត្រើញបាត់ទៅហើយ ។ ហ្នឹងខ្ញុំបញ្ជាក់ជូនឲ្យបានច្បាស់ត្រង់ហ្នឹង ។

[១៤:៣៧:៤៥]

**លោកស្រី ស៊ីលឃី ស្ទូតហ្សិនស្គី៖**

សូមអរគុណ លោក ចាន់ ខន ។ បើសិនជា ខ្ញុំបញ្ចប់សំណួរទៅសាក្សី ប៉ុន្តែខ្ញុំសុំអនុញ្ញាតទៅជនជាប់ចោទមួយសំណួរ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែរំឭកឡើងវិញ ចៀសវាងសួរសំណួរដដែល ។ ហើយដោយសារសួរចុះសួរឡើងច្រើនលើកច្រើនសា គឺតែងតែឆ្លើយតបពីជនជាប់ចោទ គាត់ថាសំណួរនេះដដែល ឬក៏រឿងដដែល ។

ជនជាប់ចោទត្រៀមនូវការស្តាប់នូវសំណួរ ហើយអាចឆ្លើយតបនឹងសំណួរ ក្នុងករណីថាជាសំណួរសមរម្យ ដែលមិនមែនជាសំណួរដដែល ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទូតហ្សិនស្គី៖**

សូមអរគុណ លោកប្រធាន ។

**ស៖** ខ្ញុំចង់ដឹង ថាតើលោកអាចប្រាប់យើងបានទេ តើវិធានការអ្វីខ្លះ? ដែលលោកបានប្រើប្រឆាំងទៅលើឪពុកមារបស់លោក សុខ? ហើយលោកបានចាប់ផ្តើមពន្យល់ពីព្រឹកនេះរួចហើយ ហើយខ្ញុំៗ បានដឹងឈ្មោះហ្នឹង ។ ហើយសំណួររបស់ខ្ញុំ សុំសួរបំភ្លឺបន្តទៅទៀត អំពីឈ្មោះ តើលោកចាំ តើវិធានការ អ្វីដែលលោកបានប្រើប្រឆាំងទៅលើជនរងគ្រោះរូបនោះ នៅក្នុងម-១៣?

**ជនជាប់ចោទ៖**

**ឆ៖** ទីមួយ ចំពោះ ពូសុខ ។ ចំពោះពូសុខ មិត្តខន គាត់និយាយច្បាស់អស់ហើយ ខ្ញុំមិនបញ្ជាក់ថែមទេ ។ ទីពីរ ចំពោះ ពូទឹម ។ ពូទឹម ក៏ដូចជាជនរងគ្រោះដទៃទៀតនៅអមលាំងដែរ ។ គេចាប់មក

ហើយ គេបញ្ជាឲ្យខ្ញុំធ្វើទារុណកម្មសួរចម្លើយហើយ ។ សួរចម្លើយចប់ គេឲ្យយើងខ្ញុំកម្ទេចហើយ ។ នេះសុំបញ្ជាក់យ៉ាងខ្លីប៉ុណ្ណេះ ។

**ស៖** សុំអភ័យទោស ប្រហែលជាខ្ញុំស្ដាប់មិនបានមកពីការបកប្រែ ។ សុំលោកបញ្ជាក់បន្ថែម លោកមិនមានចូលរួមអ្វី ដែលទាក់ទងទៅនឹងជនរងគ្រោះម្នាក់ដែលនៅរស់ ពីម-១៣ ដូចលោក សុខ អ៊ីចឹង?

[១៤:៤០:៥០]

**ឆ៖** រឿង ពូសុខ កញ្ញា ស្នូតហ្សីនស្គី សួរមិត្ត ខន ទៅឲ្យច្បាស់ទៅ គាត់ច្បាស់ជាង ។ ខ្ញុំមិនភ្លេចអស់ហើយ តែចំណែក ពូទឹម ខ្ញុំទទួលខុសត្រូវ ។ ក្នុងថ្នាក់ខ្ញុំជាប្រធានម-១៣ ឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើកគាត់ ខ្ញុំទទួល ។

**ស៖** អ៊ីចឹង មានន័យថា លោកបដិសេធមិនព្រមឆ្លើយសំណួរទាក់ទងនឹងលោក សុខ អ៊ីចឹង?

**ឆ៖** ឥឡូវ កញ្ញា ស្នូតហ្សីនស្គី សួរមិត្ត ខន ខ្លួនឯងទៅ គេច្បាស់ជាងខ្ញុំៗ ។

**លោកស្រី ស៊ីលឃីស្នូត ហ្សីនស្គី៖**

សូមអរគុណ លោកប្រធាន ខ្ញុំមិនមានសំណួរអ្វីទៀតទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ព្រះរាជអាជ្ញា សូមអញ្ជើញ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំពិនិត្យឃើញថា លោកប្រធាននឹងប្រកាសសម្រាកបន្តិតទៀតនេះ ហើយខ្ញុំសូមជូនដំណឹងជាមុនដល់អង្គជំនុំជម្រះថា ឯកសារដែលសហព្រះរាជអាជ្ញា នឹងលើកឡើងមកចំពោះមុខអង្គជំនុំជម្រះ មុននឹងយើងចេញផុតពីបញ្ហានៅម-១៣ ដើម្បីដាក់បញ្ចូលក្នុងរបៀបវារៈ ឯកសារលេខ ១៩.២(៥) នៅក្នុងឧបសម្ព័ន្ធ (គ) នៅក្នុងសេចក្ដីដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ជារបាយការណ៍ដោយ ឈិន សុទ្ធី ដែលត្រូវបានជាប់គុកនៅម-១៣ ដែរ ។ ឯកសារហ្នឹង ចុះកាលបរិច្ឆេទថ្ងៃទី ២២ មករា ឆ្នាំ១៩៧៥ ។ អត្ថបទខ្មែរច្បាប់ដើមនោះ បានដាក់ជាមួយដីកាបញ្ជូនរឿងឲ្យស៊ើបសួរលេខ ERN0002214 រហូតដល់ 2217 ។ អត្ថបទអង់គ្លេស មានលេខ ERN000172202 រហូតដល់ 07 ហើយអត្ថបទភាសា បារាំង 00196193 ទៅដល់ 97 នេះជាឯកសារ ដែលអាចនឹងលើកមកពិភាក្សាក្រោយពីប្រកាសសម្រាក ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ លោកហ្សង់ម៉ាក ចង់មានយោបល់អីទៅ?

[១៤:៤៣:៤៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍**

នេះជាសំណួររបស់ខ្ញុំ ដែលខ្ញុំចង់សួរទៅសហព្រះរាជអាជ្ញា ។ តើឯកសារនេះទាក់ទងទៅនឹងបុគ្គល ដែលជាព័ត៌មានបន្ថែមដែលបានសួរដោយសហចៅក្រមស៊ើបអង្កេតរួចហើយ ឬក៏ជាបទសម្ភាសន៍? ឯកសារដែលលោកលើកឡើងហ្នឹង ។

ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតនោះ គឺទាក់ទងទៅនឹងសាក្សីដែលលោកបានស្នើ តើលោកនៅចាំចម្លើយរបស់គេនោះដែរឬទេ?

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

ឯកសារយោងហ្នឹង ដែលខ្ញុំមាននៅចំពោះមុខខ្ញុំហ្នឹង ប៉ុន្តែតាមដែលខ្ញុំចងចាំសហចៅក្រមស៊ើបអង្កេតបានឆ្លើយតប គឺថាសាក្សីនេះមិនគប្បីតាមដានតទៅទៀតទេ គឺថារកមិនឃើញ ចៅក្រមស៊ើបអង្កេតបញ្ជាក់ថាអ៊ីចឹង ។

**លោក ហ្សង់ម៉ាក ឡាវែន៍**

ខ្ញុំជឿថា សហចៅក្រមស៊ើបអង្កេត បានបន្តធ្វើការបញ្ជាក់ ហើយមិនមានលទ្ធភាពរកឃើញទេ នៅក្នុងដំណាក់កាលស៊ើបអង្កេត ដើម្បីរកតម្រុយរកឲ្យឃើញសាក្សីនេះបាននោះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រាកម្ភៃនាទី រហូតដល់ម៉ោងបីចូលវិញ ។ មន្ត្រីតុលាការសម្របសម្រួលដល់រូបនេះដើម្បីទៅកាន់បន្ទប់រង់ចាំ ហើយនិងអញ្ជើញគាត់មកកាន់ទីនេះវិញឲ្យបានមុនម៉ោងបី ។

*[សវនាការសម្រាកពីម៉ោង ១៤:៤៥នាទីដល់ម៉ោង១៥:១៥នាទី]*

**ប្រធានអង្គជំនុំ៖**

មុននឹងអង្គជំនុំជម្រះប្រកាសបន្តដំណើរការកិច្ចពិភាក្សាដេញដោលជាបន្តទៅទៀត ហើយមុននឹងប្រគល់វេទិកាជូនទៅមេធាវីការពារក្តីក្រុមផ្សេងៗទៀតនោះ អង្គជំនុំជម្រះសូមជម្រាបថា អង្គជំនុំ

ជម្រះបានពិភាក្សាលើសំណើសុំរបស់សហព្រះរាជអាជ្ញា ដើម្បីប្រើប្រាស់នូវឯកសារដែលបានស្នើសុំនាពេលមុនឈប់សម្រាក ។ ឯកសារនោះ គឺជាឯកសារសង្ខេបនៃឯកសារដែលបានធ្វើសម្ភាសន៍ជាមួយនឹងឈ្មោះ ឈិន សុទ្ធី ដែលបុគ្គលនោះមិនបានចូលមកបំភ្លឺដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅដំណាក់កាលស៊ើបអង្កេត ។ បុគ្គលនេះមិនអាចចូលរួមក្នុងសវនាការ និងមិនអាចតទល់ជាមួយនឹងជនជាប់ចោទបានទេ គឺមានស្ថានភាពដូចគ្នានឹងបទសម្ភាសន៍ដែលបានធ្វើជាមួយបុគ្គលម្នាក់ ដែលក្រោយមកបានទទួលមរណភាពដែរ ដែលមិនអាចតទល់ជាមួយនឹងជនជាប់ចោទបាន ។

ដូច្នេះ អង្គជំនុំជម្រះសម្រេចមិនអនុញ្ញាតឲ្យព្រះរាជអាជ្ញាយកឯកសារនេះ មកធ្វើជាឯកសារយោងបានទេ ។ ឯសេចក្តីសម្រេច អង្គជំនុំជម្រះនឹងចេញនៅពេលក្រោយ ។ ហើយក៏សូមជម្រាបជូនភាគីផងដែរ ថាភាគីអាចមានយោបល់លើបញ្ហានេះ ដោយផ្ទាល់មាត់នៅព្រឹកថ្ងៃស្អែក ។

ជាកិច្ចបន្ត សូមប្រគល់វេទិកានេះជូនទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ប្រសិនបើមានសំណួរត្រូវសួរដល់សាក្សីរូបនេះ សូមអញ្ជើញ ។

**លោក គង់ ពិសី៖**

សូមគោរពលោកប្រធាន និងសូមគោរពលោក លោកស្រីចៅក្រមទាំងអស់ ។ ខ្ញុំបាទគង់ ពិសី នៅក្នុងក្រុម២ផង ហើយក្រុម៤ផង ហើយខ្ញុំមកនេះ សូមអនុញ្ញាតលោកប្រធាន ដើម្បីធ្វើការកត់សម្គាល់ខ្លះៗទាក់ទងទៅនឹងមេធាវីអន្តរជាតិរបស់ខ្ញុំជួសឈ្មោះ កញ្ញា ស៊ីលឃី ស្ទួតហ្វ៊ីនស្គី ដែលគាត់បានសួរសំណួរខ្លះៗទៅនឹងសាក្សី ហើយសំណួរទាំងនោះត្រូវបានបកប្រែទៅ មានការឆកល្វែងខ្លះ ។ ហើយខ្ញុំឡើងពីសំណួរទាំងនោះ ជូនដូចតទៅ គឺថាសំណួររបស់កញ្ញា ស៊ីលឃី ស្ទួតហ្វ៊ីនស្គី គាត់បានសួរថា សួរសាក្សីឈ្មោះចាន់ ខន នេះថា តើលោកចាំទេថា *DC-Cam* បានសម្ភាសន៍លោក? សំណួរគឺសួរអ៊ីចឹង ។ ក៏ប៉ុន្តែការបកប្រែបានបកថា តើលោកចាំពីចម្លើយ *DC-Cam* បានសម្ភាសន៍លោកទេ? មួយ សួរថា តើចាំទេថា *DC-Cam* បានសម្ភាសន៍លោក? ដល់បកៗថា តើចាំចម្លើយ *DC-Cam* បានសម្ភាសន៍លោកទេ? បញ្ហានេះគឺថាមានការបកប្រែឆកល្វែងអ៊ីចឹង ធ្វើឲ្យសាក្សីឆ្លើយមិនរួច ។ ចំណុចមួយទៀតៗ កញ្ញា ស៊ីលឃី ស្ទួតហ្វ៊ីនស្គី ដដែលបានសួរថា តើលោចង់ដឹងជោគវាសនាជីតារបស់លោកនៅមន្ទីរម-១៣ ដែរឬទេ? នេះគឺជាសំណួរទៅកាន់សាក្សី ចាន់ ខន តែការបកប្រែៗថា តើលោកដឹងជោគវាសនារបស់ជីតារបស់លោកដែរ ឬទេនៅមន្ទីរម-១៣? អ៊ីចឹងធ្វើឲ្យគាត់មានការភ័ន្តច្រឡំឆ្លើយមិនរួច។ ហើយខ្ញុំបាទសូមឲ្យលោកប្រធានមេត្តាកត់ពីបញ្ហាទាំងអស់នេះក្នុងប្រតិចារឹក ។ សូមអរគុណ។

[១៥:២០:៣៤]

**ប្រធានអង្គជំនុំ៖**

សូមប្រតិចារឹកកត់ត្រាទុកនូវអ្វីជាការកត់សម្គាល់របស់មេធាវីអម្បាញ់មិញនេះ ហើយជាកិច្ចបន្ត សូមអញ្ជើញ មេធាវីការពារ តំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៣ សូមអញ្ជើញបើសិនជាមានសំណួរចង់សួរដល់សាក្សីរូបនេះ ។

**សួរដោយលោក ហ្វីលីព កាណុន៖**

**ស៖** សូមអរគុណលោកប្រធាន លោក ចាន់ ខន តើលោកអារម្មណ៍ស្រួលទេ? លោកមិននឿយហត់ទេឬ?

**សាក្សី KW-32៖**

**ឆ៖** នឿយហត់ដែរ ឆ្លើយច្រើនហើយ ។

**ស៖** ដូច្នេះ ខ្ញុំមិនរំខានលោកច្រើនទេលោក ចាន់ ខន ខ្ញុំមានសំណួរតែពីរ សំណួរទី១ គឺដូចខាងក្រោមនេះ៖

ខ្ញុំត្រឡប់ទៅរកការប្រជុំស្វ័យទិតៀន ដែលលោកបានប្រាប់យើងថា ម្នាក់ៗនៅក្នុងអង្គប្រជុំនោះ ត្រូវតែធ្វើការទិតៀនសមាជិកមួយម្នាក់ទៀត ហើយក៏យើងធ្វើការទិតៀនខ្លួនឯងដែរចំពោះកំហុសដែលយើងបានធ្វើ ។ ដូច្នេះ ខ្ញុំចង់ឲ្យលោកប្រាប់យើង តើលោកទទួលការទិតៀនអ្វីខ្លះ? ហើយលោកធ្វើការស្វ័យទិតៀន បានន័យថា ទិតៀនខ្លួនឯងចំណុចអ្វីខ្លះ?

**ឆ៖** ចំពោះធ្វើការទិតៀន ដែលសំណួរបានសួរ ហើយក៏ខ្ញុំបានឆ្លើយរួចម្ដងមកហើយ ពេលក្នុងរបបខ្មែរក្រហមនោះ គឺអង្គប្រជុំលើកណាក៏ដោយ ឲ្យតែមានការប្រជុំ គឺការទិតៀនគ្នារវាងបុគ្គលមួយទៅបុគ្គលមួយ ។ អ៊ីចឹងឧទាហរណ៍ ដូចរូបខ្ញុំអ៊ីចឹង ធ្វើខុសពីអី មិត្តផ្សេងហ្នឹងគេឃើញខ្ញុំដើរសេរី ឬមួយមិនគោរពការចាត់តាំងរបស់ថ្នាក់លើហ្នឹង គឺត្រូវទិតៀន ។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរមួយទៀតនៅក្នុងសេចក្ដីចម្លើយដែលលោកបានឆ្លើយនៅក្នុង D37 ដែលយោងទៅលើពីព្រឹកមិញបានលើកឡើងនៅក្នុងអត្ថបទបារាំង ជាភាសាបារាំង ទំព័រ៣ លោកបានឆ្លើយថា នៅសំណួរមួយ ហើយលោកបាននិយាយដូចខាងក្រោមនេះ៖

ឌុច នឹងបញ្ជាឲ្យអ្នកយាម ដើម្បីព្រមាន ដើម្បីទប់ស្កាត់ ដើម្បីកុំឲ្យអ្នកទោសប្រព្រឹត្តអត្តឃាតដោយប្រើពាក្យ ឬក៏មិនឲ្យទុកដំបង ឬក៏កន្សែងអ្វី ក្រមាអ្វីនៅជិតដៃគេ ។ តើលោកអាចបញ្ជាក់បានទេ

លោក ចាន់ ខន?

**ឆ៖** អ៊ីចឹង គឺខ្ញុំសូមឆ្លើយនឹងសំណួរ គឺក្នុងហ្នឹងគឺមានបទបញ្ជាមែន គឺតាឌុច បានបញ្ជា គឺថាមិនឲ្យការពារហ្នឹងត្រូវត្រួតពិនិត្យមើលក្នុងគុកហ្នឹង មានឫស្សី ឬមួយមានក្រមា ឬមួយមានដែកអីត្រូវដកចេញ ខ្លាចអ្នកទោសហ្នឹងត្រូវធ្វើឃាតខ្លួនឯង ពិតប្រាកដមែន ។

[១៥:២៥:00]

**ស៖** ប្រសិនបើមានវិធានការអ៊ីចឹងបានអាចអនុវត្ត តើលោកជឿទេថា អ្នកទោសជាច្រើនបានធ្វើអត្តឃាត គឺក៏គេចង់ធ្វើអត្តឃាតដែរឬទេ?

**ឆ៖** ចំពោះបញ្ហាហ្នឹង គឺខ្ញុំរស់នៅក្នុងហ្នឹងគឺមិនដែលឃើញអ្នកទោសណាធ្វើអត្តឃាតខ្លួនឯងទេ មានតែថ្នាក់ដឹកនាំជាន់ខ្ពស់នៅក្នុងអង្គភាពហ្នឹងជាអ្នកបញ្ជាឲ្យធ្វើ បានមាន ។

**លោក ហ្វីលីព កាណុន៖**

លោកប្រធាន ដោយមានការអនុញ្ញាតខ្ញុំសូម អនុញ្ញាតសំណួរខ្លីៗពីរ-បីទៅជនជាប់ចោទ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ហើយសូមជនជាប់ចោទត្រៀមស្តាប់នូវសំណួរដែលនឹងសួរដោយមេធាវី ហើយឆ្លើយឲ្យចំនឹងសំណួរ ។

[១៥:២៦:២៤]

**សួរដោយលោក ហ្វីលីព កាណុន៖**

**ស៖** D៧៨(៤) លោក ឌុច សូមស្តាប់សំណួរដោយប្រុងប្រយ័ត្ន ខ្ញុំចង់ព្យាយាមឲ្យយល់អំពីបញ្ហាមួយចំនួនដែលលោកបាននឹងឆ្លើយនោះ ។

នៅពេលដែលលោកបានឃើញអតីតអ្នកយាមរបស់លោកនៅព្រឹកនេះ លោកនិយាយថាលោកមានមានអារម្មណ៍រំភើប ឬក៏រំជួលចិត្ត តើមែនឬទេ?

**ជនជាប់ចោទ៖**

**ឆ៖** មែន ។

**ស៖** ខ្ញុំមានអារម្មណ៍ថា លោក ឌុច សុំកែខ្ញុំបើសិនជាខ្ញុំសួរទៅខុស ។ ខ្ញុំដឹងថា លោកមាន គឺថាមានមនោសញ្ចេតនាចំពោះអ្នកយាមក្មេងៗរបស់លោក តើទំនាក់ទំនងហ្នឹង វាវិវត្តទៅយ៉ាងដូចម្តេចចំពោះលោកនិងអ្នកយាមក្មេងៗហ្នឹងផ្ទាល់នោះ?

**ឆ៖** អ្នកយាមក្មេងៗជាមនោសញ្ចេតនាស្រឡាញ់គេ ហើយចង់អប់រំគេឲ្យទៅរកផ្លូវមួយ ដែលជំនាន់នោះគេហៅថាបដិវត្តន៍ ។ ក៏ប៉ុន្តែ តាមពិតខ្លឹមសារនៃការអប់រំនេះ វាឈានទៅរកឲ្យគេមានគោលជំហរវណ្ណៈ ប៉ានអនុវត្តផ្តាច់ការវណ្ណៈអធន ។ បានន័យថា ឲ្យគេប៉ានប្រព្រឹត្តបទឧក្រិដ្ឋ ក៏ប៉ុន្តែដោយប្រើពាក្យ កុម្មុយនីស្ត ។

**ស៖** យើងពិនិត្យឃើញថា ហើយលោកបានតាំងខ្លួនអ្វីក្រៅពីអ្នកបណ្តុះបណ្តាល គឺជាអ្នកណែនាំបន្ថែមទៀត តើមែនទេ?

**ឆ៖** ខ្ញុំស្តាប់អត់បានទេ សុំមានប្រសាសន៍ឲ្យស្រួលៗស្តាប់បន្តិច ។

**ស៖** តាមពិតដែលខ្ញុំបញ្ជាក់សំណួរហ្នឹងឡើងវិញ តើយើងអាចនិយាយបានទេថា លោកចង់ធ្វើជាអ្នកណែនាំគេទៅដល់អ្នកយាមក្មេងៗហ្នឹង គឺជាមគ្គុទ្ទេសក៍ដូចជាអ្នកណែនាំគេ?

**ឆ៖** តួនាទីរបស់កម្មាភិបាលបក្ស គឺបណ្តុះបណ្តាលគេឲ្យមានគោលជំហរវណ្ណៈដាច់ខាតចំពោះខ្មាំង ។ នេះវាជាតួនាទី ជាភារកិច្ចរបស់កម្មាភិបាលបក្ស ។ ប្រសិនយើងមើលឥឡូវនេះ បានន័យថាយើងអប់រំដល់បទឧក្រិដ្ឋដោយប្រើពាក្យវប្បធម៌របស់កុម្មុយនីស្ត ឲ្យវាចូលទៅក្នុងសរសៃសរស្វងរបស់គេ ។ គេប៉ានធ្វើបទឧក្រិដ្ឋតាមដែលយើងចង់ ។

[១៥:៣០:២៦]

**ស៖** ឥឡូវនេះខ្ញុំសូមសួរសំណួរទៅលើខ្លឹមសារទាក់ទងទៅនឹងអ្នកទោស ហើយនឹងអ្នកទោសភាគច្រើនដែលនៅទីនោះ ។ យើងបានដឹងថា វាមានបុរស ស្ត្រី កុមារ ហើយនឹងមនុស្សក្មេងៗផង។ តើលោកបានចាត់ទុកថា ដូចម្តេចទេនៅថ្ងៃណាមួយបាននិយាយទៅអង្គការរបស់លោកថា ប្រហែលជាអ្នកទោសអាចនឹងត្រូវទទួលការអប់រំកែប្រែ ហើយនឹងអប់រំគេឲ្យទៅចូលក្នុងសង្គមថ្មី ជាជាងកម្ទេចគេ ។ តើលោកធ្លាប់និយាយរឿងហ្នឹង ទៅប្រាប់ថ្នាក់លើរបស់លោកទេ ឬក៏មិនដែលនិយាយសោះ?

**ឆ៖** បញ្ហានេះខ្ញុំសូមសរុបឡើងវិញ មាននិយាយរប៉ាត់រប៉ាយពីមុនមកខ្លះ។ ការអប់រំមនុស្សដែលមានបញ្ហាស្ថិតនៅក្នុងក្របខ័ណ្ឌមន្ទីរ១៣“ខ” នៅភូមិស្តុកស្រោត យកមកទុកអប់រំដើម្បីដោះលែង។ ឯចំណែកចូលដល់មន្ទីរ១៣“ក” ហើយ មានតែរឿងដាក់ខ្នោះ សួរចម្លើយ ធ្វើទារុណកម្ម ចុងបញ្ចប់កម្ទេច មិនមានរឿងដោះលែងទេៗ ។ សូមបញ្ជាក់ម្តងទៀតថា ខ្ញុំដោះលែង លំបាកបំផុតឈ្មោះ ហម អ៊ីន នេះ ។ ពីឆ្នាំ១៩៧៣មក ខ្ញុំអត់ដែលដោះលែងបានអ្នកណាម្នាក់ទេ ។ ដូច្នេះ មន្ទីរ១៣“ក” គ្មានទេភាសាដោះលែង មានតែភាសាឲ្យកម្ទេច ។ ដូច្នេះ ការអប់រំយុវជននៅកន្លែងនោះទិសដៅ គឺឲ្យគេ

ចេះអនុវត្តផ្តាច់ការវណ្ណៈអធន គឺឲ្យគេប៉ាន១ៗស្សរចម្លើយ ឲ្យគេដាច់ខាតការពារកុំឲ្យរត់រួច សំខាន់គឺអារឿងរត់រួចនោះឯង ។ ឲ្យគេចេះសួរចម្លើយ កុំឲ្យរត់គេរួច ហើយចុងបញ្ចប់ឲ្យគេប៉ានកម្ទេចមនុស្ស ។

[១៥:៣៣:២៥]

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ខ្ញុំយល់ពីអ្វីដែលលោកបានបញ្ជាក់នោះ។ ប៉ុន្តែ ខ្ញុំបានឮអ្វីដែលលោកនិយាយ ប៉ុន្តែខ្ញុំមិនទាន់យល់ច្បាស់ ។ ហេតុអ្វីបាននៅក្នុងឧត្តមគតិរបស់លោកនៅក្នុងសង្គមកុម្មុយនីស្តនោះ ថាតើលោកបានលុបបំបាត់ ឬក៏កម្ទេចជាប្រព័ន្ធ? ហេតុអ្វីក៏លោកមិនបង្រៀន ដោយសារលោកជាបញ្ញវន្ត លោកគឺជាអ្នកពូកែខាងគណិតវិទ្យា ។ លោកបានគោរពទៅតាមហេតុផលច្បាស់លាស់ ហេតុអ្វីបានជាលោកមិនគោរពទៅតាមគោលការណ៍តក្កភាពហ្នឹង ត្រូវបានបំភ្លេចចោលទាំងស្រុងក្នុងគំនិតលោកនៅពេលនោះ?

**ឆ៖** លោក កាណុន សំណួរលោកវែង ខ្ញុំយល់មិនបានគ្រប់ជ្រុងជ្រោយទេ។ ប៉ុន្តែ ឥឡូវសូមសាកល្បងឆ្លើយ ។ ការអប់រំដែលយើងទទួលនៅវិទ្យាល័យវាផ្សេង ការអប់រំរបស់កុម្មុយនីស្តវាផ្សេង ខ្ញុំបាននិយាយរាយការណ៍រួចមកហើយជូនលោកចៅក្រម ឡាវែន៍ ។

ព្រះពុទ្ធហាមមិនឲ្យយើងសម្លាប់សត្វ ពាក្យ“សត្វ”ហ្នឹង បារាំងហៅថា “*អ៊ែត្រឺស វីវ៉ង់ស៍* (ètres *vivants*) ឯចំណែកកុម្មុយនីស្តគេថា “សេចក្តីស្នេហាប្រជាជនពិតប្រាកដត្រូវប្រគល់លទ្ធភាពអនុវត្តផ្តាច់ការទៅឲ្យវណ្ណៈអធន” ។ នេះវណ្ណៈអធនមួយហើយ យើងត្រូវបញ្ចេះគេ បង្រៀនគេឲ្យគេអនុវត្តផ្តាច់ការ។ នេះវាខុសគ្នាអ៊ីចឹង ។ យើងគ្មានសិទ្ធិទៅបង្រៀនតក្កវិជ្ជារបៀបនៅវិទ្យាល័យ យើងគ្មានសិទ្ធិទៅបង្រៀនសិទ្ធិមនុស្ស សេចក្តីថ្លែងការណ៍ជាសកលនៃសិទ្ធិមនុស្សទេ ។ សូមបញ្ជាក់ថានៅកម្ពុជា សេចក្តីថ្លែងការណ៍ណ៍ជាសកលនៃសិទ្ធិមនុស្ស ខ្ញុំឃើញប្រហែលជានៅក្នុងឆ្នាំ១៩៥៥ តែម្តងគត់ ទាល់ឥឡូវបានឃើញច្រើន ។ ដូច្នេះសរុបមក គេអប់រំទៅទិសគេផ្សេង ឯចំណែកនៅមហាវិទ្យាល័យ វិទ្យាល័យ អនុវិទ្យាល័យ គេអប់រំទៅផ្សេង ។ យើងមិនអាច ធ្វើខុសពីទិសដែលគេកំណត់ទេ ខុសកំបុតក ។

**លោក ហ្វីលីព កាណុន៖**

ខ្ញុំបានកត់សម្គាល់លោកបានប្រឹងប្រែងឆ្លើយនូវសំណួររបស់ខ្ញុំ ហើយខ្ញុំមិនមានអ្វីសួរបន្ថែមទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់វេទិកាមេធាវីតំណាងដើមបណ្តឹងនៃក្រុមបួន ។ តើមានសំណួរអីត្រូវសួរដល់សាក្សីរូបនេះទេ?

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** បាទ សូមអរគុណលោកប្រធាន ។ ខ្ញុំបាទមានសំណួរបីបួនដែរ សួរទៅសាក្សី ។ លោកចាន់ ខន បើលោកស្តាប់សំណួរខ្ញុំមិនច្បាស់សូមលោកឆ្លើយថា “សំណួរនេះមិនច្បាស់ទេ” ។ លោកឮខ្ញុំនិយាយទេ?

**សាក្សី KW-32៖**

**ឆ៖** ឮ ។

**ស៖** បើអ៊ីចឹង ខ្ញុំសួរលោកថា មុនពេលសម្រាលលោកឆ្លើយជូនអង្គសវនាការរួចហើយ មិនលើកយកទេអំពីការឆ្លើយនៅប្រាំមួយឆ្នាំមុន ។ ហើយខ្ញុំក៏ចាំដូចគ្នាដែរ ព្រោះថាលោកនៅចាំការសាកសាក្សីរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងឆ្នាំ២០០៨ ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

[១៥:៣៧:២៩]

**ស៖** បើអ៊ិចឹង ខ្ញុំសួរទាក់ទងជាមួយនឹងឯកសារដែលលោកបានឆ្លើយជាមួយលោកសហចៅក្រមស៊ើបអង្កេត ។ ដោយសារលោកជាអ្នកយាមនៅក្នុងមន្ទីរម-១៣ តើលោកជាអ្នកយាមហ្នឹងបានឃើញទិដ្ឋភាពជុំវិញមន្ទីរម-១៣ មានន័យថាជារបង ឬជារណ្តៅចម្រូងដែរឬទេ?

**ឆ៖** អ៊ីចឹង គឺខ្ញុំសូមឆ្លើយនឹងសំណួរ ។ នៅក្នុងមន្ទីរ-១៣ ហ្នឹង គឺមានរបងជុំវិញ ។ របងគុកហ្នឹងប្រហែលជា៥០ម៉ែត្របួនជ្រុង ហើយក្នុងរបងហ្នឹង គឺនៅប៉ែកខាងកើតខាងណោះមានជីករណ្តៅតូចៗសម្រាប់ដាក់ចម្រូងកុំឲ្យអ្នកទោសរត់រួច ។ ហើយនៅជ្រុងខាងណោះ ប៉ែកខាងលិចនេះមានផ្តុកអូរយាមមួយសម្រាប់យាមត្រួតពិនិត្យអ្នកគុកហ្នឹងនៅក្នុងហ្នឹង ។ ហើយនៅប៉ែកខាងជើងអ៊ីចេះ មានផ្លូវចេញចូលមួយតែមួយគត់សម្រាប់ទាំងអ្នកទោសទាំងកងការពារដែលចេញទៅត្រួតពិនិត្យ ។ សូមអស់យោបល់។

**ស៖** សូមអរគុណ ។ តើលោកដែលឃើញ ពាក្យថា “ឃើញ” គឺឃើញនឹងភ្នែក ។ លោកយល់ទេ?

**ឆ៖** បាទ ។

**ស៖** ដែលឃើញមានអ្នកទោសរត់ហើយ ធ្លាក់ស្លាប់នៅក្នុងរណ្តៅចម្រូងដែលឬទេ?

**ឆ៖** យើងខ្ញុំសូមបន្តឆ្លើយសំណួរ ។ ចំពោះអ្នកទោសមិនដែលរត់ចូលរណ្តៅចម្រូងហ្នឹងទេ ។ ចម្រូងហ្នឹងបានត្រឹមតែមកដាក់ទេ គឺអ្នកទោសមិនដែលរត់ទៅចំប្រលោះហ្នឹងទេ ។ សូមអស់ ។

**ស៖** សូមអរគុណ ។ នៅក្នុងចម្លើយ ឬក៏ការសាកសួររបស់សហចៅក្រមស៊ើបអង្កេតលោកបានឆ្លើយបំភ្លឺនៅក្នុងឯកសារ D៧៨(៤) ទំព័រ៤ ។ នេះគ្រាន់ខ្ញុំរំឭកឡើងវិញថា លោកធ្លាប់ឃើញមិញខ្ញុំសួរបញ្ជាក់ថា ឃើញគឺឃើញនឹងភ្នែក ។ អ៊ីចឹង សួរឡើងវិញថា លោកបានឃើញ “កុមារ” ។ លោកស្គាល់ “កុមារ” ទេ?

**ឆ៖** ថឺមិនស្គាល់ “កុមារ” នៅតូចមិនទាន់គ្រប់អាយុ១៨ ។

**ស៖** ចុះទារក?

**ឆ៖** ទារកនៅក្នុងពោះម្តាយ ។

**ស៖** សូមអរគុណ ។ លោកបានឆ្លើយពីព្រឹកមិញទាក់ទងជាមួយនឹងឈ្មោះ “ត្រពាំងច្រាប” តើត្រពាំងច្រាបនៅចម្ងាយប៉ុន្មានពីបរិវេណគុក? សូមកុំច្រឡំបរិវេណគុក គឺលោកបាននិយាយថា ៥០ ម៉ែត្រ ប្រហែល៥០ម៉ែត្រអំមិញ ។ មួយទៀតរបងនៃមន្ទីរ ឬក៏បរិវេណមន្ទីរគុកស្ថិតនៅក្នុងមន្ទីរមានរបង ។ អ៊ិចឹង ត្រពាំងច្រាប ចម្ងាយប៉ុន្មាន ប្រហែលចុះប៉ុន្មានពីកន្លែងគុក?

[១៥:៤០:៥៣]

**ឆ៖** ខ្ញុំសូមឆ្លើយនឹងសំណួរ ។ គឺរបងដែលខ្ញុំបង្ហាញហេតុផលមិញ គឺរបងហ្នឹងវាក្នុងគុកហ្នឹងគុកដែលថារណ្តៅ ថាអីហ្នឹង គឺនៅក្នុងរបងហ្នឹង ហើយដែលខ្ញុំបានបង្អុលថា ខាងណេះដាក់ចម្រូង ខាងណោះដែលនេះគឺ-- ដែលនៅជុំវិញហ្នឹង ជុំវិញ ដូចថា ជ្រុងនេះគឺជាថ្លុកអូរមួយសម្រាប់អ្នកយាម ខ្ពស់ឯណោះ សម្រាប់មើលនេះហ្នឹង-- ហ្នឹងគឺជារបងគុកជុំវិញហ្នឹងប្រហែល៥០ម៉ែត្របួនជ្រុង ។ រីឯត្រពាំងច្រាប នៅខាងជើងអ៊ីចេះ គឺនៅប្រហែលជាដីមិនដល់ម្ភៃម៉ែត្រផងទេ ។ បើនិយាយថាឲ្យចំទៅថាម្ភៃជាងចុះ ក្រែងលោខ្ញុំមិនបានពិនិត្យច្បាស់លាស់ ។

**ស៖** សូមអរគុណ ។ ពីព្រឹកលោកបានជម្រាប និងបានឆ្លើយថា កន្លែងសួរចម្លើយរបស់លោកឌុច នៅខាងជើងត្រពាំងច្រាប ។ អ៊ីចឹងសូមៗដាស់ស្មារតីលោកម្តងទៀតថា តើខាងជើងត្រពាំងច្រាបហ្នឹងកន្លែងសួរចម្លើយមកកន្លែងគុកប្រហែលប៉ុន្មានម៉ែត្រ?

**ឆ៖** អ៊ីចឹង ខ្ញុំបន្តចម្លើយ ។ ព្រឹកមិញនេះ គឺខ្ញុំបានជម្រាបជូនហើយ ប្រហែលជាប្រាំរយម៉ែត្រពីខាងជើងត្រពាំងច្រាប ហើយឆ្ងាយពីត្រពាំង ហួសបឹងស្រែទៀតបានដល់ទួល ។ ហ្នឹងគឺកន្លែងដែលគាត់សួរចម្លើយនោះ គឺមានរោងមួយនៅមានដើមស្វាយពីមុខ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមសួរលោកថា នៅក្នុងការឆ្លើយលោកថាអ្នកទោសត្រូវបានយកទៅមុជទឹកនៅត្រពាំងច្រាប ។ អ៊ីចឹងមែនទេ?

**ឆ៖** ចំពោះអ្នកទោស គឺបញ្ជូនឲ្យទៅងូតទឹកនៅត្រពាំងច្រាប ពិតប្រាកដ ។

**ស៖** តើស្ទឹង និងត្រពាំងច្រាបនៅជិតគ្នាដែរឬទេ?

**ឆ៖** ស្ទឹងនៅខាងត្បូងៗនេះហ្នឹង ស្ទឹងជាប់ពីស្ទឹងក្រាំងពន្លៃទៅហ្នឹង ។ គឺនៅខាងត្បូងគុកហ្នឹងមិនបានប្រាំម៉ែត្រផងទេ ប៉ុន្តែ រង្វង់ដែលស្ទឹងហ្នឹងគឺហូរចាក់ទៅក្រោមអ៊ីចឹង គឺវាព្រៃវាច្រើន ។ ម្ល៉ោះហើយគឺថ្នាក់ដឹកនាំ គឺ តាឌុច ហ្នឹងគាត់មិនឲ្យទៅទេ ស្ទឹង ខ្លាចអ្នកទោសរត់ ។ អ៊ីចឹង ទៅខាងត្រពាំងច្រាបហ្នឹងវាវាលៗហើយសុទ្ធតែចម្ការដំឡូង ចម្ការត្រសក់អីអ៊ីចឹងទៅ ប៉េងបោះអ៊ីចឹង គឺងាយស្រួលក្នុងកងការពារត្រួតពិនិត្យ ។ សូមអស់យោបល់ ។

[១៥:៤៣:៤១]

**ស៖** លោកធ្លាប់យាម ឬធ្លាប់ជូនអ្នកទោសទៅងូតទឹកនៅត្រពាំងច្រាបដែរឬទេ?

**ឆ៖** ឈ្មោះថា “កងការពារ” ថា “អ្នកយាម” គឺធ្លាប់ជូនទៅ ។

**ស៖** សូមអរគុណ ។ ព្រឹកមិញលោកបានឆ្លើយនឹងសំណួររបស់លោកចៅក្រមផងដែរ អំពីការប្រជុំ ហើយមេធាវីក៏បានសួរដែរ ។ ខ្ញុំសួរថា ការប្រជុំ ដឹកនាំប្រជុំដោយ ឌុច ជាប្រធាន ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, ពិតប្រាកដ ។

**ស៖** លោកថាលោក ឌុច បានណែនាំថា “អ្នកទោស” គឺជាខ្មាំង ឯ “អ្នកយាម” គឺជាមិត្ត ។ អ៊ីចឹងទេ?

**ឆ៖** បាទ, ពិតប្រាកដ ។

**ស៖** ខ្ញុំសូមសួរឲ្យលោកមានអារម្មណ៍មួយគិតមកវិញថា ពាក្យ “ខ្មាំង” តើមានន័យថា “រាល់មនុស្សហ្នឹងគឺជាសត្រូវសម្លាប់រស់ ឬយ៉ាងម៉េច? សូមបំភ្លឺត្រង់ហ្នឹងបន្តិច?

**ឆ៖** ព្រោះកាលជំនាន់នោះ គឺខ្ញុំសូមជម្រាបជូនអស់លោក គឺពាក្យថា “ខ្មាំង” គឺគេដាក់គុកគ្នាទៅហើយ ហើយយើងដែលមានសិទ្ធិគឺយើងកំណត់ថា “អ្នកទោសគឺជាខ្មាំងជាមួយយើងហើយ” ។ បើយើងជាអ្នកយាមគេ បានន័យថា ទោះបីថាម៉េចក៏គេហ្នឹង គេថាយើងខ្មាំងជាមួយគេ គេក៏ថាយើងខ្មាំងជាមួយគេដែរ ព្រោះយើងដាក់ខ្នោះគេទៅហើយ ធ្វើបាបគេហើយមិនថាគេ “ខ្មាំង” ។ បើ “មិត្ត” មានដាក់ច្រវាក់ដាក់ខ្នោះគេឯណា “មិត្ត” ហ្នឹងបានន័យថាយើងគ្មានដាក់គេទេ ។

**ស៖** បាទ សូមអរគុណ ។ ហើយខ្ញុំសូមសួរពីរសំណួរទៅទៀតទាក់ទងអំពីលោកបានឆ្លើយថា ឃើញមានបង្គោលសម្រាប់ចងបាញ់សម្លាប់អ្នកទោស ដើម្បីបំភ័យអ្នកទោសដទៃ ។ លោកបានឃើញអ៊ីចឹងមែនទេ?

**ឆ៖** បង្គោលមានមែន ពិតប្រាកដ ។ នៅនេះឯកន្លែងផ្ទុកអូរយាម បង្គោលនៅជ្រុងអ៊ីចេះ ។ បង្គោលហ្នឹងសឹងរាល់ថ្ងៃមិនទាន់របើកផងមិនដឹងទេ ព្រោះបង្គោលវាធំៗ ក្រាស់ ។

**ស៖** នេះគឺជាសំណួរចុងក្រោយ ខ្ញុំសូមសួរថា លោកបានឆ្លើយបំភ្លឺនៅក្នុងអង្គសវនាការនេះ គឺច្បាស់ណាស់ថាលោកខ្លាចលោក ឌុច ។ សូមពន្យល់ថាដោយសារលោកឃើញការសម្លាប់ ឬឃើញការវាយដំ ការធ្វើទារុណកម្ម ឬទេដែលលោកថាខ្លាចនោះ?

[១៥:៤៦:៣៥]

**ឆ៖** ចំពោះរូបខ្ញុំមិនដែល គាត់មិនវាយដេរ វាយដំខ្ញុំទេ ក៏ប៉ុន្តែចំពោះអ្នកទោសគឺគាត់វាយដេរវាយដំពិតប្រាកដ ។ សូមអស់យោបល់ ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ សូមបញ្ចប់ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះសូមប្រគល់វេទិកានេះទៅដល់មេធាវីការពារក្តី ។ តើមេធាវីមានសំណួរអ្វីដែលត្រូវសួរដល់សាក្សីរូបនេះដែរឬទេ? បើមានសូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

**ស៖** សូមអរគុណលោកប្រធាន សូមជម្រាបសួរសាក្សី ។ ខ្ញុំមានសំណួរពីរ-បី ដូចដែលលោកបាននិយាយកន្លងមក លោកមានការនឿយហត់ណាស់មកដល់ពេលនេះ ។ សំណួរទីមួយរបស់ខ្ញុំគឺហេតុអ្វីបានក៏លោកត្រឡប់ចូលទៅបដិវត្តន៍វិញ? ហេតុអ្វីបានជាលោកចូលបដិវត្តន៍នៅពេលអាយុ១៤ ឬ

១៥ឆ្នាំ? លោកនិយាយនេះ ខ្ញុំចូលបដិវត្តន៍ ។ ហេតុអីបានជាលោកចូលបដិវត្តន៍ហ្នឹង?

**ឆ៖** ពាក្យគឺមិនបានពិបាកឆ្លើយទេ ។ ក្នុងយុគសម័យហ្នឹង គឺសម័យសង្គ្រាម ។ អ៊ីចឹង គឺបដិវត្តន៍បដិវត្តន៍មួយម៉ាត់ហ្នឹងដូចអស់លោកទាំងអស់ធ្លាប់ឆ្លងកាត់ពីរបប ប៉ុល ពត ហើយ គឺបដិវត្តន៍ៗមួយម៉ាត់ហ្នឹង គឺខ្លាំងណាស់ ។ អ៊ីចឹងថា ចាត់តាំងចំឈ្មោះរូបណា រូបហ្នឹងត្រូវតែអនុវត្តទៅ បើមិនទៅទេ វាមានកំហុស ឬមួយមានទោសដល់ខ្លួនឯង ព្រោះយើងរស់នៅក្រោមបទបញ្ជាគេ មិនមានសិទ្ធិតម្លៃតវ៉ាដូចយើងរាល់ថ្ងៃនេះទេ ។ សូមអស់យោបល់ ។

**ស៖** អរគុណ ។ គឺខ្ញុំទទួលបានចម្លើយច្បាស់ ម្ល៉ោះហើយគឺនៅពេលចាប់ផ្តើម-- នៅពេលដែលលោកត្រូវបានគេយកទៅម-១៣ ថាតើលោកមានការពេញចិត្តក្នុងការបញ្ជូនទៅម-១៣ ដែរឬទេ? ឬក៏លោកពេញចិត្តក្នុងការបម្រើជួរទ័ពជាង?

**ឆ៖** ព្រោះធម្មតាទាំងរូបគេទាំងរូបខ្ញុំទៅរស់នៅឃើញមនុស្ស ទោះមានទោស អត់ទោសក៏ដោយឃើញជាប់ខ្នោះរប៉ាត់រប៉ាយ ស្គមរយីករយាក លំបាកវេទនាអ៊ីចឹង គឺក្នុងសតិអារម្មណ៍មិនពេញចិត្តទេ ។ ក៏ប៉ុន្តែ បើសិនជាយើងចេះតែរត់ ចេះតែបោល ចេះតែទៅណេះទៅណោះ គឺបណ្តាលឲ្យអាយុជីវិតរបស់យើងស្លាប់ ។ ម្ល៉ោះហើយគឺបក្សប្រគល់ត្រង់ណាត្រូវធ្វើត្រង់ហ្នឹង ។ សូមអស់យោបល់ ។

**ស៖** ដូច្នេះ តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ? ថាតើតាមការចាំរបស់លោក លោកនៅម-១៣ រយៈពេលប៉ុន្មានខែ? តើលោកចាំទេថាតើលោកនៅម-១៣ រយៈពេលប៉ុន្មាន? មួយឆ្នាំ ឬក៏តិចជាងមួយឆ្នាំ?

**ឆ៖** ជំនាន់ហ្នឹងគឺខ្ញុំចាំមិនបានច្បាស់ទេ តែដឹងថាខ្ញុំទៅរស់នៅក្នុងមន្ទីរ-១៣ ហ្នឹងគឺក្នុងឆ្នាំ៧៣ ។ ហើយដល់ចុងឆ្នាំ៧៣ហ្នឹងមិនដឹងជា ដល់៧៤មិនដឹងគឺត្រូវ តាឌុច គាត់បញ្ជូនខ្ញុំ ឲ្យទៅនៅធ្វើស្រែនៅអូរព្រាល ខាងលិចត្រពាំងគ្រើញហ្នឹង គឺខ្ញុំចាំមិនបានច្បាស់ទេអស់លោក ។

**ស៖** នៅពេលដែលលោកទៅដល់ម-១៣ ថាតើ ចាន់ វឿន គាត់នៅទីនោះរួចហើយឬនៅ? តើលោកស្គាល់ ចាន់ វឿន ដែរ ឬទេ?

**ឆ៖** ចាន់ វឿន គឺខ្ញុំស្គាល់ពិត ។ ប៉ុន្តែ ជំនាន់នោះ គឺខ្ញុំភ្លេចដែរមិនដឹងជា ចាន់ វឿន ហ្នឹងត្រូវចូលបដិវត្តន៍ហ្នឹងមុនខ្ញុំ ឬមួយខ្ញុំចូលមុន គឺខ្ញុំអត់បានគិតទេ ។ សូមអស់យោបល់ ។

**ស៖** ប៉ុន្តែ តើលោកអាចប្រាប់យើងបានដែរឬទេ ថាតើលោកនៅម-១៣ ក្នុងខណៈពេល ចាន់ វឿន នៅទីនោះ ប៉ុន្តែខ្ញុំចង់សួរលោកថាតើលោកចាំដែរឬទេ ថាលោកជាមួយ ចាន់ វឿន គឺនៅម-១៣

ជាមួយគ្នា?

**ឆ៖** សូមអានសំណួរមួយលើកទៀត អត់សូវយល់ ។

**ស៖** សំណួររបស់ខ្ញុំគឺថា នៅពេលដែលលោកនៅម-១៣ ថាតើ ចាន់ វឿន គាត់ជាអ្នកយាម នៅទីនោះមែនឬ?

**ឆ៖** ចំពោះ ចាន់ វឿន គឺជាអ្នកយាម ។

**ស៖** សំណួររបស់ខ្ញុំ គឺច្បាស់ណាស់ថា តើ ចាន់ វឿន ដែលជាអ្នកយាមនោះ ហើយលោកហ្នឹងក៏ជាអ្នកយាមដែរ តើគាត់នៅទីនោះហើយ ឬនៅពេលដែលលោកទៅ?

**ឆ៖** ខ្ញុំបានបញ្ជាក់ជូនអស់លោករួចហើយថា មិនដឹងជាខ្ញុំទៅមុន ចាន់ វឿន ឬមួយក៏ ចាន់ វឿន ទៅមុនខ្ញុំ ហ្នឹងខ្ញុំបញ្ជាក់ជូន ព្រោះសម័យនោះគឺខ្ញុំភ្លេចបាត់ទៅហើយ ។ ប៉ុនដឹងច្បាស់ថា ចាន់ វឿន ជាកងការពារជាមួយខ្ញុំ ។ សូមអស់ ។

[១៥:៥៤:៤៦]

**ស៖** ថាតើលោកមានជាប់ពាក់ព័ន្ធជាមួយនឹង ចាន់ វឿន ដែរ ឬទេ? ឬក៏លោកជាសាច់ញាតិរបស់ ចាន់ វឿន ដែរ ឬទេ?

**ឆ៖** ចំពោះ ចាន់ វឿន ហើយនិងខ្ញុំគ្មានសាច់ញាតិ ធាតុអីជាមួយគ្នាទេ គ្រាន់តែមនុស្សរួមក្នុងស្រុក ក្នុងភូមិធ្លាប់រៀនសូត្រពីតូចពីតាចមកធ្លាប់ឃ្វាលគោរស់នៅជាមួយគ្នាទេ គ្រាន់តែប៉ុណ្ណឹងទេ បើមានជាសាច់ញាតិ គឺអត់សុទ្ធ ។

**ស៖** អរគុណ ។ ខ្ញុំសូមឲ្យមានការឆ្លើយបំភ្លឺមួយចំនួន នៅពេលដែលលោកត្រូវបានគេសម្ភាសតាមរយៈការស្នើសុំពីចៅក្រមស៊ើបអង្កេតនៅពេលសម្ភាសន៍នោះ គឺលោកបានលើកឡើងអំពីបង្គោលដែលគេចងអ្នកទោស ។ ហើយលោកបាននិយាយថា បង្គោលទាំងអស់នោះគឺត្រូវបានគេប្រើដើម្បីទុកចងអ្នកទោស ដើម្បីឲ្យអ្នកទោសនោះស្លាប់ហើយនិងគំរាមអ្នកទោសផ្សេងៗ ។ អ្នកដែលបាញ់អ្នកទោស គឺ ចាន់, វន, មាស, ផល, ប៉ាល់-- ផល បាទ សូមទោស ។ ហើយខ្ញុំមិនដែលឃើញ ឌុច បាញ់ទេ ។ តើអ្វីដែលលោកឆ្លើយអ៊ីចឹងគឺតើត្រឹមត្រូវដែរឬទេ? គឺខ្ញុំសូមកែប្រែគឺថា តើគាត់មានដែលឃើញអ្នកទាំងអស់នោះបាញ់ដែរ ឬទេ?

**ឆ៖** ចំពោះអ្នកទាំងអស់នោះធ្លាប់បាញ់ពិតប្រាកដ ។ តែគ្រាន់តែការបាញ់នោះមិនដឹងជាមានបញ្ហាពី តាឌុច ឬអត់ ខ្ញុំអត់បានដឹង ។ តែឈ្មោះអ្នកទាំងអស់នោះគឺធ្លាប់បាញ់ ។ សូមអស់យោបល់ ។

**សៈ** សាក្សីលោកបាននិយាយថា ឌុច ធ្វើការងាររហូត ។ តើលោកអាចប្រាប់យើងខ្ញុំឲ្យបានច្បាស់ដែរឬទេ ថាតើគាត់បានធ្វើអ្វីខ្លះនៅពេលដែលគាត់ធ្វើការគ្រប់ពេលទាំងអស់នោះ?

**ឆៈ** សូមអានសំណួរហ្នឹងមួយលើកទៀត ។

**សៈ** លោកបាននិយាយថា នៅក្នុងការផ្តល់ចម្លើយរបស់លោកថា ឌុច បានធ្វើការនៅទីនោះ នៅកន្លែងម-១៣ នោះ គឺម៉ឺងម៉ាត់ណាស់ ។ សំណួររបស់ខ្ញុំគឺដូចខាងក្រោម ។ តើលោកអាចប្រាប់យើងបានទេ តើការងារអ្វីដែលគាត់ធ្វើនោះ? ដែលគាត់ធ្វើម៉ឺងម៉ាត់គ្រប់ពេលវេលានោះ?

[១៥:៥៨:៣៩]

**ឆៈ** ខ្ញុំសូមជម្រាបជូនអស់លោកថា តាឌុច គាត់ធ្វើអីក៏ម៉ឺងម៉ាត់ដែរ ក្នុងការងារ ។ គឺម៉ឺងម៉ាត់ ហ្មត់ចត់យកស្អាតស្អំ គឺមិនចេះតែធ្វើទេ ។ គឺសម្រេចផែនការអីមួយ គឺគាត់ធ្វើទាល់តែបាន ។ គឺគាត់អនុវត្តចំតួតាមទ្រឹស្តីរបស់កុម្មុយនីស្តតែម្តង ។ គឺគាត់ប៉ានធ្វើអី គឺគាត់ត្រូវធ្វើឲ្យបាន ។ ហ្នឹងហើយដែលខ្ញុំថា គាត់អនុវត្តភារកិច្ច ម៉ឺងម៉ាត់ ហ្មត់ចត់នោះ ។

**សៈ** សូមអរគុណ ។ លោកបានឆ្លើយសំណួររបស់មេធាវីមួយនៅក្នុងថ្ងៃនេះ ដោយនិយាយថា ពាក្យថា “ខ្មាំង” ត្រូវបានប្រើដើម្បីសំដៅដល់អ្នកទោស សម្រាប់ហៅអ្នកទោសថាជា “ខ្មាំង” ។ ហើយក្នុងពេលនោះដែរ លោកបាននិយាយថា ជម្រាបទៅចៅក្រម ឡាវ៉ែន៍ ថា-- ដែលចៅក្រម ឡាវ៉ែន៍ បានសួរនោះ គឺថាខ្ញុំមានការស្មុគស្មាញដោយថាឪពុកមាររបស់ខ្ញុំពីរក៏ជាអ្នកទោសដែរ ។ ខ្ញុំមានការព្រួយបារម្ភ ហើយខ្ញុំបានដឹងថា ពួកគាត់ទាំងពីរនោះមិនមែនជាខ្មាំងទេ ។ តើចម្លើយនោះត្រឹមត្រូវដែរឬទេ?

**ឆៈ** គាត់និយាយថាម៉េចខ្ញុំស្តាប់មិនបានអាត្រង់នោះ?

**សៈ** លោកបានដឹងថា គឺថាជីតារបស់លោកពីររូបក៏បានត្រូវដាក់ឃុំឃាំងដែរ ហើយលោក ដឹងថាជីតានោះមិនមែនជាខ្មាំងទេ ។ អ៊ីចឹងទេ?

**ឆៈ** ខ្ញុំមានបាននិយាយថា គាត់នឹងខ្មាំងឯណា ។ ដូចខ្ញុំប្រកាសអ៊ីចឹង អ្នកដែល-- ដូចគាត់លើកឡើងអ៊ីចឹង អ្នកជាប់គុកគឺជាខ្មាំង ។ រីឯមិត្តផងគ្នាដែលមិនជាប់គុកជាមិត្ត ។ តែចំពោះថា ជីតារបស់ខ្ញុំចូលក្នុងហ្នឹង ទោះបីខ្ញុំថាគាត់មិនខ្មាំងក៏ត្រូវខ្ញុំថាខ្មាំងដែរ ព្រោះអីបើខ្ញុំថាអត់ខ្មាំងទៅ វាអាស្រ័យងាប់ដល់រូបខ្ញុំទៀត ។ ព្រោះជំនាន់នោះមិនមែនធម្មតាឯណា គឺមិនថាម៉ែ មិនថាឪ មិនថាបង មិនថាប្អូនប្រាស់យករួចតែខ្លួនទេ អត់មានទៅចូកចែរនរណាម្នាក់បានទេ ។ គេថាខ្មាំងមួយម៉ាត់ហើយ គឺយ៉ាប់ហើយមានតែចូលរណ្តៅទេ ។ អាហ្នឹងសូមអស់យោបល់ ។

**ស៖** លោកប្រធានខ្ញុំសូមនិយាយទៅរកជនជាប់ចោទវិញម្តង ។ ឌុច លោកបានស្តាប់សាក្សីដែលពីមុនគាត់ជាអ្នកយាមក្មេងម្នាក់ ។ តើលោកបានស្តាប់ពីការពិពណ៌នាអំពីស្ថានភាពដែលគាត់បានដែលថាគាត់ត្រូវតែចាត់ទុកថា ជីតារបស់គាត់សុទ្ធតែជាខ្មាំង? កាលណាដាក់ទោសហើយ តើឌុច មានមតិអ្វីទេក្នុងរឿងហ្នឹង?

**ជនជាប់ចោទ៖**

**ឆ៖** នៅពេលនេះ ដែលខ្ញុំត្រូវនិយាយ ។ និយាយចំពោះ មិត្តខន ម្នាក់ក៏ដូចជានិយាយចំពោះជនរងគ្រោះទាំងអស់ដែលនៅអមលាំង ។ ពីព្រោះទីតាំងរបស់មន្ទីរ-១៣ វានៅអមលាំង ។ ដូចខ្ញុំបាននិយាយពីព្រឹកមិញអ៊ីចឹង ប្រជាជនកម្ពុជាដែលនៅភូមិឃុំអស់នេះ មុនដំបូងគេជឿទុកចិត្តបដិវត្តន៍ណាស់ ប៉ុន្តែ ស្ថានការណ៍វាផុតទៅ ។ ឆ្នាំ៧១ គេថាចិត្តវានៅមូលតែមួយ។ កាលណាឆ្នាំ៧២ គេថា ចិត្តវាបែកខ្ញែកជាពីរហើយ ម្នាក់ទៅលិច ម្នាក់ទៅកើត ។ បានន័យថា ប្រជាជននៅមូលដ្ឋានបង្អែកនេះ គេឃើញបណ្តើរៗហើយ ។ សុំទោសប៉ា! មូលដ្ឋានបង្អែកសុំប្រាប់*តាស្តាប់ពុយ* (ឮមិនច្បាស់)។ នៅឆ្នាំ១៩៧២ ប្រជាជននៅមូលដ្ឋានបង្អែក គេឃើញចរិតបដិវត្តន៍ ដែលនាំទុកមកឲ្យគេវិញកាន់តែច្បាស់បណ្តើរៗហើយ ។

ដល់ឆ្នាំ១៩៧៣ នោះដែលចូលទៅមន្ទីរ១៣ មិនមែនត្រឹមតែគិញនោះទេ គឺចូលទាំងប្រជាជននៅមូលដ្ឋានបង្អែក គឺនៅផ្សារពាម ឃុំអមលាំង ហ្នឹងតែម្តង ។ ផ្សារពាម ឃុំអមលាំងនេះ ឆ្នាំ៧៣ ក្រោយពី ពូប៊ុត គាត់រត់ទៅ ហើយមកវិញមានរឿងកាំភ្លើងឯណាគេភូតភរនោះ តាម៉ុក ឲ្យដេញរកអាកាំភ្លើងនោះ អស់មនុស្សប្រហែលជា៦០នាក់, ៥០នាក់យ៉ាងតិចប៉ុណ្ណឹង ឈ្មោះដែលខ្ញុំនៅចាំឥឡូវនេះ ។ មនុស្សដែលខ្ញុំរាប់ឈ្មោះ រំឭកឈ្មោះឡើងវិញនៅចាំឥឡូវហ្នឹងបានប្រហែលជា៣០នាក់ ។ ដូច្នេះ ចំពោះបញ្ហាឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើប្រជាជននៅអមលាំង វាធំធេង ខ្ញុំនឹកមិនភ្លេចទេ ។ ខ្ញុំបានសន្យាជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងនេះថា ខ្ញុំនឹងសរសេរអត្ថបទមួយប្រហែលជាមានពី១៥ទៅ២០កថាខណ្ឌដើម្បីនឹងរំឭកអំពីឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើប្រជាជននៅអមលាំង ហើយសុំទោស សុំពៃរ៍ជាតិប្រជាជនខ្ញុំ នេះជារឿងពិត ។

ដូច្នេះ សរុបមក ទន្ទឹមនោះ ខ្ញុំអត់ភ្លេច ប៉ុន្តែខ្ញុំគ្រាន់តែអត់ដឹងថា ពូទឹម ឪពុកមាខ្មោច បងខុម អំសុំទោសឪពុកមា បងខុម ដូចជាង សយ ជាងអីហ្នឹង ខ្ញុំអត់ភ្លេចទេ ។ ប៉ុន្តែ ថាឲ្យខ្ញុំទៅបាញ់ ជាងសយដោយដៃឯងហ្នឹងភរ មិនមែនទេ ។ ជាងសយហ្នឹងសូមបញ្ជាក់ លោកអ្នកបកប្រែបន្តិច ជាងសយ មិន

មែន ជា ស ទេ ឈ្មោះគាត់ឈ្មោះ សយ តែគាត់ជាជាងកាត់ដេរ គេហៅ ជាងសយ ។ ដូច្នេះ ហើយបានជាខ្ញុំថា ឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើប្រជាជនអមលាំង ដែលមុនដំបូងគេស្របដណ្តប់ គេឧបត្ថម្ភខ្ញុំដូចកូន ដូចចៅ គេឲ្យកូនគេមកនៅជាមួយនឹងខ្ញុំ ខ្ញុំអប់រំកូនគេៗឲ្យទៅជាអ្នកផ្តាច់ការ ។ អ្នកអនុវត្តផ្តាច់ការ មិនមែនអ្នកផ្តាច់ការ អ្នកអនុវត្តផ្តាច់ការដ៏ស្មោះត្រង់បំផុតរបស់បក្ស ។

ដូច្នេះ សរុបមកការងារនេះ ខ្ញុំមិនដែលជានឹកនាចង់ធ្វើទេ ដូចខ្ញុំបាននិយាយអ៊ីចឹង ខ្ចីមអាចម៍ជាន់អាចម៍ ពីលើកមុនខ្ញុំគិតឃើញថា ធ្វើនគរបាលបែបនៅតំបន់២៥ ថ្ងៃក្រោយកំបុតកដោយសារមេវាក្បត់ ។ ចុំ អត់បកប្រែ! ខ្ញុំសុំម្តងទៀតអត់បកប្រែភាសាបារាំងទេ ។

[១៦:១០:០០]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការសម្របសម្រួលជាមួយអ្នកបកប្រែទៅមើល ម៉េចមានបញ្ហា?

*(មានបញ្ហាបច្ចេកទេសបកប្រែ)*

**ជនជាប់ចោទ៖**

**ឆ៖** ពីលើកមុនខ្ញុំឃើញសភាពការទំនាស់នៅតំបន់២៥ ក្នុងផ្ទៃបក្សកុម្មុយនីស្តកម្ពុជា ខ្ញុំឃើញក្នុងផ្ទៃបក្សកុម្មុយនីស្តកម្ពុជា កាប់ចាក់ៗគ្នាដណ្តើមអំណាច ។ ខ្ញុំសូមបញ្ជាក់ម្តងទៀត លោកអ្នកបកប្រែ ក្នុងផ្ទៃបក្សកុម្មុយនីស្តកម្ពុជា មិនមែនក្នុងកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងផ្ទៃបក្សកុម្មុនីស្តកម្ពុជាៗនៅតំបន់២៥ កាប់ចាក់គ្នាដណ្តើមអំណាច ខ្ញុំស្បថ ខ្ញុំថាអ្ហែ អត់ធ្វើអានគរបាលនេះ ថ្ងៃក្រោយអាមេវាក្បត់ អាកូនវាដាច់ក ជាពិសេស អាមេនគរបាលហ្នឹងដាច់កមុនគេ ។ ហើយដល់មកដល់អមលាំងនេះគេលួងលោមគេថាៗ បក្សអំពាវនាវកុលបុត្ររបស់ខ្លួនឲ្យបំពេញភារកិច្ចនេះ មិត្តត្រូវតែបំពេញ មិនបំពេញមិនបាន ការចាប់ចងគេអ្នកសម្រេច គេអ្នកទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ មិត្តកុំភ័យ ។ ហើយខ្ញុំថា ខ្ញុំមិនប៊ានសម្លាប់មនុស្សទេ គេថា កូនកសិករគេល្អ មិត្តចេញតែបញ្ជាទៅគេធ្វើហើយ យើងមានតែរៀនសូត្រពីគេទេ ។

ខ្ញុំនិយាយអំពីការតាមដានរបស់នគរបាល ត្រូវហ្មត់ចត់ ព្រោះខ្ញុំហើយនិង ឆាយ គឹមហ៊ំ ហៅ ហុក ប្រធានមន្ទីរភូមិភាគនិរតីនេះ ។ ប្រធានមន្ទីរភូមិភាគនីរតី មិនមែនប្រធានភូមិភាគនិរតីទេ ប្រធានមន្ទីរភូមិភាគនិរតីនេះ និងខ្ញុំធ្លាប់បានមើលកុនមួយជាមួយគ្នា។ រោងកុននេះគេនិយាយអំពីចារកម្មនៅស្រុកគេ ល្អិតល្អន់ណាស់ ច្បាស់លាស់ណាស់ ។ គេថា យើងកសាងបណ្តើរៗទៅពីបាតដៃទទេៗ ។

ដូច្នេះ ហើយបានជាដំបូងខ្ញុំមានមោទនភាព *(សុំទោស)* ដំបូងខ្ញុំយល់ច្រឡំគិតណាស់ខំ ខ្ញុំខំណាស់ ខំរកមនុស្សដើម្បីដោះលែង ខ្ញុំដោះលែងបាន១០នាក់ ដូចបានរាយការយ៍ជម្រាបលោកចៅក្រមហើយ ។ ដល់ឆ្នាំ១៩៧៣ ដូចខ្ញុំបានជម្រាបលោកចៅក្រមពីលើកមុន ទិសប្រែហើយ មិនមែនសម្លាប់គិញទេ គឺសម្លាប់វណ្ណៈ គឺកម្មេចវណ្ណៈជិះជាន់ តាមសម្តីបងស៊ី គឺយើងត្រូវកម្ចាត់សក្តិភូមិនាយទុន ។ សក្តិភូមិ គឺស្អី តាមសម្តីបងស៊ី គឺឈ្មោះដើម ជូ ជេត គឺមេឃុំ ប៉ាល់ *(សុំទោស)* មេឃុំ ភឿង មេឃុំ ប៉ាន់ អាហ្នឹងសក្តិភូមិ ។ អាហ្នឹងគេអប់រំទៅអ៊ីចឹង ដូច្នេះ ពី១៩៧៣ មកបដិវត្តន៍វាប្តូរហើយ ។

សរុបមក ខ្ញុំពេលនេះដែលឃើញមុខ មិត្តខន សាជាថ្មី ខ្ញុំតក់ស្លុតចំពោះប្រជាជនដែលដំបូងជឿទុកចិត្តបដិវត្តន៍ ដល់ចុងបញ្ចប់ធ្លាក់ខ្លួនមកអន្តរាយ ដោយសារតែបដិវត្តន៍ ។ ខ្ញុំឈឺចាប់នឹងកំហុសរបស់ខ្ញុំ ដែលសុខចិត្តចុះចាញ់គេ ទទួលភារកិច្ចដែលខ្ញុំស្អប់ខ្ពើម ហើយអនុវត្តភារកិច្ចមួយកុំស្មានថា មិនឧក្រិដ្ឋមហាឧក្រិដ្ឋ ។ មហាឧក្រិដ្ឋមិនមែនត្រឹមតែឧក្រិដ្ឋទេ។ មិត្តខន នៅជាសាក្សីស្រាប់ អ្នកណាជាប់ខ្នោះគឺខ្លាំងហើយ។ ដូច្នេះ មិត្តខនហ៊ានចាត់ទុក ពូតឹម ថាមិនមែនខ្លាំងអ្ហែ អត់ហ៊ានទេ អាណាអប់រំ? គឺខ្ញុំអ្នកអប់រំ ។ ដូច្នេះ មិនមែនជាបញ្ហា មាស មិនមែនជាបញ្ហា ប៉ុន គឺបញ្ហាខ្ញុំ ព្រោះខ្ញុំអប់រំគេ ខ្ញុំរៀបចំការចាត់តាំងមួយឲ្យបានខ្លាំងក្លាដើម្បីអនុវត្តផ្តាច់ការនៅទីនេះ ។ សូមទោសណ៎ា មិត្តខន ខ្ញុំសុំនិយាយត្រង់ហើយមិត្តមើលទៅ ខ្ញុំមើលទៅ ខ្ញុំមិនទាន់ពេញចិត្ត ខ្ញុំរកលេសបញ្ជូនមិត្តទៅខាងស្រែឯណោះ ឲ្យដាច់ពីគេ ។ នេះគឺខ្ញុំហ្នងមើលទៅវាមិនលូតលាស់ទៅដូច មាស ខ្ញុំបញ្ជូនទៅអ៊ីចឹង ខ្ញុំនិយាយត្រង់ហើយថ្ងៃហ្នឹង ។

ដូច្នេះ សរុបមកវិញពេលនេះ ខ្ញុំនិយាយសរុបរឿងនៅម-១៣ ឲ្យអស់ ឲ្យស្គាល់ថា ឧក្រិដ្ឋកម្មរបស់ខ្ញុំប៉ុនណា ។ ថ្វីត្បិតតែបញ្ហានេះ មិនចូលទៅក្នុងសំណុំរឿងកាត់ទោសក៏ដោយ ខ្ញុំត្រូវតែខំរៀនគិតដើម្បីសារភាពជាតិប្រជាជនខ្ញុំឲ្យអស់ ឥឡូវអត់ទាន់អស់ទេ និយាយហ្នឹងអត់ទាន់អស់ទេ ។ សូមជាតិប្រជាជនកម្ពុជា លោកចាំពាក្យសន្យារបស់ខ្ញុំចុះ ខ្ញុំសុំចប់ប៉ុណ្ណេះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកសាក្សី ខ្ញុំមិនមានសំណួរអ្វីទៀតទេ ។

សូមអរគុណលោកប្រធាន លោកចៅក្រមផងដែរ ។

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអីទេ លោកសហព្រះរាជអាជ្ញាអន្តរជាតិមុន បើសិនជាមាន ។ សូមខ្ចីចុះបានហើយសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ខ្ញុំអត់មានសំណួរចំពោះសាក្សីនោះទេ ។ ប៉ុន្តែ គឺខ្ញុំសូមដាក់សេចក្តីសន្និដ្ឋាន ចំពោះអង្គជំនុំជម្រះសាលាដំបូង ហើយខ្ញុំមិនចង់បាត់បង់ឱកាស ក្នុងការដាក់សេចក្តីសន្និដ្ឋាននេះ សូមឲ្យលោកចៅក្រមធ្វើការឲ្យសាក្សីនេះបញ្ចប់ ឬក៏ឲ្យគាត់បញ្ចប់ ធ្វើការងារបញ្ចប់ទៅលើសាក្សីសិនទៅ បន្ទាប់មកខ្ញុំនឹងធ្វើការដាក់សេចក្តីសន្និដ្ឋានរបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ សូមជម្រាបអ៊ីចេះថា អង្គជម្រះទុកឱកាសដល់ភាគី នឹងធ្វើសេចក្តីកត់សម្គាល់របស់ខ្លួន ឬក៏សេចក្តីសន្និដ្ឋាន សមល្មម ប៉ុន្តែដោយសារពេលវេលាអស់ យើងលើកទៅថ្ងៃស្អែក ដើម្បីឲ្យធ្វើ នេះជាផែនការក្នុងការគ្រប់គ្រងសវនាការ ។ អ៊ីចឹង គឺបំណងនេះ យើងនឹងទុកសិទ្ធិជូនភាគីក្នុងការធ្វើសេចក្តីសន្និដ្ឋាន ឬកត់សម្គាល់នៅព្រឹកថ្ងៃស្អែក ។

លោក ចាន់ ខន អង្គជម្រះអរគុណលោក ដែលបានអញ្ជើញមកផ្តល់សក្ខីកម្មតាមការកោះហៅរបស់អង្គជម្រះសាលាដំបូង ហើយដល់ពេលនេះអស់សំណួរហើយ ។ អ៊ីចឹង សូមលោកអញ្ជើញទៅកាន់លំនៅដ្ឋានវិញចុះ មន្ត្រីតុលាការចាត់ចែង រៀបចំគាត់ ជូនទៅឲ្យអង្គភាពគាំពារសាក្សីនិងអ្នកជំនាញដើម្បីរៀបចំគាត់ជូនទៅលំនៅដ្ឋានវិញ ។

អង្គជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងបន្តនៅព្រឹកថ្ងៃស្អែក ចាប់ផ្តើមពីម៉ោង៩ទៅ ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយជម្រាបផងដែរ ដល់អ្នកចូលរួមក្នុងសវនាការ សូមអញ្ជើញមកថ្ងៃស្អែកឲ្យបានមុនម៉ោង៩ ៕

*[សវនការផ្អាកនៅម៉ោង ១៦:២២ នាទី]*